ទស្សនាវដ្ដីស្រាវជ្រាវ

# រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia Journal

លេខ៩ ខែកញ្ញា ឆ្នាំ២០២២ | Vol.9-September-2022



រក្សាសិទ្ធិគ្រប់យ៉ាង

**នាយកការផ្សាយ**

ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច**

**និពន្ធនាយក**

ឯកឧត្តមបណ្ឌិត **យង់ ពៅ**

**គណៈកម្មការនិពន្ធ**

ឯកឧត្តមបណ្ឌិត **នូ ចាន់សុភី**

ឯកឧត្តមបណ្ឌិត **ផុន កសិកា**

ឯកឧត្តមបណ្ឌិត **អ៊ឹម បុណ្ណា**

ឯកឧត្តមបណ្ឌិត **នុត សម្បត្តិ**

ឯកឧត្តមបណ្ឌិត **គិន ភា**

ឯកឧត្តមបណ្ឌិត **មាឃ បូរ៉ា**

ឯកឧត្តមបណ្ឌិត **គី សេរីវឌ្ឍន៍**

ឯកឧត្តម **សូត្រ សំណាង**

ឯកឧត្តមបណ្ឌិត **ហ៊ាន សុខុម**

លោក **ហេង វីរិទ្ធិ**

លោក **សាន សុរាវនិត**

**លេខាធិការដ្ឋានបោះពុម្ពផ្សាយ**

លោកស្រី **កែវ ខេមរា**

លោក **ធឿន សុត្ថា**

លោក **ហេង ហុកវេន**

លោកស្រី **សំរិទ្ធ ចរិយា**

លោក **កៅ សុម៉ាឡេត**

លោក **គ្រឿង មករា**

លោក **ភួយ បញ្ញា**

# អារម្ភកថា

ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងការបោះពុម្ពផ្សាយជាកត្តារួមចំណែកមួយក្នុងការអភិវឌ្ឍសង្គមជាតិដែលក្នុងនោះរាជបណ្ឌិត្យសភាកម្ពុជាបានធ្វើការសិក្សាស្រាវជ្រាវលើជំនាញផ្សេងៗនិងបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដីស្រាវជ្រាវ នៃរាជបណ្ឌិត្យសភាកម្ពុជាជាច្រើនលេខរួចមកហើយ។ នៅក្នុងលេខទីប្រាំបួននេះមានអត្ថបទជាច្រើនទៀតដែលទាក់ទងនឹងវប្បធម៌ ភាសាវិទ្យា អប់រំ គីមីវិទ្យា អក្សរសិល្ប៍ ទស្សនវិជ្ជា និងរដ្ឋបាលសាធារណៈជាដើម សុទ្ធសឹងជាអត្ថបទសិក្សាស្រាវជ្រាវ និងវិភាគបែបវិទ្យាសាស្ត្រ ដែលអាចជាជំនួយស្មារតីដល់អ្នកសិក្សាស្រាវជ្រាវផងដែរ។

ទស្សនាវដ្ដីស្រាវជ្រាវ នៃរាជបណ្ឌិត្យសភាកម្ពុជាបានរួមចំណែកផ្សព្វផ្សាយស្នាដៃស្រាវជ្រាវបែបវិទ្យាសាស្ត្ររបស់ បណ្ឌិត្យសភាចារ្យ អ្នកស្រាវជ្រាវ និងអត្ថបទសិក្សាស្រាវជ្រាវរបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងបេក្ខជនបណ្ឌិត។ ការបោះពុម្ពផ្សាយនូវស្នាដៃស្រាវជ្រាវថ្មីៗបែបវិទ្យាសាស្ត្រគឺដើម្បីផ្ដល់នូវចំណេះដឹងបែបវិទ្យាសាស្ត្រជូនដល់សង្គមជាតិ និងជួយសម្រួលដល់អ្នកសិក្សាស្រាវជ្រាវស្វែងយល់ ក៏ដូចជាជួយជម្រុញដល់អ្នកស្រាវជ្រាវទាំងឡាយកាន់តែមានឆន្ទៈស្រាវជ្រាវប្រកបដោយវិទ្យាសាស្ត្រ។

គណៈកម្មការរៀបចំទស្សនាវដ្ដីសង្ឃឹមថា អត្ថបទទាំងអស់ដែលបានចុះផ្សាយក្នុងទស្សនាវដ្ដីស្រាវជ្រាវនេះនឹងក្លាយជាឯកសារដ៏សំខាន់មួយ សម្រាប់ការសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ។

គណៈកម្មការរៀបចំរង់ចាំទទួលមតិរិះគន់ក្នុងន័យស្ថាបនាពីសំណាក់អ្នកអាននិងអ្នកស្រាវជ្រាវគ្រប់មជ្ឈដ្ឋានដើម្បីកែលម្អនូវចំណុចខ្វះខាតនិងកំហុសឆ្គងដែលអាចកើតមានដោយអចេតនា ទាំងលើខ្លឹមសារ និងផ្នែកបច្ចេកទេស ឱ្យកាន់តែមានសុក្រិតភាព។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២

**គណៈកម្មការទស្សនាវដ្ដីស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជា**

# មាតិកា


១. ប្រវត្តិការកកើត និងការវិវត្តន៍នៃល្ខោនបាសាក់ បេក្ខជនបណ្ឌិត **តាំង វ៉ាំងថង** ---------------------- ១

២. ការវិភាគនៃគោលការណ៍អាស្រ័យផ្ទត់ បេក្ខជនបណ្ឌិត **ផល សូភឿន** ------------------------------ ៩

៣. ទេវរាជៈ និមិត្តរូបនៃការបង្កើតស្ដេចទេវរាជនាសម័យអង្គរ បេក្ខជនបណ្ឌិត MIAO Si ---------- ១៧

៤. ជំនឿសាសនា បេក្ខជនបណ្ឌិត **សុំ សុខា**------------------------------------------------------- ៣៧

៥. បម្រែបម្រួលបរិមាណអ៊ីយ៉ុងស្យានូនិងនីត្រាតក្នុងមើមដំឡូងមីតាមពូជនិងអាយុកាលលូតលាស់ បេក្ខជនបណ្ឌិត **ប៉ក់ វណ្ណៈ**------------------------------------------------------------------------ ៥១

៦. ការបង្រៀននិងរៀនមុខវិជ្ជាសិក្សាសង្គមនៅបឋមសិក្សា បេក្ខជនបណ្ឌិត **សេង បូណា** ---------៥៧

៧. ការរៀបចំប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈរបស់បណ្ដាប្រទេសអាស៊ាន បេក្ខជនបណ្ឌិត **សឹង សំណាង**---------------------------------------------------------------------------------------៦៧

៨. សារៈសំខាន់នៃការគ្រប់គ្រងធនធានមនុស្ស បេក្ខជនបណ្ឌិត **ហ៊ុន ដានី** ----------------------- ៧៣

៩. ទ្រឹស្តីស្ត្រីបរិបទសកលនិងតួនាទីក្នុងកងយោធពលខេមរភូមិន្ទនៅកម្ពុជា បេក្ខជនបណ្ឌិត **ដាំ ដាវីនី** ---------------------------------------------------------------------------------------------------៧៩

១០. ស្ត្រីកម្ពុជាក្នុងសម័យសកលភាវូបនីយកម្ម បេក្ខជនបណ្ឌិត **តាន់ ផល្លី** -----------------------៨៥

# ប្រវត្តិការកកើត និងការវិវត្តនៃល្ខោនបាសាក់

បេក្ខជនបណ្ឌិត **តាំង វ៉ាំងថង** ជំនាញ **អក្សរសិល្ប៍** ជំនាន់ទី៥ វគ្គ១

## ១. និយមន័យល្ខោនបាសាក់

ល្ខោនបាសាក់នេះ កើតមកពីភូមិស្រុកកម្ពុជាក្រោម ដែលយើងនិយមហៅថាស្រុកបាសាក់។ តាមព័ត៌មានពីលោកតា ឆា គ្រន់ ជាអ្នកដឹកនាំយកល្ខោននេះចូលមកសំដែងនៅស្រុកខ្មែរនៅឆ្នាំ១៩៣០ លោកនិយាយថាដំបូងនៅស្រុកកម្ពុជាក្រោម មានក្រុមល្ខោនយីកេលេងតាមស្រុកភូមិ ដូចនៅកម្ពុជាកណ្តាលយើងនេះដែរ។ ប៉ុន្តែដល់មើលយូរដែលៗពេកអ្នកស្រុកក៏ធុញទ្រាន់មានអ្នកខ្លះចូលចិត្តទៅមើលហាតបូយយួនទៅវិញ។ ជួនកាល ហាតបូយនោះតុបតែងឆាកលម្អគ្រឿងតាមបែបកែលឿង(ល្ខោនសម័យថ្មី)ផង ក៏ជាហេតុនាំឱ្យរឹតតែប្លែកភ្នែកណាស់ទៅទៀត។ ម្ល៉ោះហើយ គាត់មានគំនិតតម្រូវចិត្តអ្នកស្រុក ក៏យកល្ខោនយីកេកាឡៃទៅជាបែបហាតបូយ ជាល្ខោនច្រៀង មិនមែនរបាំរេរាំទេ។ ពេលគេសំដែងមានច្រៀងរៀបរាប់ខ្លួនឯងតាមដំណើរ ឥតមានអ្នកពោល ហើយធ្វើតាមកាយវិការទៅតាមសភាវគតិគឺលោត រត់ ដួល ដើរ ប្រកាច់ ប្រដេញគ្នា លួងលោមចែចង់គ្នា ទៅតាមសាច់រឿង។ វេលានោះមានមនុស្សជាច្រើន អ្នកចាស់ អ្នកក្មេងហៅល្ខោននេះថាយីកេៗ ព្រោះមានដើមកំណើតពីល្ខោនយីកេ។ ល្ខោននេះបានចូលមកដល់ក្រុងព្រៃនគរ រឹតតែល្បីទៀត មានទាំងពួកយួនៗមកមើលកកកុញផង រហូតដល់មានអ្នកមកពីភ្នំពេញទៅឃើញក៏បបួលដឹកនាំមកសំដែងនៅប្រទេសខ្មែរ។ លុះមកដល់ក៏ទទួលបានជោគជ័យយ៉ាងខ្លាំង ព្រោះល្ខោននេះមានកាយវិការហ៊ឹកហ៊ាក់រហ័សរហួន មើលមិនធុញ។ លេងនៅក្នុងភ្នំពេញ រួចដឹកនាំទៅលេងនៅតាមបណ្តាខេត្តទៀត ប៉ុន្តែគេទៅតាមតែខេត្តដែលនៅតាមមាត់ទឹកដូចជា កំពង់ចាម ក្រចេះ កំពង់ឆ្នាំង ព្រោះក្រុមល្ខោននេះគេនៅនឹងទូកប៉ុកចាយធំ បើលើកទៅណាទៅទាំងទូក មានកន្លែងដេកនៅ បាយទឹក និងប្រដាប់ប្រដា សម្ភារៈសម្រាប់ធ្វើរោង រនាំងសំពត់ កៅអីដែកបត់ អាចដំឡើងបានភ្លាមៗ នៅទីណាក៏បានឱ្យតែមានដីវាល[១]។

ក្រោយពីសិក្សាស្រាវជ្រាវអំពីទម្រង់ល្ខោនបាសាក់មកយើងពិនិត្យឃើញថាល្ខោនបាសាក់គឺជាក្រដាស់ផ្តិតយ៉ាងក្រាស់ដែលតែងតែស្រូបយកនូវចំណុចនិងមធ្យោបាយសំខាន់ៗពីទម្រង់សិល្បៈដទៃទៀតដោយមិនរើសមុខឬគេច្រើននិយាយថា ល្ខោនបាសាក់ជាចង្ក្រានដែលមានភ្លើងឆេះផ្តោលដោយអុសគ្រប់ធុន។ ដោយល្ខោនបាសាក់បានចាប់កំណើតឡើងនៅក្នុងតំបន់មួយដែលមានជាតិសាសន៍ចម្រុះគ្នា "ខ្មែរ ចិន វៀត ណាម" ដែលជាដំបូងនោះ គេសង្កេតឃើញជាតុទាំង៣ នេះមានរួចជាស្រេចនៅក្នុងទម្រង់ល្ខោនបាសាក់។ ប៉ុន្តែចាប់ពីឆ្នាំ១៩៣០ ក្នុងពេលដែលទម្រង់ល្ខោនបាសាក់នេះបានកើតឡើង និងវិវត្តន៍មកដល់កម្ពុជាកណ្តាលទម្រង់

---

[១] លី ធេមតេង *ការស្រាវជ្រាវល្ខោនខ្មែរ* ទំព័រទី៧។

នេះបានស្រូបយកមធ្យោបាយផ្សេងៗ អំពីល្ខោនប្រាមោជ្ជទ័យ និងល្ខោនមហោរី ដូចជាយកបទមហោរីជាច្រើនបទមកបន្ថែមទៀតក្នុងទម្រង់របស់ខ្លួនជាដើម[២]។

នៅចន្លោះអំឡុងឆ្នាំ១៩៦២-១៩៧០ ភាពយន្តចិនបែបកាប់ដាវ និងប្រដាល់បែបកាវ៉ាត់តេ បានជះឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងសង្គមខ្មែរ ល្ខោនបាសាក់ក៏បានស្រូបយកបែបកាប់ដាវ ក្បាច់កាវ៉ាត់តេ ព្រមទាំងសម្រែកយ៉ាងខ្លាំងរបស់កុនចិន មកបំពេញឱ្យទម្រង់របស់ខ្លួនថែមទៀត។ នេះបង្ហាញឱ្យឃើញថាទម្រង់សិល្បៈល្ខោនបាសាក់(ជាសម្លកកូរមួយឆ្នាំង) ដែលអាចស្រូបយកបន្លែគ្រប់មុខ ពិសេសគឺអង្ករលើងដែលជាគ្រឿងផ្សំដើម បញ្ចេញក្លិនថាជាសម្លកកូរ។ បើបាត់ឬពុំមានអង្ករលើងទេនោះគឺមិនមែនជាសម្លកកូរខ្មែរឡើយ។ យើងខ្ញុំចង់បញ្ជាក់ថា ទោះបីល្ខោនបាសាក់ស្រូបយកឬទាញយកទាំងកាយវិកា ទាំងចម្រៀង ឬសម្លៀកបំពាក់ខ្លះៗពីទម្រង់សិល្បៈបរទេសផ្សេងៗ ក៏ទម្រង់នេះនៅតែរក្សាពណ៌សម្បុរ និងគុណតម្លៃខាងខ្លឹមសារនៃទម្រង់របស់ជាតិខ្លួនជានិច្ច។

## ២. ការកកើត និងការវិវត្តនៃល្ខោនបាសាក់

### ២.១. ការកកើត (១៩១០ –១៩៣០)

តាមឯកសាររបស់អ្នកស្រី ដាំង វូធីថាវ (Đang Vu Thi Thao) សិក្សានិងសម្ភាសន៍លោក សឺន ហ៊្វិញ (Son Huynh) សាស្ត្រាចារ្យបង្រៀននៅសាលា ឯកទេសវប្បធម៌ខេត្តហូវយ៉ាង ស្តីអំពីទម្រង់សិល្បៈល្ខោនបាសាក់ខេត្តឃ្លាំង បានឲ្យដឹងថា "នៅខេត្តឃ្លាំង អ្នកដែលបង្កើតក្រុមល្ខោនបាសាក់គឺលោក លី គួន (Ly Cuon)។ លោក លី គួន (Ly Cuon) ជាជនជាតិខ្មែរម្នាក់ រស់នៅឃុំ អាន និញ (An Ninh) (សព្វថ្ងៃចំណុះខេត្តហូវយ៉ាង)។ ក្រោយមកគាត់បានបង្កើតក្រុមល្ខោនបាសាក់ហើយធ្វើជាគ្រូបង្ហាត់ដោយខ្លួនឯង។ រីឯនៅខេត្តត្រាវិញ (ព្រះត្រពាំង) គេដឹងស្គាល់ឈ្មោះ គ្រូល្ខោនមួយទៀតគឺ លោកគ្រូ គឹម សួ គាត់ជាមេក្រុមផងហើយជាអ្នកបង្ហាត់សំដែងដល់ សិល្បករ សិល្បការិនី ទៀតផង" [៣]។

ដើម្បីឈ្វេងយល់បន្ថែមពីលោក គឹម សួ យើងខ្ញុំបានស្វែងរកពូជអំបូរ កូនចៅរបស់គាត់ ដែលរស់នៅឃុំហ៊ីវទឺ និងឃុំហ្វាឡើយ។ ឆ្លងតាមការសម្ភាសន៍ជាមួយ ព្រះតេជគុណ គិម ជុំ ជាព្រះចៅអាធិការវត្តពោធិវង្សកំពង់ដូង (ផ្នោរដូង) ស្ថិតនៅឃុំហ៊ីវទឺ ស្រុកទីកឺន ខេត្តត្រាវិញ ព្រះអង្គជាចៅទួតរបស់ លោក គឹម សួ មានសង្ឃដីកាបានឱ្យដឹងថា *"លោក គឹម សួ មានឈ្មោះពិតគឺ គឹម សួន កើតឆ្នាំ ១៨៨៤ នៅភូមិចុងង ឃុំហ៊ីវទឺ ស្រុកទីកឺន ខេត្តត្រាវិញ។ លោក គឹម សួ មានបងប្អូនបង្កើតទាំងអស់ ៥រូបគឺៈ អ្នកស្រី គឹម អូន អ្នកស្រី គឹម ធីតូច អ្នកស្រី គឹម ធីដួង លោក គឹម សួន និងអ្នកស្រី គឹម ធីហ្វាន់។ លោក គឹម សួ មានប្រពន្ធពីរូប*

---

[២] ពេជ្រ ទុំក្រវិល *ទស្សនីយភាពសិល្បៈខ្មែរ* បោះពុម្ពឆ្នាំ២០០៣ ទំព័រទី១៥៥-១៦០។

[៣] Nhiều tác giả, (1988), *Tìm hiểu vốn văn hóa dân tộc Khmer Nam Bộ*, NXB Viện Văn hóa Tp Hồ Chí Minh và tỉnh Hậu Giang tr. 290-292.

*ប្រពន្ធទីមួយ មិនបានរំឭកដល់ទេ ចំណែកឯប្រពន្ធទីពីររបស់លោក គឹម សួ គឺរស់នៅភូមិខ្សាច់កណ្តាល ឃុំហ្វាឡើយ ស្រុកចូវថាញ់ ខេត្តត្រាវិញ។ សព្វថ្ងៃនេះមានចៅទួតរបស់គាត់កំពុងរស់នៅភូមិខ្សាច់កណ្តាលដែរ។ ក្នុងអំឡុងឆ្នាំ១៨៧៩ តាទួតរបស់ព្រះអង្គ ជាអ្នកមានចំណេះខាងអក្សរសិល្ប៍ អក្សរសាស្ត្រ មានទេពកោសល្យខាងនិពន្ធ និងកំណាព្យយ៉ាងជ្រៅជ្រះ ក៏បានប្រមូលអ្នកមានចំណេះដឹងខាងអក្សរសាស្ត្រ អក្សរសិល្ប៍ដូចគ្នា ដើម្បីហាត់សំដែងទម្រង់សិល្បៈល្ខោន ដើមដំបូងគេហៅថាល្ខោន "ទ្រើងឃ្លោក"។ ក្រោយមកល្ខោនទ្រើងឃ្លោក មានសកម្មភាពរស់រាននិងសាយភាយជាបន្តបន្ទាប់រហូតមក។ ដោយបំណងប្រមូលអ្នកមានចំណេះដឹងខាងអក្សរសាស្ត្រ អក្សរសិល្ប៍ និងកំណាព្យ ដើម្បីហាត់រៀន ទម្រង់ល្ខោនទ្រើងឃ្លោកនេះ ក្នុងន័យបន្តវេនថែរក្សាមរតកសិល្បៈពីចាស់ទុំ ជំនាន់ដើម ដែលបន្សល់ទុកឱ្យមនុស្សជំនាន់ក្រោយបានឃើញ បានស្គាល់ ស្រឡាញ់ ចូលចិត្ត ហើយរួមគ្នា អភិរក្សឱ្យគង់វង្ស ទើបលោកតា សួន បានខិតខំនាំគ្នារៀបចំការហាត់រៀន ដើម្បីសម្តែងឱ្យមហាជនបានទស្សនាក្នុងពិធីបុណ្យផ្សេងៗ។ ពេលនោះមហាជនមើលឃើញ រោងសម្តែងមានដាំដើមឫស្សីជាជួរដូចទ្រើងឃ្លោក ហើយយកស្លឹកឈើគ្របពីលើ ដើម្បីបិទបាំងកំដៅ ឫសន្សើមនាពេលយប់។ ចាស់ទុំក៏ហៅល្ខោននោះថា៖ "ល្ខោនទ្រើង ឃ្លោកៗ" រហូតមក"*[៤]។

ក្នុងអំឡុងពីឆ្នាំ ១៩២៦-១៩៣៣ ក្រៅពីក្រុមល្ខោនទ្រឹងឃ្លោករបស់លោក គឹម សួ នៅមានក្រុមល្ខោនមួយទៀត បានបង្កើតនៅភូមិប្រសាទ ឃុំង្វៀតហ្វា ស្រុកចូវថាញ់ ខេត្រត្រាវិញ។ ឆ្នាំ ១៩២៩ មានក្រុមល្ខោនមួយទៀតបានបង្កើតនៅ ភូមិកំពង់ក្សាន្ត (សព្វថ្ងៃជាសង្កាត់ទី៦ទីក្រុងត្រាវិញ) និងមានក្រុមល្ខោនផ្សេងៗជាច្រើនទៀតបានកកើតឡើងក្នុងដំណាក់កាលនេះ ដូចជា៖ ក្រុមល្ខោនភូមិកោះ ភូមិសំរោង ភូមិចម្ការ ភូមិខឿន ភូមិចេកភូមិថ្មទល់ ។ល។ ក្រុមល្ខោនទាំងអស់នេះពេលសំដែងច្រើនតែយកឈើស្ងួតដុតឱ្យឆេះសន្ធោសន្ធៅ សម្រាប់បំភ្លឺទីសំដែង។

ដំណាក់កាលដំបូងនៃការបង្កើតទម្រង់សិល្បៈល្ខោនបាសាក់ គឺកើតចេញពីការចលនាសកម្មភាពសិល្បៈមហាជនសម្រាប់កម្សាន្តនិងរំឭកនូវអ្វីដែលជាវប្បធម៌ ប្រពៃណី របស់ជាតិ។ ការកកើតនៃទម្រង់សិល្បៈល្ខោនក៏បានចាប់ផ្តើមអភិវឌ្ឍខ្លួនបន្តិចម្តងៗ តាំងពីក្រុមតូចៗ រហូតដល់ក្រុមដែលមានទ្រង់ទ្រាយធំជាបណ្តើរៗ។ ចាប់កំណើតពីលោក Ly Cuon បានបង្កើតជាទម្រង់សិល្បៈមួយនៅក្នុងតំបន់វាលរាបទន្លេមេគង្គដោយពិតប្រាកដ។ ទម្រង់សិល្បៈនេះបានកកើត និងអភិវឌ្ឍខ្លួនក្នុងមហាជន ហើយបានរីកចម្រើនបន្តិចម្តងៗទៅកាន់ភាពថ្លៃថ្នូរ មានប្រជាប្រិយភាពខ្លាំងក្លា ពេលបានស្រូបយកឥទ្ធិពលខ្លះពីទម្រង់សិល្បៈរបស់ជនជាតិចិន និងជនជាតិវៀតណាមក្នុងអនាគត។

---

[៤] ក្រុមសិក្សាស្រាវជ្រាវអំពីសិល្បៈប្រជាប្រិយខ្មែរតំបន់វាលរាបទន្លេមេគង្គ របស់សាកលវិទ្យាល័យត្រាវិញ សម្ភាសន៍សិល្បៈករឆ្នើម ថាច់ ចឺន (អតិតប្រធានក្រុមសិល្បៈរស្មីប្រទីបខេត្តត្រាវិញ) ឆ្នាំ២០១៨។

## ២.២. ការវិវត្ត

### ក. ដំណាក់កាល ១៩៣១ – ១៩៦០

ដំណាក់កាលនេះ បានសម្គាល់ថាជាដំណាក់កាលរីកចម្រើននៃទម្រង់សិល្បៈល្ខោនបាសាក់នៅដែនកម្ពុជាក្រោម ក្រុមល្ខោននានាក្នុងខេត្តត្រាវិញ (ព្រះត្រពាំង) និងខេត្តឃ្លាំងក៏បានកកើតឡើងជាបន្តបន្ទាប់។

នៅខេត្តឃ្លាំង មានក្រុមល្ខោនរួមទាំងអស់ ៨ ក្រុម។ ក្រុមល្ខោនដំបូងបង្អស់ គឺក្រុមរបស់លោក លី គួន (Ly Cuon) បង្កើតលើកទីមួយនៅឆ្នាំ១៩២១ ក្រោយមកត្រូវរលាយក្រុមនៅឆ្នាំ១៩៤៤ ហើយបានបង្កើតឡើងវិញលើកទីពីរនៅឆ្នាំ១៩៤៨ ដោយស្នាដៃកូនស្រីរបស់លោក លី គួន (Ly Cuon) គឺអ្នកស្រី លី ធីសុភី (Ly Thi So Phi) ហើយរលាយក្រុមទៅវិញនៅឆ្នាំ១៩៧២ [៥]។

នៅខេត្តត្រាវិញ (ព្រះត្រពាំង) រួមមានក្រុមល្ខោនទាំងអស់ ១៣ ក្រុម។ ដំបូងគឺក្រុមរបស់លោក សឺន គីវ (Son Cuu) បន្ទាប់មកគឺក្រុមរបស់លោក ថាញ់ ហ្វា (Thach Hoa)។ ដោយតម្រូវការបើកទូលាយទីតាំងសកម្មភាពសំដែង ក្រុមល្ខោនទាំងពីរក៏បានបែងចែករំលែកជាក្រុមល្ខោនតូចៗជូនបងប្អូន កូនចៅគ្រប់គ្រងដើរសំដែងតាមភូមិស្រុកនានា។ ម្យ៉ាងទៀត ក៏មានការរួមបញ្ចូលក្រុមតូចៗឱ្យជាក្រុមធំដែរ សម្រាប់បង្កលក្ខណៈងាយស្រួលក្នុងការប្រមូលធនធានមនុស្សក៏ដូចជារួមវិភាគទានក្នុងការវិនិយោគធនធានសម្រាប់សកម្មភាពដើរសំដែងបម្រើតម្រូវការទស្សនារបស់ហាជនផង សម្រាប់ធ្វើសេដ្ឋកិច្ចផង។

ប្រភេទទម្រង់សិល្បៈនេះ មានការអភិវឌ្ឍរលូន គឺមកពីការចលនាមហាជន ទើបបានកកើតក្រុមល្ខោនជាច្រើន ហើយគេហៅថាក្រុមសិល្បៈមហាជន។ ទេពកោសល្យរបស់សិល្បករ សិល្បការិនីទាំងឡាយបានសិក្សារៀនសូត្រពីគ្នានឹងគ្នា សិក្សាបង្ហាត់បង្រៀនបន្តវេនគ្នា និងសិក្សាពីទម្រង់សិល្បៈផ្សេងៗ បានញ៉ាំងឱ្យទម្រង់សិល្បៈល្ខោនពីមួយថ្ងៃទៅមួយថ្ងៃកាន់តែមានការស្ទាត់ជំនាញ និងមានប្រជាប្រិយភាពជាង។ ជាក់ស្តែងនៅខេត្តត្រាវិញ (ព្រះត្រពាំង) មានលោក ថាច់ ដុង និងលោក ថាច់ ថាញ់ បានសិក្សារៀនសូត្រនូវក្បាច់រាំពីជនជាតិចិន ក្នុងអំឡុងទសវត្សរ៍ទី ៤០ ហើយក៏បានបង្ហាត់បន្តដល់សិល្បករ សិល្បការិនីនៃក្រុមសិល្បៈរស្មីប្រទីបខេត្តត្រាវិញ។ នៅខេត្តឃ្លាំងវិញ មានលោក ថាច់ វង្ស លោក ថាច់ ទីក្វាង អ្នកស្រី គឹម ធីសួង បានបង្ហាត់បង្រៀនដល់ សិល្បករ សិល្បការិនី នៃក្រុមសិល្បៈប្រចាំខេត្តឃ្លាំង ដើម្បីសំដែងរហូតមកដល់សព្វថ្ងៃ [៦]។

---

[៥] ក្រុមសិក្សាស្រាវជ្រាវអំពីសិល្បៈប្រជាប្រិយខ្មែរតំបន់វាលទំនាបទន្លេមេគង្គ របស់សាកលវិទ្យាល័យត្រាវិញ សម្ភាសន៍សិល្បៈករឆ្នើម ថាច់ ចឹន (អតិតប្រធានក្រុមសិល្បៈរស្មីប្រទីបខេត្តត្រាវិញ) ឆ្នាំ២០១៨។

[៦] ថាច់ សេដ្ឋ *ការកកើត និងអភិវឌ្ឍនៃក្រុមសិល្បៈរស្មីប្រទីបខេត្តត្រាវិញ* ការផ្សាយរបស់សមាគមអ្នកអក្សរសិល្ប៍វៀតណាម ឆ្នាំ២០១៩ ទំព័រទី១៣-២០។

ស្ថេរភាពនៃក្រុមល្ខោនទាំងអស់របស់មហាជនខ្មែរភាគខាងត្បូងនៃប្រទេសវៀតណាម ដែលឋិតថេរមានរយៈពេលយូរអង្វែងជាងគេ គឺក្រុមល្ខោននៅខេត្តត្រាវិញ និងក្រុមល្ខោននៅខេត្តឃ្លាំង។ ក្រុមល្ខោនរបស់លោក លី គួន (Ly Cuon) បង្កើតនៅខេត្តឃ្លាំង សកម្មភាពក្នុងរយៈពេល ៥៧ឆ្នាំ ចាប់តាំងពីឆ្នាំ១៩២១ ដល់ឆ្នាំ១៩៤៤ ហើយបង្កើតឡើងវិញពីឆ្នាំ១៩៤៨ ដល់ឆ្នាំ១៩៧២ រួចរលាយក្រុមរហូតមកដល់សព្វថ្ងៃ។ ក្រុមល្ខោនរបស់លោក សឺន គីវ (Son Cuu) បង្កើតនៅខេត្តត្រាវិញ សកម្មភាពក្នុងរយៈពេល ៤១ឆ្នាំ ចាប់ពីឆ្នាំ១៩៣៤ដល់ឆ្នាំ១៩៧៥ រួចរលាយក្រុមរហូតមកដល់សព្វថ្ងៃ។ បន្ទាប់ពីឆ្នាំ១៩៧៥ មានសិល្បករ សិល្បការិនីមួយចំនួន នៃក្រុមល្ខោនរបស់លោក សឺន គីវ (Son Cuu) បានរួមបញ្ចូលខ្លួនជាមួយក្រុមល្ខោនប្រចាំខេត្តឃ្លាំងរហូតមកដល់សព្វថ្ងៃ។ នៅខេត្តត្រាវិញ មានក្រុមល្ខោនមួយបានបង្កើតនៅឃុំ តាមង៉ាយ ស្រុកទីវកឹន គឺជាក្រុមល្ខោនបដិវត្តន៍មានសកម្មភាពសំដែងបម្រើមហាជនរហូតមកដល់ថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៦៣ បានប្ដូរឈ្មោះ មកជាក្រុមសិល្បៈរស្មីប្រទីប ហើយក្លាយជាក្រុមល្ខោនប្រចាំខេត្តត្រាវិញជាផ្លូវការចាប់តាំងពី ពេលនោះមក [៧]។

## ខ. ដំណាក់កាល ១៩៦១ មកដល់សព្វថ្ងៃ

ចាប់ពីឆ្នាំ១៩៦៣ ដល់ឆ្នាំ១៩៧៥ ទម្រង់សិល្បៈល្ខោនបានប្រែក្លាយខ្លួនពីសិល្បៈមហាជន មកជាសិល្បៈបដិវត្តន៍បម្រើបដិវត្តន៍ វណ្ណកម្មរឿង ដែលបានតែងនិពន្ធ រៀបរៀងយកមកសំដែងជាទម្លីករណ៍ប្រការនេះ។ ក្នុងដំណាក់កាលនេះរឿងល្ខោនដែលបានយកមកសំដែងគឺជារឿងទាក់ទងនឹងតថភាពសង្គមអាណានិគម ស្ញើចសរសើរមាតុភូមិ លើកកម្ពស់សាមគ្គីភាពជាតិ ស្ញើចសរសើរវីរបុរសជាតិ ។ល។ ដើម្បីបម្រើបដិវត្តន៍ប្រយុទ្ធប្រឆាំងនឹងរបបចក្រពត្តិនិយម។

ឆ្លងតាមរយៈការសិក្សាពីប្រវត្តិកបង្កើតក្រុមសិល្បៈរស្មីប្រទីប បានបញ្ជាក់ថា៖ រឿងល្ខោន ដែលជាប្រធានបទតថភាពសង្គមសម័យ មានផលប៉ះពាល់យ៉ាងធំក្នុងការចលនាប្រយុទ្ធប្រឆាំងនឹងរបបចក្រពត្តិអាមេរិក។ រឿងល្ខោនទាំងនោះបានឆ្លុះបញ្ចាំងអំពីការប្រយុទ្ធប្រឆាំងនឹងសត្រូវ ពោរពេញដោយភាពលំបាកលំបិនរបស់វិរបុរសជាតិនាសម័យនោះ។ ចាប់តាំងពីថ្ងៃរំដោះ ទី៣០ ខែមេសា ឆ្នាំ១៩៧៥ មក ក្រុមល្ខោនជំនាញទាំងឡាយទទួលបានការយកចិត្តទុកដាក់យ៉ាងខ្លាំងពីសំណាក់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់របស់រដ្ឋ ហើយរដ្ឋាភិបាលក៏បានបង់ថវិកាជាច្រើនសម្រាប់ការបណ្ដុះបណ្ដាល ជ្រើសរើសសិល្បករ សិល្បការិនីមានទេពកោសល្យដើម្បីរក្សានិងពង្រីកទម្រង់សិល្បៈនេះមកដល់សព្វថ្ងៃ។

ក្រៅពីក្រុមសិល្បៈរស្មីប្រទីបខេត្តត្រាវិញ បានទទួលស្គាល់ និងបានទទួលជាក្រុមសិល្បៈប្រចាំខេត្តរបស់រដ្ឋ នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៦៣ នៅមានក្រុមមួយចំនួនទៀត ក៏ត្រូវបានរដ្ឋាភិបាលទទួលស្គាល់ និងតែងតាំងជាក្រុមសិល្បៈប្រចាំខេត្តរបស់រដ្ឋជាបន្តបន្ទាប់

[៧] -ជ- ទំព័រទី១៣-២០។

ផងដែរ ដូចជា ក្រុមសិល្បៈខ្មែរខេត្តឃ្លាំង ក្រុមសិល្បៈខ្មែរខេត្តក្រមួនស (Kien Giang) ក្រុមសិល្បៈខ្មែរ ខេត្តទឹកខ្មៅ (Ca Mau) ក្រុមសិល្បៈខ្មែរខេត្តពលលាវ (Bac Lieu)។ ក្រោយពីថ្ងៃរំដោះ ទី៣០ មេសា ឆ្នាំ១៩៧៥ ក្រុមសិល្បៈទាំងនោះសុទ្ធសឹងបានរដ្ឋអំណាចភូមិភាគអនុញ្ញាតឱ្យបញ្ជូនសិល្បករ សិល្បការិនីមួយចំនួនមកសិក្សារៀនសូត្រពីក្រុមសិល្បៈរស្មីប្រទីបខេត្តត្រាវិញ ដើម្បីយកទៅបម្រើក្រុមខេត្តរបស់ខ្លួនតរៀងមក [៨]។

## ៣. សេចក្ដីសន្និដ្ឋាន

ដំណើរការកសាងទឹកដីរបស់ប្រជាជន នៃជនជាតិ ខ្មែរ កិញ និង ចិន នៅតំបន់វាលរាបទន្លេមេគង្គ បានធ្វើឱ្យទឹកដីនេះមួយថ្ងៃកាន់តែសម្បូរទៅដោយវប្បធម៌ចម្រុះ។ យើងមិនអាចបដិសេធដំណើរការរួមចំណែកដ៏ធំធេងរបស់បុព្វបុរសយើង ចំពោះបុព្វហេតុនៃការកសាង និងអភិវឌ្ឍជាតិរហូតមកពេលបច្ចុប្បន្ននោះទេ។ ល្ខោនបាសាក់បានកកើតឡើង និងវិវត្តន៍ជាដរាបវិវត្តន៍យ៉ាងខ្លាំងក្លានៅក្នុងសហគមន៍ខ្មែរកម្ពុជាក្រោម ទម្រង់សិល្បៈពៅពន្លកនេះ អាចចាត់ទុកថាជាអាហារសម្រាប់វិញ្ញាណដែលមិនអាចខ្វះបានក្នុងការបម្រើប្រជាជន និងបម្រើជាតិផង។

អក្សរសិល្ប៍ គឺជាការបំផុសគំនិតក្នុងការបង្កើតរឿងល្ខោនបាសាក់ អក្សរសិល្ប៍ និងល្ខោនបាសាក់តែងតែដើរទន្ទឹមគ្នា ពិបាកនឹងបំបែកចេញពីគ្នាបាន។ ល្ខោនបាសាក់នាំមកជូននូវតម្លៃវប្បធម៌ដ៏វិសេសវិសាលសម្រាប់ជាតិ គឺជាការសំយោគនូវភាពចម្រុះនៃអក្សរសិល្ប៍ កំណាព្យ តន្ត្រី របាំ គំនូរ សម្លៀកបំពាក់ជាដើម ដែលជាស្នាដៃដ៏មានតម្លៃខ្ពស់ ហើយបានក្លាយជាវិស័យវិទ្យាសាស្ត្រផងដែរ។

[៨] ថាច់ សេដ្ឋ *ការកកើត និងអភិវឌ្ឍនៃក្រុមសិល្បៈរស្មីប្រទីបខេត្តត្រាវិញ* ការផ្សាយរបស់សមាគមអ្នកអក្សរសិល្ប៍វៀតណាម ឆ្នាំ២០១៩ ទំព័រទី១៣-១៩។

# គន្ថនិទ្ទេស

## ភាសាខ្មែរ


១. នួន កន *ល្ខោនក្នុងជីវភាពខ្មែរ* ភ្នំពេញ ឆ្នាំ១៩៧៣។

២. ក្រុមសិក្សាស្រាវជ្រាវអំពីសិល្បៈប្រជាប្រិយខ្មែរតំបន់វាលរាបទន្លេមេគង្គ របស់សាកលវិទ្យាល័យត្រាវិញ ឆ្នាំ ២០១៨។

៣. គណៈកម្មការស្រាវជ្រាវសិល្បៈវប្បធម៌ *ទស្សនីភាពខ្មែរ* ភ្នំពេញ ឆ្នាំ២០០៣។

៤. លី ធេមតេង *ការស្រាវជ្រាវល្ខោនខ្មែរ* ការផ្សាយរបស់កម្ពុជសុរិយា ភ្នំពេញ។

៥. ជួន ណាត *វចនានុក្រមខ្មែរ ភាគ១-២* បោះពុម្ព ឆ្នាំ១៩៦៧។

៦. សៀវភៅ រ៉េ យ៉ំ *ខ្មែរប្រឈមមុខនឹងវប្បធម៌* ភ្នំពេញ ឆ្នាំ២០០១។

៧. ពេជ្រ ទុំក្រវិល *យីកេ និងល្ខោនបាសក់* ភ្នំពេញ ឆ្នាំ១៩៩៧។

៨. ពេជ្រ ទុំក្រវិល *ទស្សនីយភាពសិល្បៈខ្មែរ* ភ្នំពេញ ឆ្នាំ២០០៣។

៩. សារព័ត៌មាន នគរធំ ឆ្នាំទី២៣ លេខ១៨៨៤ ចេញផ្សាយថ្ងៃអាទិត្យ-ច័ន្ទ ទី១១-១២ ខែវិច្ឆិកា ឆ្នាំ២០១៨។

១០. ថាច់ សេដ្ឋ *ការកកើត និងអភិវឌ្ឍនៃក្រុមសិល្បៈរស្មីប្រទីបខេត្តត្រាវិញ* ការផ្សាយរបស់សមាគមអ្នកអក្សរសិល្ប៍វៀតណាម ឆ្នាំ២០១៩

១១. អេង សុត *មហាបុរសខ្មែរ ភាគទី១-២* បោះពុម្ពឡើងវិញ ឆ្នាំ២០០០។


## ភាសាវៀតណាម


១២. Huỳnh Thanh Ân (chịu trách nhiệm xuất bản), Ngô Khị, Châu Ôn, Lý Sên, (1996), *Kabuôn Kamnap*, Sở Văn hóa và Thông tin tỉnh Sóc Trăng.

១៣. Nguyễn Trọng Báu, Thạch Xuân Mai, (2009), *Truyện Cổ Khơ Me*, NXB Giáo dục Việt Nam.

១៤. Mai Mỹ Duyên, (2014), *Đôi điều về nghệ thuật sân khấu Dù kê*, Nghệ thuật sân khấu Dù kê Khmer Nam Bộ Di sản văn hóa dân tộc, Tạp chí khoa học, Trường Đại học Trà Vinh (số 13) tr. 64 - 67.

១៥. Đoàn nghệ thuật Khmer Ánh Bình Minh, (2014), *Quá trình hình thành và hoạt động biểu diễn nghệ thuật sân khấu Dù kê tỉnh Trà Vinh*, Nghệ thuật sân khấu Dù kê Khmer Nam Bộ Di sản văn hóa dân tộc, Tạp chí Khoa học, Trường Đại học Trà Vinh (số 13) tr. 176 - 181.

១៦. Sơn Phước Hoan, Sơn Ngọc Sang, (1995), *Truyện kể Khmer*, NXB Giáo dục.

១៧. Phạm Tiết Khánh, (2014), *Nghệ thuật Sân khấu Dù kê Khmer Nam Bộ-Vấn đề và suy nghĩ*, Nghệ thuật sân khấu Dù kê Khmer Nam Bộ Di sản văn hóa dân tộc, Tạp chí Khoa học, Trường Đại học Trà Vinh (số 13) tr.5-10.

១៨. Thạch Chane Vitu, (2015), *Kịch bản Sân khấu Dù kê từ Văn học dân gian,* Luận văn Thạc sĩ Văn hóa học, Trường Đại học Trà Vinh.

១៩. Huỳnh Ngọc Trảng, (1983), *Truyện cổ KhơMe Nam Bộ*, NXB Văn hóa, Hà Nội.

២០. Kịch bản Sân khấu Dù kê Đoàn Nghệ thuật Khmer Ánh Bình Minh tỉnh Trà Vinh.

២១. Nhiều tác giả, (1998), ***Về sân khấu truyền thống Khmer Nam Bộ,*** NXB Phân Viện Văn hóa Nghệ thuật Việt Nam tại Tp Hồ Chí Minh và Sở Văn hóa Thông tin tỉnh Sóc Trăng tr. 31

២២. Nhiều tác giả, (1988), ***Tìm hiểu vốn văn hóa dân tộc Khmer Nam Bộ***, NXB Viện Văn hóa Tp Hồ Chí Minh và tỉnh Hậu Giang tr. 290-292.

https://www.khsearch.com/qna/4397(9:40, 14/8/2021)

# ការវិភាគពីគោលការណ៍អាស្រ័យផ្នត់

បេក្ខជនបណ្ឌិត **ផល សូភឿន** ជំនាញ **ភាសាវិទ្យា** ជំនាន់ទី៥ វគ្គ១

## ១- សេចក្ដីផ្ដើម

គោលការណ៍អាស្រ័យផ្នត់[១]មានលក្ខណៈតាមបែបបរន្តនិយម។ គោលការណ៍នេះត្រូវបានបង្កើតឡើងនៅដើមសត្សទីម្ភៃមួយ ដោយភាសាវិទូ ច័ន្ទ សំណព្វ ហើយជាផ្នែកមួយនៃវេយ្យាករណ៍បរន្តនិយម[២]។ វិធាននៃវេយ្យាករណ៍នេះ ផ្ដោតទៅលើការកំណត់សំណេរនៃពាក្យកម្លាយដែលមានលក្ខណៈជាសត្យានុម័ត ប្រកបដោយសុក្រឹតភាពនិងសកលភាព។ ការសរសេរពាក្យកម្លាយតាមគោលការណ៍អាស្រ័យផ្នត់មានលក្ខណៈជាប្រព័ន្ធ ពោលគឺពាក្យកម្លាយតាមផ្នត់នីមួយៗមានសំណេរដូចវិធានដែលបានចែងទាំងអស់ ហើយគ្មានករណីផ្ទុយឬខុសពីវិធាននោះឡើយ។[៣]

សម្មតិកម្មដែលចែងថាផ្នត់ជាកត្តាកំណត់សំណេរពាក្យកម្លាយមានខ្លឹមសារយ៉ាងណា ហើយមានវិសាលភាពអនុវត្តកម្រិតណាខ្លះនោះ វាជាលទ្ធផលនៃការសិក្សាទៅលើមូលហេតុនិងដើមចមនៃការសរសេរពាក្យកម្លាយក្នុងភាសាខ្មែរក្នុងក្របខ័ណ្ឌសំរាយតំរួត។

## ២- សំណេរពាក្យកម្លាយអាស្រ័យលើផ្នត់

នៅក្នុងកថាខណ្ឌជាបន្តបន្ទាប់នេះ យើងនឹងបង្ហាញពីសំណេរនៃពាក្យកម្លាយក្នុងក្របខ័ណ្ឌនៃគោលការណ៍អាស្រ័យផ្នត់នេះ ក្នុងគោលបំណងសិក្សាស្វែងយល់ដើម្បីបានឈ្វេងយល់ពីសុក្រឹតភាពនិងសកលភាពនៃគោលការណ៍នេះ។

### ២.១- សំណេរពាក្យកម្លាយដោយផ្នត់ដើមទម្រង់(ព-)[៤]

តាមការសិក្សាស្រាវជ្រាវបានឱ្យដឹងថា *ក្បាំង ច្បិច ត្បូង ប្ដឹង ស្កាត់* ជាពាក្យកម្លាយចេញពីឫស *បាំង បិច បូង ដឹង កាត់* ដែលសុទ្ធតែមានសំណេរជាព្យាង្គរាយ បែរជាមានសំណេរជាព្យាង្គតំរួតទៅវិញដែលស្របទៅនឹងវិធាននៃគោលការណ៍អាស្រ័យផ្នត់ដែលបានចែងមក។

---

[១] ច័ន្ទ សំណព្វ ***សំណេរនិងអក្ខរាវិរុទ្ធខ្មែរ*** រាជបណ្ឌិត្យសភាកម្ពុជា ២០១២ ទំ១១៥។

[២] ចាប់តាំងពីការបង្កើតឡើងនៅដើមសតវត្សទីម្ភៃមួយរហូតដល់ឆ្នាំ២០២០ ទ្រឹស្ដីនេះមានឈ្មោះថាទ្រឹស្ដីអន្តរកម្មនិយម។

[៣] រហូតមកដល់ពេលនេះ យើងរកមិនទាន់ឃើញមានឧទាហរណ៍ណាមួយដែលអាចប្រើជាបដិសម្មតិកម្មទល់នឹងគោលការណ៍អាស្រ័យផ្នត់នៅឡើយទេ។

[៤] *ព* ជាអក្សរកាត់នៃពាក្យ *ព្យញ្ជនៈ* ឯគំនូសមួយ ជាសញ្ញាបញ្ជាក់ថាមានពាក្យឫសដែលត្រូវយកមកភ្ជាប់។ *ព* នេះមិនមែនជាផ្នត់ទេ ហើយវាក៏គ្មានតួនាទីក្នុងការកម្លាយពាក្យពាក្យឫសនោះទេ។ តាមពិតទៅ *ព* នេះជាអក្សរកាត់នៃពាក្យ *ព្យញ្ជនៈ* ដែលបញ្ជាក់ថាផ្នត់មានធាតុតែមួយគត់គឺព្យញ្ជនៈ ហើយព្យញ្ជនៈនេះអាចជា *ក ច ត ប ស* តែមិនមែន *ព* ទេ។

សំណេរជាព្យាង្គតំរួតនៃពាក្យកម្លាយដោយផ្នត់ដើមទាំងអស់ដែលមានទម្រង់(ព-) គឺកើតឡើងដោយសារតែផ្នត់ជាព្យញ្ជនៈ ហើយឫសសុទ្ធតែជាពាក្យដែលផ្ដើមឡើងដោយព្យញ្ជនៈ លុះនៅពេលប្រកបផ្នត់នឹងឫសដោយតម្រូវឱ្យផ្នត់ជាធាតុនៅខាងដើមទៀតនោះ ហេតុនេះ វានាំឱ្យមានការប្រកបចូលគ្នារវាងព្យញ្ជនៈនៃផ្នត់ដើមនិងព្យញ្ជនៈដើមព្យាង្គនៃពាក្យឫស។ ការប្រកបចូលគ្នានៃព្យញ្ជនៈទាំងនេះហើយដែលតម្រូវឱ្យមានការសរសេរត្រួតព្យញ្ជនៈទីមួយលើព្យញ្ជនៈទីពីរដែលតាមវេយ្យាករណ៍ថា មានការប្ដូរទៅជាជើង។

## ២.២- សំណេរពាក្យកម្លាយដោយផ្នត់ដើមទម្រង់(ពស-)[៥]

តាមគោលការណ៍អាស្រ័យផ្នត់ ផ្នត់ដើមទាំងអស់ដែលមានទម្រង់ទម្រង់(ពស-)កម្លាយពាក្យឫសដែលមានសំណេរជាព្យាងរាយឬជាព្យាង្គតំរួត ឱ្យបានទៅជាពាក្យកម្លាយដែលមានពីរព្យាង្គនិងមានសំណេរជារាយព្យាង្គទាំងអស់ ដោយគ្មានករណីលើកលែង។

ឧទាហរណ៍ *ស្រាក់* ជាពាក្យដែលមានសំណេរជាព្យាង្គតំរួត តែនៅពេលកម្លាយដោយផ្នត់ដើម[ស-]ដែលមានទម្រង់(ពស-) គេបានពាក្យកម្លាយ *សស្រាក់* ដែលមានសំណេរជារាយព្យាង្គ។ ដូចគ្នាដែរ *គ្រឹក គ្រេង* ក៏មានសំណេរជាព្យាង្គតំរួតដែរ តែពាក្យកម្លាយចេញពីពាក្យទាំងនេះតាមរយៈផ្នត់ដើម[គ-]ដែលមានទម្រង់(ពស-)ដែរនោះ គឺមានសំណេរជារាយព្យាង្គ *គគ្រឹក គគ្រេង*។

## ២.៣- សំណេរពាក្យកម្លាយដោយផ្នត់ដើមទម្រង់(ពសព-)

តាមគោលការណ៍អាស្រ័យផ្នត់ជាផ្នែកមួយនៃវេយ្យាករណ៍បរន្តេនិយម ជាទូទៅពាក្យកម្លាយតាមរយៈផ្នត់ដើមទាំងអស់ដែលមានទម្រង់(ពសព-) សុទ្ធតែជាពាក្យដែលសរសេរជាតំរួតព្យាង្គ[៦]។ ឧទាហរណ៍ ពាក្យតំរួតព្យាង្គ*សង្កត់ កញ្ចាស់ បង្គ្រប់ បញ្ច្រាស* ជាពាក្យកម្លាយរៀងគ្នាចេញពីពាក្យឫស *កត់ ចាស់ គ្រប់ ប្រាស*។ គួរកត់សំគាល់ថាពាក្យកម្លាយតាមរយៈផ្នត់ដើមទម្រង់(ពសព-) ដែលមានសូរ**អេ'ម**អាចមានសំណេរពីរយ៉ាងផ្សេងគ្នា ពោលគឺអាចសរសេរជារាយព្យាង្គក្នុងករណីដែលគេកត់សូរ**អេ'ម**នៃផ្នត់ដោយស្រៈ**អំ** ហើយមានសំណេរជាតំរួតព្យាង្គក្នុងករណីដែលគេកត់សូរអេ'មនៃផ្នត់ដោយការប្រកបសូររវាង

[៥] សូមរំលឹកដោយទទូចថា(សព-)គ្រាន់តែស្លាកបែបវេយ្យាករណ៍ដែលគេសន្មតកំណត់ឡើងដើម្បីតាងជាទូទៅឱ្យធាតុដែលមានក្នុងផ្នត់។ វាមិនមែនជាផ្នត់ទេ ហើយវាគ្មានតួនាទីក្នុងការកម្លាយពាក្យឫសឬកំណត់ពីសំណេរនៃពាក្យកម្លាយនោះដែរ។ យើងរំលឹកដោយទទូចបែបនេះពីព្រោះមានអ្នកយល់ច្រលំបែបនេះ ដូចមានការលើកបង្ហាញជូននៅក្នុងទស្សនៈចំណាកគោលស្រាប់។

[៦] ច័ន្ទ សំណព្វ ***សំណេរនិងអក្ខរាវិរុទ្ធខ្មែរ*** រាជបណ្ឌិត្យសភាកម្ពុជា ២០១២ ទំ១១៨។

ស្រៈកប់គួអំនិងព្យញ្ជនៈ*ម*។ ដោយសារតែផ្នត់ដើមដែលមានទម្រង់(ពសព-)នេះបានរំលេចនូវបាតុភូតពីរផ្សេងគ្នា។ បាតុភូតទាំងពីរនោះគឺៈ

*ទីមួយ* ជាទូទៅ ផ្នត់ដើមដែលមានទម្រង់(ពសព-)បានកម្លាយពាក្យឫសឱ្យកើតបានជាពាក្យកម្លាយមានសំណេរជាតំរួតព្យាង្គ ទោះបីពាក្យឫសមានសំណេរព្យាង្គរាយឬព្យាង្គតំរួតក៏ដោយ។ ជាក់ស្តែង *វៀច ចូល* សំណេរជាព្យាង្គរាយបានកម្លាយរៀងគ្នាដោយផ្នត់ដើម[ក'ង-] [ប'ញ-] មានទម្រង់(ពសព-) បានទៅជាពាក្យកម្លាយ *កង្វៀច បញ្ចូល* សុទ្ធតែសរសេរជាតំរួតព្យាង្គទាំងអស់។

*ទីពីរ* ចំពោះពាក្យឫសមានសំណេរជាព្យាង្គតំរួត ពាក្យកម្លាយខ្លះសរសេរជាតំរួតព្យាង្គ ដូចក្នុងករណីនៃពាក្យ *បង្គ្រប់ បញ្ច្រាស បញ្ច្រាប កញ្ច្រោល* ។ល។ តែខ្លះទៀតបែរជាសរសេរជារាយព្យាង្គទៅវិញ ដូចជា *បង់ក្លាយ បំភ្លឺ បំផ្លោង* ជាដើម។ ពាក្យទាំងនេះមិនធ្លាប់ត្រូវបានសរសេរជាផ្លូវការឬកត់ត្រាចារទុកដោយមានសំណេរ *បង្ក្លាយ បម្ភ្លឺ បម្ផ្លោង* បែបនេះទាល់តែសោះ។

ពាក្យកម្លាយដែលសរសេរជារាយព្យាង្គបែបនេះ ជាទូទៅគឺជាពាក្យដែលបានកម្លាយចេញពីពាក្យឫសដែលមានសំណេរជាព្យាង្គតំរួត ហើយត្រូវបានកម្លាយតាមរយៈផ្នត់ដើម [ប'ម-] និងផ្នត់ដើម[ប'ង-] ដែលមានតែមួយករណីគត់គឺពាក្យ *បង់ក្លាយ* ។

**២.៤- សំណេរពាក្យកម្លាយដោយផ្នត់ដើមទម្រង់(ពពស-)**

ក្នុងករណីកម្លាយដោយផ្នត់ដើមទម្រង់(ពពស-) ជាទូទៅ ពាក្យឫសមានតែមួយព្យាង្គ តែពាក្យកម្លាយដែលបានមកសុទ្ធតែជាពាក្យពីរព្យាង្គ ដោយព្យាង្គទីមួយបានមកពីផ្នត់ដើម ហើយព្យាង្គទីពីរបានមកពីពាក្យឫស។ ទោះបីឫសមានសំណេរបែបណាក៏ដោយ ក៏ពាក្យកម្លាយដែលបានមកមានសំណេរជារាយព្យាង្គទាំងអស់ ដូចមាន *ចចឹក ជដែក សសៀរ បបោស គគ្រឹកគគ្រេង សស្រាក់សស្រាំ ប៉ប្លឹបប៉ប្លែត ចប្រែត ចប្រេសចប្រាស* ជាឧទាហរណ៍ស្រាប់។ យើងអាចទាញនូវសេចក្តីសង្ខេបនិងការសន្និដ្ឋានដូចខាងក្រោមៈ

ក- ផ្នត់ដើមទាំងអស់មានបួនទម្រង់គឺទម្រង់(ព-) ទម្រង់(ពស-) ទម្រង់(ពសព-) និងទម្រង់(ពពស-) ដែលក្នុងការកម្លាយពាក្យឫស បានកាន់កាប់ទីតាំងខាងដើមនៃពាក្យកម្លាយ។

ខ- ផ្នត់ដើមទាំងអស់ដែលមានទម្រង់(ព-) កម្លាយពាក្យឫសដែលជាទូទៅ សុទ្ធតែមានសំណេរជាព្យាង្គរាយ ឱ្យកើតបានទៅជាពាក្យកម្លាយដែលសរសេរជាព្យាង្គតំរួតទាំងអស់។

គ- ផ្នត់ដើមទាំងអស់ដែលមានទម្រង់(ពស-) កម្លាយពាក្យឫសដែលជាទូទៅមានសំណេរជាព្យាង្គរាយឬជាព្យាង្គតំរួត ឱ្យកើតបានទៅជាពាក្យកម្លាយដែលសរសេរជារាយព្យាង្គទាំងអស់។

ឃ- ផ្នត់ដើមទាំងអស់ដែលមានទម្រង់(ពសព-) កម្លាយពាក្យឫសដែលជាទូទៅមានសំណេរជាព្យាង្គរាយឬជាព្យាង្គតំរួតឱ្យកើតបានទៅជាពាក្យកម្លាយដែលសរសេរជាតំរួតទាំងអស់ លើកលែងតែករណីនៃផ្នត់មានសូរអៈម ដែលពាក្យកម្លាយអាចសរសេរបានទាំងតំរួតព្យាង្គទាំងរាយព្យាង្គ។

ង- ផ្នត់ដើមទាំងអស់ដែលមានទម្រង់(ពពស-)កម្លាយពាក្យពាក្យឫសដែលជាទូទៅមានសំណេរជាព្យាង្គរាយ ឱ្យកើតបានទៅជាពាក្យកម្លាយដែលសរសេរជារាយព្យាង្គទាំងអស់។

ជារួម យើងអាចសន្និដ្ឋានបានថាផ្នត់ដើមក្នុងទម្រង់នីមួយៗមានមុខងារកម្លាយពាក្យឫសឱ្យកើតបានទៅជាពាក្យថ្មីដែលមានប្រភេទពាក្យដូចឬខុសពីប្រភេទពាក្យឫស ហើយន័យនៃពាក្យកម្លាយក៏ខុសពីន័យនៃពាក្យឫសដែរ។

ជាបន្តទៅទៀតនេះ យើងសូមចាប់ផ្តើមការសិក្សាពីពាក្យកម្លាយតាមរយៈផ្នត់ដែកដោយចែកទៅតាមករណីនៃទម្រង់នីមួយៗដូចតទៅនេះ។

## ២.៥- សំណេរពាក្យកម្លាយដោយផ្នត់ដែកទម្រង់(-ព-)

ផ្នត់ដែកដែលមានទម្រង់(-ព-)មានជាតុតែមួយទេ គឺព្យញ្ជនៈដោយមិនមានស្រៈឬព្យញ្ជនៈណាផ្សេងទៀតនោះឡើយ។ នៅក្នុងការកម្លាយពាក្យ ផ្នត់ដែលមានទម្រង់(-ព-)នេះ ត្រូវប្រកបជាមួយព្យញ្ជនៈដើមព្យាង្គនៃពាក្យឫសសិន មុននឹងទៅប្រកបសូរជាមួយនឹងស្រៈនៃពាក្យឫសនោះ។ លក្ខណៈបែបនេះដូចគ្នាទៅនឹងអ្វីដែលមានចែងជានិយមន័យនៃព្យាង្គតំរួតក្នុងវេយ្យាករណ៍បរន្តេនិយមដែរ។

ជាក់ស្តែង ការកម្លាយឫសដែលមានសំណេរជាព្យាង្គរាយ *កាច់ លេង* ដោយផ្នត់ដែក[-ប-]ដែលមានទម្រង់(-ព-) បង្កើតបានទៅជាពាក្យកម្លាយ *ក្បាច់ ល្បែង* ដែលមានសំណេរជាព្យាង្គតំរួត។

គួរកត់សំគាល់ថា ចំពោះពាក្យកម្លាយ *ខ្មាន់*[៧] គឺមានការញែកព្យញ្ជនៈ *ក* ដែលក្លាយទៅជា *ខ* ចេញពីស្រៈអានិង *ន* បន្តក់ ដោយព្យញ្ជនៈ *ម* នៃផ្នត់ ដែលបានក្លាយទៅជាជើង *ម*។ បើយើងសរសេរជា *ខ(ក) + ម + ា + ន + ់* បែបនេះវិញនោះ យើងឃើញពីការញែកជាតុនៃពាក្យឫសដោយផ្នត់ដែក *ម* នេះយ៉ាងច្បាស់។ ការប្តូរពី *ក* ទៅ *ខ* បែបនេះគឺដើម្បីសម្រួលការប្រកបសូររវាងព្យាញ្ជនៈនិងព្យញ្ជនៈនៅក្នុងការបង្កើតព្យាង្គ។[៨] ការបើកខ្យល់ព្យញ្ជនៈបែបនេះក៏ឃើញមានចំពោះពាក្យ *ឆ្នាំ ឈ្នួញ ឆ្នុក ឈ្មាន់* ជាពាក្យកម្លាយចេញពីឫស *ចាំ ជួញ ចុក ជាន់* ដោយផ្នត់ដែក[-ម-]និងផ្នត់ដែក[-ន-]។

---

[៧] វង្ស មេង ***អន្តេបទ /-ម-/ និង /-ន-/ នៅក្នុងភាសាខ្មែរ*** និក្ខេបបទបណ្ឌិតភាសាវិទ្យា រាជបណ្ឌិត្យសភាកម្ពុជា ២០១១ ទំ៣២-៣៧។

[៨] ដោយយោងលើបរន្តេកម្មរវាងព្យញ្ជនៈ *ក* និង *ម*។ ការបើកបិទខ្យល់ព្យញ្ជនៈនេះជាទស្សនៈដើមរបស់ភាសាវិទូ ច័ន្ទ សំណព្វ ហើយត្រូវបានយកទៅអនុវត្តក្នុងនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ភាសាវិទ្យារបស់លោក យៀង វីរបុត្រ។

## ២.៦- សំណេរពាក្យកម្លាយដោយផ្នត់ដែកទម្រង់(-សព-)

ផ្នត់ដែកទាំងអស់ដែលទម្រង់(-សព-)កម្លាយឫសឱ្យកើតបានទៅជាពាក្យកម្លាយ ដែលមានសំណេរជាតំរួតព្យាង្គ។ ឧទាហរណ៍ ផ្នត់ដែក[-អ'ង-] កម្លាយឫស ខ្វះ ធ្វើ ស្អាត ឱ្យបានទៅជាពាក្យ *កង្វះ ទង្វើ សម្អាត* ដែលមានសំណេរជាតំរួតព្យាង្គយ៉ាងពិតប្រាកដ។

យើងបានសង្កេតឃើញផងដែរថា បើតាមវេយ្យាករណ៍បរន្តេនិយម មានពាក្យជាច្រើនដែលត្រូវបានកម្លាយដោយផ្នត់ដែក[-អ'ម-] បង្កើតបានទៅជាពាក្យកម្លាយដែលមានសំណេរជារាយព្យាង្គ។ ពាក្យទាំងនោះមានដូចជា *កំហុស ជំហាន ទំហំ* ជាដើម ដែលតាមធម្មតា មិនត្រូវបានសរសេរជាតំរួតព្យាង្គទាល់តែសោះ។ ជាក់ស្តែង យើងមិនដែលឃើញគេសរសេរពាក្យកម្លាយទាំងនេះជា *កម្ហុស ជម្ហាន ទម្ហំ* បែបនេះទេ ទោះបីជាតាមសម្ព័ន្ធនៃភាសាខ្មែរ ការសរសេរបែបនេះមិនមានឧបសគ្គមករារាំងក៏ដោយ។

ប្រការនេះបណ្តាលមកពីផ្នត់ដែកមានទម្រង់នេះបានចូលញែកយកព្យញ្ជនៈមួយនៃសំណុំព្យញ្ជនៈដើមព្យាង្គនៃពាក្យឫសយកមកប្រកបជាមួយខ្លួនរួចបង្កើតបានជាព្យាង្គបិទដោយព្យញ្ជនៈនៃផ្នត់។ លក្ខណៈបិទនៃព្យាង្គដែលបង្កើតបានជាព្យាង្គទីមួយនៃពាក្យកម្លាយនេះ ហើយផ្តល់លទ្ធភាពក្នុងការសរសេរតំរួតព្យាង្គ។[៩] ប៉ុន្តែ ក្នុងករណីដែលគេកត់សូរអេ'មនៃផ្នត់ដោយស្រៈអំ ពាក្យកម្លាយដែលបានមកសុទ្ធតែមានសំណេរជារាយព្យាង្គទៅវិញ ស្របតាមគោលការណ៍អាស្រ័យផ្នត់ដែលបានចែងមក។

## ២.៧- សំណេរពាក្យកម្លាយដោយផ្នត់ដែកទម្រង់(-ស/ព-)

តាមវេយ្យាករណ៍ប្រពៃណី ផ្នត់ដែកដែលមានទម្រង់(-ស/ព-)មិនមានច្រើនទេ ពោលគឺមានតែផ្នត់ដែក[-អ/ប-]និងផ្នត់ដែក[-អ៊/ន-] ប៉ុណ្ណោះ។ ដោយឡែក ក្នុងក្របខណ្ឌនៃវេយ្យាករណ៍បរន្តេនិយម ផ្នត់ដែក[-អ៊/ន-]ត្រូវបានជំនួសដោយផ្នត់ដែក[-អ/ន-]វិញ ដោយហេតុថាស្ថាបនិកនៃវេយ្យាករណ៍នេះបានវិភាគឃើញថាក្នុងបរបទនៃមូលភេទអអ៊ ភាសាខ្មែរមិនមានស្រៈពួកអ៊នោះទេ។

ពាក្យកម្លាយតាមរយៈផ្នត់ដែក[-អ/ន-] មានជាអាទិ៍ដូចខាងក្រោម៖

**[-អ/ន-]+រូត→រនូត**

**+រោច→រនោច**

---

[៩] សូមអានសេចក្តីពិស្តារស្តីពីសំណេរព្យាង្គតាមបែបបរន្តេកម្មនេះក្នុង *ទ្រឹស្តីច័ន្ទ សំណព្វ* ឬ *ទ្រឹស្តីបរន្តេនិយម* (២០២២)។

ចំពោះផ្នត់ដែក[-អ/ន-]ក៏ដូចផ្នត់ដែក[-អ/ប-]សុទ្ធតែមានទម្រង់(-ស/ព-)ដូចគ្នា ហើយត្រូវបានប្រើដើម្បីកម្លាយពាក្យឫសដែលមានសំណេរជាពាក្យមួយព្យាង្គនិងជាព្យាង្គរាយ។ ប៉ុន្តែពាក្យកម្លាយដែលបានពីការកម្លាយតាមរយៈផ្នត់នេះគឺសុទ្ធតែមានសំណេរជារាយព្យាង្គទាំងអស់។

## ២.៨- សំណេរពាក្យកម្លាយដោយផ្នត់ដែកទម្រង់(-សព/ព-)

ដោយផ្អែកលើវេយ្យាករណ៍នានា ជាអាទិ៍ វេយ្យាករណ៍ប្រពៃណី ផ្នត់ដែលមានទម្រង់(-សព/ព-) មានពីរគឺផ្នត់ដែកផ្នត់ដែក[-អ'ម/ណ-]និងផ្នត់ដែក[-អ៊'ម/ន-]។ ប៉ុន្តែបើតាមវេយ្យាករណ៍បរន្តេនិយម ផ្នត់ដែកដែលមានទម្រង់(-សព/ព-)មានតែមួយទេគឺ[-អ'ម/ណ-]ឬ[-អ'ម/ន-]ដោយសារតែព្យញ្ជនៈ *ណ*និង*ន* គ្រាន់តែជាគូព្យញ្ជនៈនៃមូលភេទអអ៊ីតែប៉ុណ្ណោះ ហើយអ៊ីនៃផ្នត់[-អ៊'ម/ន-] ដែលមាននៅក្នុងវេយ្យាករណ៍ប្រពៃណីនោះគឺមិនមានអត្ថិភាពជានៅក្នុងផ្នត់ទេ តែវាមាននៅក្នុងពាក្យកម្លាយក្រោយពីមានការទាញសូរដោយព្យញ្ជនៈដើមព្យាង្គនៃពាក្យឫសដែលជាពួកអ៊ីនោះទៅវិញទេ។ ម្យ៉ាងទៀត ព្យញ្ជនៈ *ណ ន* គឺត្រូវបានប្រើដើម្បីតម្រូវសូរអាននៃពាក្យកម្លាយដែល ជាទូទៅអនុលោមតាមសូរព្យញ្ជនៈដើមព្យាង្គនៃពាក្យឫសផង និងដើម្បីចៀសពីសំណេរពាក្យកម្លាយតាមបែបទំនាញសូរផង។

វេយ្យាករណ៍បរន្តេនិយមបានថែងថា ការកម្លាយពាក្យឫសតាមរយៈផ្នត់ដែកទម្រង់(-សព/ព-) ត្រូវអនុវត្តតាមវិធានដូចខាងក្រោម៖

ករណីពាក្យឫសមានព្យញ្ជនៈដើមព្យាង្គជាពួកអ ការកម្លាយពាក្យត្រូវប្រើផ្នត់ដែក[-អ'ម/ណ-]។ ផ្ទុយទៅវិញ ក្នុងករណីដែលពាក្យឫសមានព្យញ្ជនៈដើមព្យាង្គជាព្យញ្ជនៈពួកអ៊ី វេយ្យាករណ៍បរន្តេនិយមតម្រូវឱ្យប្រើផ្នត់ដែក[-អ'ម/ន-]ដើម្បីកម្លាយពាក្យពាក្យឫសនោះ។ ក្នុងក្របខ័ណ្ឌនេះ ពាក្យកម្លាយដែលបានមកមិនត្រូវបានសរសេរតាមបែបទំនាញសូរនោះទេ។ ពាក្យឫស *គិត ទាញ ជួស* មានព្យញ្ជនៈដើមព្យាង្គរៀងគ្នាគឺ *គ ទ ជ* ដែលសុទ្ធតែជាព្យញ្ជនៈពួកអ៊ីត្រូវតែកម្លាយតាមរយៈផ្នត់ដែក[-អ'ម/ន-] ដើម្បីឱ្យពាក្យកម្លាយបានមកមានសំណេរជា *គំនិត ទំនាញ ជំនួស* សំណេរទាំងនេះមិនត្រឹមតែមានសូរត្រូវទៅតាមអំណានសូរនៃពាក្យប៉ុណ្ណោះទេ តែថែមទាំងបានចៀសផុតពីការប្រទំនាញសូរទៀតផង។

# ៣- សន្និដ្ឋានលើសំណេរនៃពាក្យកម្លាយតាមគោលការណ៍អាស្រ័យផ្នត់

ក្រោយពីបានសិក្សាពីពាក្យកម្លាយតាមគោលការណ៍អាស្រ័យផ្នត់រួចមក យើងអាចទាញចេញនូវសេចក្តីសន្និដ្ឋានជាសកលមួយដូចតទៅ៖

*ទីមួយ* ពាក្យឫសក្នុងភាសាខ្មែរដែលត្រូវយកមកកម្លាយតាមរយៈផ្នត់ដើមនិងផ្នត់ដែក ជាទូទៅជាពាក្យមួយព្យាង្គ[១០] ហើយមានសំណេរជាព្យាង្គរាយឬជាព្យាង្គតំរួត។

*ទីពីរ* ក្នុងករណីពាក្យឫសមានសំណេរជាព្យាង្គរាយ ពាក្យកម្លាយដែលបានមកជាច់ខាតមិនមែនជាព្យាង្គរាយទេ គឺមានសំណេរជាព្យាង្គតំរួត តំរួតព្យាង្គ ឬរាយព្យាង្គ។ ជាទូទៅពាក្យឫសមានសំណេរជាព្យាង្គរាយត្រូវបានកម្លាយតាមរយៈផ្នត់ដើមដែលមានទម្រង់(ព-) (ពស-) (ពសព-) (ពពស-)និងតាមរយៈផ្នត់ដែកដែលមានទម្រង់(-ព-)(-សព-)[១១](-សព/ព-) និង(-ស/ព-)។

*ទីបី* ក្នុងករណីពាក្យឫសមានសំណេរជាព្យាង្គតំរួត ក្រោយពីកម្លាយតាមរយៈផ្នត់អ្វីក៏ដោយ មានទម្រង់អ្វីក៏ដោយ ក៏ពាក្យកម្លាយដែលបានមកមិនមានសំណេរជាព្យាង្គតំរួតដូចពាក្យឫសជាដាច់ខាត។ អនុលោមតាមផ្នត់ដែលមានទម្រង់ផ្សេងៗ ពាក្យកម្លាយអាចមានសំណេរជាតំរួតព្យាង្គឬជារាយព្យាង្គដែលខុសពីសំណេរនៃពាក្យឫស។

*ទីបួន* ពាក្យកម្លាយក្នុងភាសាខ្មែរមិនមានសំណេរជាព្យាង្គរាយទេ តែអាចមានសំណេរជាព្យាង្គតំរួត តំរួតព្យាង្គ ឬរាយព្យាង្គ។

*ទីប្រាំ* ពាក្យកម្លាយដែលមានសំណេរជាព្យាង្គតំរួតមិនមែនត្រូវបានកម្លាយចេញពីពាក្យឫសដែលមានសំណេរជាព្យាង្គតំរួតនោះទេ។

*ទីប្រាំមួយ* ជាទូទៅ ពាក្យកម្លាយទាំងអស់មិនមានសំណេរដូចពាក្យឫសដែលគេយកមកកម្លាយដើម្បីបង្កើតបានជាពាក្យកម្លាយនោះទេ។

*ទីប្រាំពីរ* សំណេរពាក្យកម្លាយមិនអនុលោមតាមសំណេរនៃពាក្យឫសឡើយ។

*ទីប្រាំបី* សំណេរពាក្យកម្លាយអាស្រ័យលើផ្នត់ដែលមានបរន្តេកម្មជាមួយពាក្យឫសនៅក្នុងបរបទនៃការប្រកបសូរមួយកំណត់ច្បាស់លាស់។

សរុបសេចក្តីមក សំណេរនៃពាក្យកម្លាយជាព្យាង្គតំរួត ជារាយព្យាង្គ ឬជាតំរួតព្យាង្គ មិនមែនបណ្តាលមកពីសំណេរនៃពាក្យឫសនោះទេ តែវាអាស្រ័យលើផ្នត់ដែលតាមលក្ខណៈធាតុរបស់វាត្រូវបានបែងចែកជាទម្រង់ផ្សេងៗ។

---

[១០] តាមទស្សនៈរបស់បណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ មានពាក្យខ្ចីពីភាសាបាលីសំស្ក្រឹតខ្លះដែលមានពីរព្យាង្គ ហើយត្រូវបានកម្លាយតាមរយៈផ្នត់នៃភាសាខ្មែរ។ លោកបានផ្តល់ជាឧទាហរណ៍ថា *ផ្កាសា* ជាពាក្យដែលខ្មែរយើងបានខ្ចីពីភាសាសំស្ក្រឹត ហើយត្រូវបានកម្លាយតាមរយៈផ្នត់ដែក[-អ'ម/ណ-] ឱ្យកើតបានទៅជាពាក្យកម្លាយ *បណ្តាសា* ។

[១១] ភាសាវិទូ ច័ន្ទ សំណព្វ បានបញ្ជាក់ថាក្នុងចំណោមផ្នត់ដែកដែលមានទម្រង់(-សព-)ទាំងអស់ គឺមានតែផ្នត់ដែក[-អ'ម-] មួយគត់ដែលត្រូវបានប្រើសម្រាប់កមនលាយពាក្យឫសដែលមានសំណេរជាព្យាង្គរាយ ហើយផ្នត់ដែក[-អ'ម-] នេះត្រូវបានកត់សូរដោយស្រៈ**អ'ម**ឬដំលើ។ ក្នុងករណីនេះ ពាក្យកម្លាយសុទ្ធតែមានសំណេរជារាយព្យាង្គ ដែលខុសពាក្យពីពាក្យឫសដែលមានសំណេរជាព្យាង្គរាយ។

# គន្ថនិទេស


**ក- ឯកសារភាសាជាតិ**

១- កេង វ៉ាន់សាក់ *មូលភាពនៃការបង្កើតពាក្យថ្មី* ភ្នំពេញ ១៩៦៤។

២- ច័ន្ទ សំណព្វ *អក្សរ ព្យាង្គ ពាក្យ* រាជបណ្ឌិត្យសភាកម្ពុជា ២០១៣។

៣- ច័ន្ទ សំណព្វ *សំណេរនិងអក្ខរាវិរុទ្ធខ្មែរ* រាជបណ្ឌិត្យសភាកម្ពុជា ២០១២ ទំ១៥៥។

៤- ច័ន្ទ សំណព្វ *ទ្រឹស្តីអន្តរកម្មនិយម* សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ២០០៥។

៥- ច័ន្ទ សំណព្វ *បង្កើតពាក្យ កម្ចីពាក្យ បម្រើបម្រាស់ពាក្យ* ភ្នំពេញ ២០១០។

៦- ជួន ណាត *"វចនានុក្រមខ្មែរ ភាគទី១និងភាគទី២"* ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥១១ គ.ស.១៩៦៧។

៧- វង្ស មេង *ភាសា វប្បធម៌ និងសង្គមខ្មែរ* ភ្នំពេញ ២០២០។

៨-វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា *វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ* ភ្នំពេញ ២០១៧។

៩- ឡុង សៀម *"បញ្ហាវចនស័ព្ទវិទ្យាខ្មែរ"* ១៩៩៩។

១០- ឡុង សៀម *"ស្ថាននាមវិទ្យាខ្មែរ"* ១៩៩៧។

១១- អៀវ កើស *"ភាសាខ្មែរ"* ព.ស.២៥០៩ គ.ស.១៩៦៧ បណ្ណាគារមិត្តសេរី។

**ខ- ឯកសារភាសាបរទេស**

1- CHAN Somnoble *Identité et variation des unités de langue : Étude des unités lexico-grammaticales en Khmer contemporain, Université de Paris X-Nanterre, France, 2002*

2- CHAN Somnoble *Linguistique appliquée : Systématique des emplois de təw en Khmer contemporain, Université de Paris X-Nanterre, France, 1998.*

3- CHAN Somnoble *Étude du fonctionnement de ba:n en Khmer contemporain, Université de Paris X-Nanterre, France, 1997.*

4- CHAN Somnoble *Recueil de poèmes : Textos de l'été, Université Royale de Phnom Penh, 1995.*

**គ. និក្ខេបបទ**

១- វង្ស មេង *អន្តរបទ /-ម-/ និង /-ន-/ នៅក្នុងភាសាខ្មែរ* និក្ខេបបទបណ្ឌិតភាសាវិទ្យា ២០១១

**ឃ- ព្រឹត្តិបត្រ ទស្សនាវដ្តី និងសារព័ត៌មាន**

**១- ស្នាដៃជាភាសាខ្មែរ**

ច័ន្ទ សំណព្វ «*ពាក្យកម្លាយនិងពាក្យក្លាយ*» នៅក្នុងៈទស្សនាវដ្តីរាជបណ្ឌិតសភាកម្ពុជា លេខ១ ធមាសទី១ ឆ្នាំ២០០៩។

# «ទេវរាជ៖ និមិត្តរូបនៃការបង្កើតស្ដេចទេវរាជនាសម័យអង្គរ»

ស្រាវជ្រាវដោយ៖ បេក្ខជនបណ្ឌិត Ms. MIAO Si[1]

ប្រែសម្រួលជាភាសាខ្មែរដោយ៖ កញ្ញា **តាកេត ស័កដា**

ត្រួតពិនិត្យដោយ៖ បណ្ឌិត **ផុន កសិកា**

ទេវរាជគឺជានិមិត្តរូបដ៏សំខាន់នៃស្ដេចទេវរាជក្នុងសម័យអង្គរ និង មាន៤ទម្រង់ខុសៗគ្នា។ ទេវរាជបានបង្កើតឡើងក្នុងរាជព្រះបាទជ័យវរ្ម័នទី២ ហើយអង្គរបានឯករាជ្យពីការគ្រប់គ្រងរបស់ជ្វា។ ម្យ៉ាងវិញទៀត ទេវរាជគឺមានវប្បធម៌លាយឡំគ្នារវាងសាសនាឥណ្ឌា និងប្រពៃណីខ្មែរ។ លើសពីនេះ ទេវរាជអាចនិយាយបានថា ជានិមិត្តសញ្ញាយ៉ាងស្អិតរមួតរវាងព្រះ (ទេព) និងព្រះរាជា ដែលឆ្លុះបញ្ចាំងអំពីឥទ្ធិពលសាសនា នៅក្នុងវប្បធម៌ហិណ្ឌូ។ ថ្វីត្បិត ក្នុងរាជស្ដេចនិមួយៗ នាសម័យអង្គ មានភាពខុសគ្នានូវផ្នែកអក្សរសិល្ប៍ ស្ថាបត្យកម្ម និងជំនឿសាសនាក្ដី ក៏ស្ដេចនៃអាណាចក្រអង្គរទាំងអស់ធ្វើពិធីទេវរាជជានិមិត្តរូប ដើម្បីបង្ហាញពីភាពអង់អាច នៃអាណាចក្រអង្គរដ៏រុងរឿង។

❖ ពាក្យគន្លឹះ៖ ទេវរាជ, អាណាចក្រអង្គរ, ការបង្កើតស្ដេចទេវរាជ

សម្រាប់ការសិក្សាអំពីស្ដេចទេវរាជ មិនមានរជ្ជកាលណាប្រសើរជាងក្នុងសម័យអង្គរនេះទេ ដែលជាសម័យកាលបង្ហាញអំពីដំណើរអភិវឌ្ឍពេញលេញចាប់ពីការអភិវឌ្ឍដំបូងៗរហូតដល់កំពូល និងការធ្លាក់ចុះវិញដែលព្រះរាជាក្នុងរាជសម័យអង្គរនីមួយៗបានប្រកាសខ្លួនជាទេពតាមរបៀបផ្សេងៗគ្នា។ ព្រះបាទជ័យវរ្ម័នទី២ គឺជាអ្នកបង្កើតសន្តតិវង្សអង្គរ ជាព្រះមហាក្សត្រដំបូងបង្អស់ដែលឡើងសោយរាជ្យដោយប្រារព្ធពិធីដែលហៅថា «ទេវរាជ» នេះមុនគេហើយជាពាក្យដ៏ទាក់ទាញ ពីអ្នកប្រាជ្ញជាច្រើនចាប់តាំងពាក្យ «ទេវរាជ» ត្រូវបានបកប្រែជាលើកដំបូងចេញពីសិលាចារឹក។ ការពិភាក្សាអាចបែងចែកជា៣ផ្នែកធំៗមានដូចជា៖ ១.

---

[1] Doctoral Candidate from Institute of International and Area Studies and Law School, Tsinghua University.

សង្កត់ធ្ងន់ទៅលើប្រពៃណីរបស់ទេវរាជ, ២. ផ្ដោតទៅលើឥទ្ធិពលនៃវប្បធម៌ទេវរាជ និង ៣. ចង្អុលបង្ហាញអំពីការកំណត់និមិត្តសញ្ញានៃទេវរាជ។ ទិដ្ឋភាពទាំងបីដែលបានរៀបរាប់នេះគ្រាន់តែជាទម្រង់លក្ខណៈមួយចំនួនរបស់ទេវរាជក៏ពិតមែន ប៉ុន្តែនៅតែពុំទាន់បង្ហាញគ្រប់គ្រាន់នូវទម្រង់ពេញលេញរបស់ទេវរាជនៅឡើយ។ អត្ថបទនេះ ចង់ស្វែងយល់អំពីទស្សនៈនៃការបង្កើតទេវរាជ និង កំណត់ការឡើងគ្រងរាជ្យរបស់ស្ដេចទេវរាជនៅកម្ពុជា ក្នុងគោលបំណងផ្ដល់នូវទស្សនៈថ្មីមួយនៃការសិក្សាអំពីស្ដេចទេវរាជកម្ពុជា។

## ១. ការប្រារព្ធពិធីទេវរាជ

ជាពិធីដ៏មានសារៈសំខាន់មួយនៃការឡើងសោយរាជ្យរបស់ព្រះបាទជ័យវរ្ម័នទី២ តំណាងឱ្យការចាប់ផ្ដើមនៃយុគសម័យអង្គរ។ អ្នកប្រាជ្ញ **កុលកេ Kulke** បានលើកឡើងសង្កត់ធ្ងន់ទៅលើពិធីទេវរាជ ដោយដកស្រង់នូវស្នាព្រះហស្ដរបស់ព្រះបាទជ័យវរ្ម័នទី២ និងភាពរីកររនៃការបែងចែកអាណាចក្រទាំងពី និងការធ្លាក់ចុះរបស់ចេនឡា ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជ្វា។ ទិដ្ឋភាពដ៏សំខាន់បំផុតរបស់ទេវរាជនោះគឺជាពិធីតែងតាំងមួយដ៏ធំ ដែលមានផ្សារភ្ជាប់ទំនាក់ទំនងគ្នាយ៉ាងទូលំទូលាយរវាងស្ដេច និងចេនឡានាពេលនោះ។ រីឯបញ្ហា គឺត្រូវបានប្រឈមមុខដោយអាណាចក្រក្រោយៗមកទៀត មានការស្លាបនាខុសៗគ្នា។ សារៈសំខាន់នៃពិធីទេវរាជបានរលាយបាត់បន្តិចម្ដងៗ រហូតដល់ស្ទើរលែងមានតទៅទៀត ដោយសារបញ្ហាប្រឈមរបស់អាណាចក្រក្រោយៗ ខុសពីសម័យដើម ហើយស្ដេចមួយចំនួនបន្តបន្ទាប់ទៀតបាននៅបន្តធ្វើពិធីដដែល។

ការយល់ឃើញរបស់អ្នកប្រាជ្ញ Herman Kulke អំពីទេវរាជ គឺមានទំនោរទៅរកទេវរាជច្រើនជាងពិធីសាសនា។ ផ្ទុយទៅវិញ អ្នកប្រាជ្ញផ្សេងទៀតបានកំណត់ថា លិង្គ(Linga) និងស្ថាបត្យកម្មប្រាសាទភ្នំគឺមានទាក់ទងគ្នាជាមួយនឹងទេវរាជ។ អ្នកប្រាជ្ញ Kulke ចូលចិត្តការស្រាវជ្រាវ តាមរយៈការអានសិលាចារឹក ដោយលើកហេតុផលថា ការពិតនៃទេវរាជត្រូវបានស្ដារឡើងវិញតាមរយៈកំណត់ត្រាជាលាយលក្ខណ៍អក្សរ ខណៈពេលដែលការបកស្រាយ

ដោយមិនប្រើជាអក្សរ តាមរយៈ លិង្គ (Linga) ដែលមានតួនាទ ស្ថិតក្នុងការស្រមើស្រមៃរបស់អ្នកនិពន្ធ។ ផ្អែកទៅលើការអានសិលាចារឹកស្តុកកក់ធំ អ្នកប្រាជ្ញ Kulke អះអាងថា មានអត្ថន័យសំខាន់៤យ៉ាងរបស់ទេវរាជ៖

១. ការប្រកាសរំដោះកម្ពុជាពីការគ្រប់គ្រងរបស់ជ្វា

២. ការឡើងសោយរាជ្យរបស់ព្រះបាទជ័យវរ្ម័នទី២ផ្ទាល់

៣. ការលើកឡើងអំពីការបង្រួបបង្រួមគ្នារវាងចេនឡាដីគោក និងចេនឡាទឹក

៤. ភាពឱឡារិកនៃពិធីទេវរាជ។

ផ្អែកទៅលើសិលាចារឹកស្តុកកក់ធំ គោលបំណងនៃពិធីទេវរាជគឺដើម្បីប្រកាសថា ពីពេលនេះតទៅ កម្ពុជាទទួលបានឯករាជ្យពីការគ្រប់គ្រងរបស់ជ្វា ហើយព្រះបាទជ័យវរ្ម័នទី២ គឺជាស្តេចផែនដី (ស្តេចចក្រវាឡ)។ លើសពីនេះទៅទៀត ពិធីទេវរាជគឺជាពិធីដ៏ឱឡារិកដំបូងបង្អស់ នាសម័យអង្គរ។ លទ្ធិទេវរាជ គឺមិនសំដៅទៅលើស្តេច តែសំដៅទៅលើព្រះសិវៈ ដែលក្លាយជាស្តេចទេវរាជ ដែលបានការពារប្រទេសកម្ពុជាពីការឈ្លានពានរបស់ជ្វា និងបានប្រទានពរឱ្យប្រទេសមានភាពរុងរឿង។ ទិដ្ឋភាពសំខាន់ផ្សេងទៀតនៃទេវរាជគឺ ការបង្រួបបង្រួមគ្នារវាងចេនឡាទាំងពីរ។ ជាស្តេចដំបូងដែលបង្រួបបង្រួមការបែកបាក់របស់ចេនឡា ព្រះបាទជ័យវរ្ម័នទី២បានតម្រូវឱ្យមានពិធី ដើម្បីពង្រីកព្រំដែននៃការគ្រប់គ្រងរបស់ទ្រង់[2]។

លោក I.W. Mabbett បានសង្កត់ធ្ងន់លើពិធីសាសនាទេវរាជ ដែលផ្សារភ្ជាប់ទៅនឹងអាណាចក្រដែនដី និងអាទិទេព ទៅតាមក្បួនខ្នាតយ៉ាងជាក់លាក់ នៅកន្លែងដែលអាចបញ្ជូនសារពីអាទិទេពមកដែនដី។ នៅក្នុងការបកស្រាយផ្សេងទៀត បានលើកឡើងថា ទេវរាជបង្កើតឱ្យស្តេចមានភាពស្មើគ្នាជាមួយនឹងទេព។ ក៏ប៉ុន្តែទេពរបស់ស្តេចគឺមិនខុសប្លែកពីគេនោះទេ គឺមានពីកំណើត។ ទេព គឺត្រូវបានស្នងដោយស្តេច រួមជាមួយនឹងភាពជោគជ័យរបស់ព្រះអង្គតាមរយៈការធ្វើពិធីនៅក្នុងពិធីទេវរាជ។ តាមរយៈការវិភាគផ្ទាំងសិលាចារឹក និងរូបសំណាក

[2] Hermann Kulke, *The Devaraja Cult* (tr. I. W. Mabbett), Ithaca: Cornell University Southeast Asia Programme, 1978, pp.14-24.

លិង្គ ដែលជាទីគោរពរបស់ព្រះមហាក្សត្រ ព្រះបរមរាជវាំង និងទំនុកចម្រៀងថ្វាយទេព លោក Mabbett បានលើកឡើងថា ពិធីទេវរាជគឺជាពិធីមួយដ៏សំខាន់នៃការទទួលស្គាល់ជាព្រះមហាក្សត្រ។ ការទទួលស្គាល់ជាព្រះមហាក្សត្រ គឺមិនបានទទួលបានមកពីទេពរបស់ព្រះអង្គនោះទេ។ ប៉ុន្តែជាការពិតណាស់ ពិធីឡើងគ្រងរាជរបស់ព្រះមហាក្សត្រ គឺបានផ្តល់និយមន័យដោយធានាបាននូវការទទួលស្គាល់ជាព្រះមហាក្សត្រស្របច្បាប់យ៉ាងពិតប្រាកដ។ ទេពគឺជាផ្នែកមួយយ៉ាងសំខាន់ នៅក្នុងពិធីទេវរាជ និងរូបសំណាក់លិង្គ ដែលជានិមិត្តរូបរបស់ព្រះសិវៈចាប់ផ្តើមនៅដើមសម័យអង្គរ។ ការជ្រើសរើសពិធីទេវរាជ នៅតែជាពិធីចម្បងសម្រាប់គោលបំណង នៃការទទួលស្គាល់ នៃការឡើងគ្រប់គ្រងជាព្រះមហាក្សត្រស្របច្បាប់។ រូបសំណាកព្រះមហាក្សត្រ ជាធម្មតាមានទីតាំងនៅចំកណ្តាលព្រះបរមរាជវាំង ដែលតំណាងឱ្យមជ្ឈមណ្ឌលនៃអាណាចក្រ ប្រៀបបាននឹងកណ្តាលនៃចក្រវាឡ។ លោក Mabbett បានសំដៅទៅលើការបកស្រាយ ទំនុកចម្រៀងថ្វាយទេព នៅក្នុងសិលាចារឹក ដែលជានិច្ចកាលប្រើដើម្បីច្រៀងរៀបរាប់អំពីទេព និងព្រះមហាក្សត្រ ក្នុងអត្ថន័យថា ទេព និងស្តេច តាមពិតគឺតែមួយ[3]។ លោក Mabbett ក៏បានបំផុសគំនិត ដោយលើកឡើងអំពីលោក Briggs ដែលបានពង្រីកការសិក្សារបស់គាត់ បន្តពីលោក Mabbett ហើយសិក្សាអំពី បុព្វជិតរបស់ព្រះមហាក្សត្រ និងខ្សែរាជវង្ស។

លោក L. P. Briggs បានសិក្សា និងយល់ដឹងច្រើនអំពីពិធីទេវរាជ និងបានអះអាងអំពីដំណើរក្លាយជាព្រះមហាក្សត្រ ក្នុងនោះលោក Briggs ក៏បានសិក្សាផ្តោតលើបុព្វជិតដែរ និងបង្ហាញអំពីការគ្រង់ដ៏ល្អពិសិដ្ឋនាសម័យអង្គរ។ លោក Briggs បានមកស្រាយយ៉ាងពេញលេញអំពីពិធីទេវរាជ និងព្យាយាមបង្កើតរូបភាពនៃពិធីទេវរាជតាមរយៈសិលាចារឹកផ្សេងៗគ្នាតាមរយៈបុរាណវត្ថុ សំណង់ស្ថាបត្យកម្ម ប្លង់នៃបរមរាជវាំង និងរចនាបថនៃរូបចម្លាក់។ លោក Briggs ក៏បានរៀបរាប់អំពីពិធីទេវរាជ ត្រូវបានរៀបចំប្រារព្ធពិធីនេះដំបូងបង្អស់ដោយ

---

[3] I. W. Mabbett, “Devarāja”, *Journal of Southeast Asian History*, Vol. 10, No. 2 (Sep., 1969), pp.220-223.

Hiranyadama ដែលជាអ្នកជំនាញផ្នែកពិធីសាសនា បានអញ្ជើញពីចម្ងាយមកដោយ ព្រះបាទជ័យវរ្ម័នទី២ ដែលក្រោយមកបានប្រគល់សិទ្ធិអំណាចឱ្យធ្វើពិធីទេវរាជថ្វាយព្រះសិរៈ ហើយក៏បានក្លាយទៅជាអ្នករៀបចំប្រារព្ធពិធីដ៏ធំបំផុត នៃពិធីទេវរាជ។ លោក Briggs បានលើកឡើងថាពិធីទេវរាជគឺជាពិធីសោយរាជ្យឱ្យក្លាយទៅជាស្តេចទេព ហើយជាពិធីទទួលស្គាល់ពេញលេញដោយបុព្វជិតជាច្រើន ដែលនាសម័យអង្គរ បានប្រកាសការគ្រប់គ្រងនៃអំណាចទេព។ លោក Briggs ប្រើប្រាស់កស្តុតាងសិលាចារឹក ដើម្បីស្វែងយល់អំពីខ្សែរាជវង្ស និងឥស្សរជនជាច្រើនទៀត ដោយលើកយកតួនាទីរបស់បុព្វជិត នៅក្នុងពិធីទេវរាជ និងការស្នងរាជ្យបល្ល័ង[4] ។ យ៉ាងណាមិញ ឯកសារដែលអ្នកប្រាជ្ញជាច្រើនបានសិក្សាតាមលំដាប់លំដោយ។ ជាទូទៅសម្រាប់ឯកសារដែលជាទស្សនៈវិស័យសាសនា។ ចំណុចសំខាន់នៃពីធីទេវរាជសង្កត់ធ្ងន់ទៅលើប្រវត្តិសាស្ត្រខ្មែរ ដែលបានទទួលបានឯករាជ្យពីចេនឡា និងទិដ្ឋភាពក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី២ ដែលបានបង្កើតប្រព័ន្ធនយោបាយ និងជាអ្នកកំណត់ការប្រារព្ធពិធីសាសនាមុនគេបង្អោះនាសម័យអង្គរ។ ពិធីទេវរាជគឺជាទស្សនៈមួយដែលបានដកស្រង់ចេញពីឯកសារប្រវត្តិសាស្ត្រ ប៉ុន្តែទស្សនៈរបស់ពិធី គឺផ្តោតទៅលើចំណុចមួយក្នុងប្រវត្តិសាស្ត្រ ដែលមិនបានផ្តោតលើការបន្តប្រវត្តិសាស្ត្រ និងអន្តរកម្មនៃប្រវត្តិសាស្ត្រ ជាមួយនឹងពិធីទេវរាជរបស់ព្រះបាទជ័យវរ្ម័នទី២ ការត្រឡប់មកវិញនៃនគរភ្នំចេនឡា និងការក្រឡេកទៅមើលចំណុចនៃទស្សនៈរបស់ពិធីសាសនាដែលមិនអាចពន្យល់អំពីឥទ្ធិពលនៃពិធីទេវរាជ ណាមួយដែលចាំបាច់តម្រូវឱ្យមានទស្សនៈទូលំទូលាយនៃពិធីសាសនា។

## ទេវរាជជានិមិត្តរូបនៃវប្បធម៌

ទោះបីជានិមិត្តរូបនៃទេវរាជបានទាក់ទាញចំណាប់អារម្មណ៍ជាយូរមកហើយ និងមានការពិភាក្សារវាងអ្នកសិក្សាស្រាវជ្រាវនៅប៉ែកអឺរ៉ុប និងអ្នកសិក្សាស្រាវជ្រាវកម្ពុជាក្តី ទេវរាជនៅតែជាទស្សនៈដ៏ពេញនិយមពីសំណាក់អ្នកស្រាវជ្រាវអំពីវិស័យវប្បធម៌។ ក្នុងអត្ថន័យនៃពាក្យថា «

[4] Lawrence Palmer Briggs, *The Ancient Khmer Empire*, Philadelphia: The American Philosophical Society, 1951, pp.81-85.

ទេវរាជ» លោក G. Coedes ឱ្យនិយមន័យថា «ទេវ» គឺជាបញ្ជាក់នៃឱ្យ «រាជ» មានន័យថា ទេពដូចជាស្ដេច។ ចំពោះ G. Coedes ទេវរាជ គឺពិតជាផ្នែកមួយយ៉ាងសំខាន់ណាស់ក្នុងវប្បធម៌ខ្មែរ ដែលបានរួមបញ្ចូលក្នុងវត្ថុធាតុជាច្រើនដូចជា៖ សិលាចារឹក, រូបសំណាកលិង្គ, រូបចម្លាក់, រាជវាំង, ប្រាសាទភ្នំ និងបណ្ដាញដែលមានទំនាក់ទំនងជាមួយព្រះមហាក្សត្រ ដែលមានដូចជា៖ បុព្វជិត, រដ្ឋមន្ត្រី និងស្រ្តី ដែលពាក់ព័ន្ធនឹងជំនឿសាសនា ព្រះសិវៈនិយម, តង់ត្រិកនិយម, សាសនាមហាយាន, និងព្រះវិស្ណុនិយម។ លោក G. Coedes អះអាងថា ទេវរាជ ជាផ្នែកមួយនៃវប្បធម៌ខ្មែរ និងមានសមាសធាតុដ៏ចាំបាច់របស់ទេវរាជទាក់ទងនឹងទឹក ដែលបានបង្ហាញនៅក្នុងពិធីទេវរាជ។ ពិធីទេវរាជ គឺជាទំនៀមនៃពិធីធ្វើឱ្យទៅជាព្រះមហាក្សត្រ គឺជាទំនៀមនៃពិធីគោរពបូជាចំពោះរូបសំណាកលិង្គ និងឱ្យព្រះនាមរបស់ស្ដេចថាជាទេព ដែលតំណាងឱ្យស្ដេច និងទេព គឺតែមួយ។ ទេវរាជ គឺជាពិធិធ្វើឱ្យព្រះសិវៈមានការគោរពខ្លាំង ក្នុងតំបន់អាស៊ីអាគ្នេយ៍។ ការចាប់ផ្ដើមនៃរាជ្យព្រះបាទជ័យវរ្ម័នទី២ ជាព្រះមហាក្សត្រដ៏អស្ចារ្យ នាសម័យអង្គរ ដោយសារការបង្កើតរូបសំណាកលិង្គ និងសំណង់ស្ថាបត្យកម្មសម្រាប់ព្រះអង្គផ្ទាល់ ហើយព្រះមហាក្សត្រនិមួយៗក្លាយជាស្ដេចទេវរាជនៃអាណាចក្រអង្គរ ចាប់ពីពេលនោះមក។ រូបសំណាកលិង្គបានសាងសង់ឡើងស្របពេលនៃការបង្កើតពិធីទេវរាជរបស់ព្រះមហាក្សត្រ ប៉ុន្តែអាវតាររបស់ព្រះសិវៈ បានបញ្ជូនទៅព្រះមហាក្សត្រដោយព្រាហ្មណ៍។ ក្នុងនាមជាស្ដេចជ្រែករាជ្យ ព្រះបាទជ័យវរ្ម័នទ៤ មានជំនឿលើព្រះសិវៈ ទ្រង់បានសង់ប្រាសាទរបស់ព្រះអង្គថ្វាយព្រហសិវៈ។ ប្រាសាទបាយ័ន សាងសង់ដោយព្រះបាទជ័យវរ្ម័នទី៧ ដែលមានបដិមាព្រះអង្គជារូបព្រះពុទ្ធ។ ការសន្មតនៃជំនឿទេវរាជគឺស្ថិតក្នុងកម្រិតកំពូល គឺអាស្រ័យលើការសិក្សាស៊ីជម្រៅនៃប្រវត្តិសាស្រ្តកម្ពុជា។ លោក G. Coedes អះអាងការធ្វើឥណ្ឌានីយកម្ម នៅតំបន់អាស៊ីអាគ្នេយ៍ ជាលទ្ធផលនៃឥទ្ធិពលវប្បធម៌ឥណ្ឌាជាប្រវត្តិសាស្រ្ត។ វប្បធម៌នៃពិធីទេវរាជគឺ ការរួមបញ្ចូលគ្នារវាងវប្បធម៌ឥណ្ឌា និងវប្បធម៌ក្នុងតំបន់ ក្នុងដំណើរនៃការរីកសាយ

កាយវប្បធម៌ឥណ្ឌាខ្លាំងក្នុងតំបន់អាស៊ីអាគ្នេយ៍[5]។

ការបកប្រែរបស់ លោក G. Coedes អំពីឥណ្ឌានីយកម្ម នៃវប្បធម៌ទេវរាជ គឺពិតជាបានបណ្ដុះគំនិតសម្រាប់អ្នកសិក្សាស្រាវជ្រាវជាច្រើន ហើយ លោក សុង លីតាវ (Song Lidao) បានសិក្សាយោងទៅលើវប្បធម៌ទេវរាជ ជាគោលគំនិតនៃស្ដេចទេវរាជ ប៉ុន្តែនៅក្នុងខ្លឹមសារ គឺជាប្រពៃណីចាក់ឫសក្នុងវប្បធម៌ខ្មែរ ដែលមានជាយូរលុងណាស់មកហើយ។ មិនដូចទ្រឹស្ដីរបស់ លោក G. Coedes លើកឡើងអំពីអាណានិគមឥណ្ឌា ទោះបីជាយ៉ាងណាក៏ដោយលោក សុង លីតាវ Song Lidao បានស្នើឱ្យទ្រឹស្ដីបញ្ចូលគ្នាវប្បធម៌ឥណ្ឌា ទៅនឹងវប្បធម៌ក្នុងតំបន់អាស៊ីអាគ្នេយ៍។ ទស្សនៈនយោបាយនៃភាពជាស្ដេចនៅក្នុងបណ្ដាប្រទេសភាគខាងត្បូងដែលកាន់សាសនាពុទ្ធ ត្រូវបានបង្កើតឡើងដោយឥណ្ឌា ដែលត្រូវបានឆ្លុះបញ្ចាំងអំពីស្ដេចទេវរាជដែលបានបង្ហាញនៅក្នុងសិលាចារឹក និងគោលគំនិតពុទ្ធសាសនានៃស្ដេចព្រះធម៌ ឬស្ដេច Cakravarti ជាមួយនឹងរូបសំណាកលិង្គ ដែលជានិមិត្តរូបនៃការរួបរួមនៃព្រះសិវៈជាមួយនឹងអំណាចរាជវង្ស ដែលជាគំនិតនៃស្ដេចទេវរាជត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគម្ពីរតំណាងរបស់ឥណ្ឌា Manava-Dharma-Sastra ដែលពិភពលោកបានធ្លាក់ចូលទៅក្នុងភាពវឹកវរហើយព្រាហ្មបានប្រើប្រាស់ឱវាទរបស់ព្រះដើម្បីបង្កើតស្ដេច[6]។ ឥទ្ធិពល នៃអ្នកកាន់សាសនាព្រះពុទ្ធថេរវាទ គឺបានបត់បែនទៅតាមរបបផ្ដាច់ការរបស់ស្ដេច ត្បិតស្ដេចគឺជាទេព ហើយកម្មផល ឬនិស្ស័យល្អរបស់ព្រះអង្គ បង្ហាញពីភាពត្រឹមត្រូវនៃការគ្រប់គ្រងរបស់ទ្រង់។ ទស្សនៈ របស់អ្នកកាន់សាសនាព្រះពុទ្ធថេរវាទ ដែលពិភពលោកបានចាប់ផ្ដើមបង្កើត និងបញ្ចប់ទៅវិញដោយភាពសុខដុមរមនា។ ទេព ឬព្រះ គឺជិតស្និទ្ធបំផុតនឹងអំណាចនៃចក្រវាឡ ត្រូវបានលើកតម្កើងដោយធម្មជាតិផ្សារភ្ជាប់ជាមួយទេព ឬព្រះ។ ច្បាប់នៃការគ្រប់គ្រងរបស់ស្ដេចគឺបានមកពីទេពរបស់ទ្រង់ ហើយការសម្របខ្លួនដែលអាចបត់បែនបាន ដោយអនុញ្ញាតឱ្យមានស្ដេចថ្មីឡើង

[5] George Cœdès, The Indianized States of Southeast Asia, Honolulu: University of Hawaii Press,1996, pp.97-103.

[6] Song Lidao, *Shensheng yu Shisu: Nanchuanfojiaoguojiadezongjiaoyuzhengzhi*(Divinity and Secularism: Religion and Politics in Theravada Buddhism Countries), Beijing: Press of Religions, 2000, p.72.

សោយរាជ្យដោយមិនបោះបង់ចោលវប្បធម៌ទេវរាជ និងមិនគិតពីការផ្លាស់ប្តូររបប។ "វិបត្តិសង្គមនៃការពិតមិនអាចលុបចោលតាមរយៈការពន្យល់បែបមនោគមវិជ្ជានោះទេ។ ផ្ទុយទៅវិញបន្ទិតបង្ខំសង្គមណាមួយដែលស្វែងរកការផ្លាស់ប្តូរសណ្តាប់ធ្នាប់សង្គមដែលមានស្រាប់ដើម្បីជំនួសអំណាចនយោបាយចាស់អាចទៅរកទ្រឹស្តីដូចគ្នា (រួមទាំងទ្រឹស្តីសាសនា) សម្រាប់អំណះអំណាងនៃភាពស្របច្បាប់។ ទាំងនេះជាហេតុផលមួយដែលគំនិតនយោបាយពុទ្ធសាសនាភាគខាងត្បូងអាចឆ្លងកាត់សម័យកាលផ្សេងៗគ្នា ហើយនៅតែបម្រើដល់របបនិមួយៗនោះបាន»[7]។

លោក ចាង ហុងយុន Zhang Hongyun បង្កើតទៅលើស្នាដៃរបស់ លោក លីតាវ ដោយសង្កត់ធ្ងន់លើលក្ខណៈវប្បធម៌ទេវរាជនៅតំបន់អាស៊ីអាគ្នេយ៍ ដោយមើលឃើញវប្បធម៌របស់ស្តេចដែលតំណាងដោយ«ទេវរាជ»។ លោក ហុងយុន មិនបដិសេធឥទ្ធិពលនៃទំនៀមទំលាប់របស់ទេពឥណ្ឌាមកលើវប្បធម៌របស់ស្តេចនៅតំបន់អាស៊ីអាគ្នេយ៍នោះទេ ដោយសារឈ្មោះនិងគុណធម៌របស់ស្តេច ត្រូវបានគេយកតម្រាប់តាមរឿងបុរាណដែលទាក់ទងនឹងព្រះរបស់ឥណ្ឌា ហើយស្តេចបានប្រើពិធីសាសនាដើម្បីបង្កើតទំនាក់ទំនងរវាងអំណាចព្រះសិរៈ និងខ្លួនពួកគេផ្ទាល់។ ប៉ុន្តែការអភិវឌ្ឍន៍នៃវប្បធម៌របស់ស្តេចទេវរាជ ក្នុងបណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍បង្ហាញពីទិសដៅផ្សេងៗគ្នា ហើយអាចបែងចែកជាបីប្រភេទគឺ អង្គរកណ្តាល ជ្វាកណ្តាល និងថៃកណ្តាល ដែលអង្គរមានភាពចំណាស់ជាងគេ។ ពិធីទេវរាជត្រូវបានឆ្លុះបញ្ចាំងក្នុងកម្រិតពីរប្រភេទខុសគ្នា ខណៈដែលស្តេចនៅតំបន់កោះក៏ប្រើពិធីសាសនា ការផឹកទឹកសម្បថ និងការធ្វើមាគ៌ាផ្ទៃក្នុងដើម្បីបង្ហាញពីខ្លួនជាការរួមបញ្ចូលខ្លួនទៅនឹងព្រះសិរៈ ហើយស្តេចសៀម បានឃើញថា ស្តេចមិនត្រឹមតែជាស្តេចនៃទេពប៉ុណ្ណោះទេ ថែមទាំងជាស្តេចនៃព្រះពុទ្ធ និងព្រះធម៌ទៀតផង។ ដោយស្តេចបានធ្វើ «សច្ចាប្រណិធាន» ស្តេចមានអំណាចក្នុងការប្រាស្រ័យទាក់ទងជាមួយទេព ក្នុងពេលប្រារព្ធពិធី «សច្ចាប្រណិធាន»។ ហើយនៅថ្ងៃ

---

[7] Ibid, p.84.

នៃពិធីឡើងសោយរាជ្យរបស់ស្ដេចសៀមក៏បានប្រារព្ធក្នុងទម្រង់នៃពិធីទេវរាជ។ បន្ទាប់ពីសិក្សាអំពីប្រភេទស្ដេចផ្សេងៗគ្នា លោក ហុងយុន បានសង្ខេបអំពីលក្ខណៈនៃវប្បធម៌ស្ដេចទេវរាជនៅតំបន់អាស៊ីអាគ្នេយ៍ជា ៧ លក្ខណៈផ្សេងគ្នារួមមាន៖

១. ការទស្សន៍ទាយប្រភពដើមរបស់ស្ដេច

២. ការទស្សន៍ទាយនៃឋានៈរបស់ស្ដេច

៣. ការទស្សន៍ទាយនៃចរិតលក្ខណៈរបស់ស្ដេច

៤. ការទស្សន៍ទាយនៃការគោរពបូជារូបសំណាកលិង្គ

៥. ការបង្ហាញរូបអាទិទេព និងរូបសំណាករបស់ស្ដេច

៦. ការរៀបចំសំណង់ស្ថាបត្យកម្ម

៧. ការរៀបចំនៃការគ្រប់គ្រងអាណាចក្រ[8]។

សរុបមក អ្នកប្រាជ្ញទាំងនេះបានសង្កត់ធ្ងន់កាន់តែខ្លាំងទៅលើការសម្រេចខ្លួនរបស់ស្ដេច ពីក្រោយការប្រារព្ធពិធីទេវរាជ ដែលតាមទស្សនៈរបស់ពួកគេ ទោះបីគ្រាន់តែជាឈ្មោះពិធីសាសនាក៏ដោយ គឺជាការបង្ហាញត្រឹមត្រូវបំផុតនៃលកខណៈស្ដេចទេវរាជ នៅតំបន់អាស៊ីអាគ្នេយ៍ ដែលមិនអាចមិនអើពើបាន។ ទោះបីជាអ្នកប្រាជ្ញទាំងនេះមិនយល់ស្របលើសមាមាត្រនៃវប្បធម៌ឥណ្ឌា និងជនជាតិដើមភាគតិចក៏ដោយ ក៏ពួកគេកត់សម្គាល់ពីសារៈសំខាន់នៃវប្បធម៌ទេវរាជ ដែលជាការផ្សារភ្ជាប់គ្នារវាងវប្បធម៌ឥណ្ឌា និងវប្បធម៌អាស៊ីអាគ្នេយ៍ ដែលកើតចេញពីវប្បធម៌សាសនាឥណ្ឌា ហើយបានបន្តក្នុងសម័យអង្គរ ខណៈពេលដែលកំពុងរីករាលដាលទៅខាងក្រៅពាសពេញតំបន់អាស៊ីអាគ្នេយ៍។ វាងាយស្រួលនឹងមើលឃើញថា ទស្សនៈវប្បធម៌របស់ទេវរាជបំពេញចន្លោះនៃពិធីសាសនា ទស្សនៈមួយទៀតមើលឃើញពីភាពស្មុគស្មាញ និងភាពសម្បូរបែបនៃទេវរាជ ប៉ុន្តែទស្សនៈវប្បធម៌របស់ទេវរាជគឺទូលំទូលាយខ្លាំង ដោយពន្យល់ពីប្រវត្តិរបស់ទេវរាជ អតីតកាល និង អនាគតកាល។ ប៉ុន្តែការ ពិតនៃទេវរាជ ច្រើនតែបាត់បង់

---

[8] Zhang Hongyun, *Dongnanyashenwangwenhuayanjiu*(Research of God-King Culture in Southeast Asia), Beijing: Social Science Press of China, 2017, pp.185-188.

ទៅដោយសេចក្តីលម្អិតប្រវត្តិសាស្ត្របែបនិទានកថា ប្រសិនបើទស្សនៈនៃពិធីសាសនាជាចំណុចមួយ នោះទស្សនវិស័យវប្បធម៌គឺមានភាពស្មុគស្មាញដូចសរសៃអំបោះ ទៅលើការបាត់បង់ដ៏ធំធេងដំបូង និងភាពសម្បូរបែប មិនអាចបែងចែកបាន។ ទាំងទស្សនវិស័យពិធីសាសនា និងវប្បធម៌ មានគុណសម្បត្តិ និងគុណវិបត្តិរបស់វា។ តើមានទស្សនៈវិស័យទីបីដែលល្អឥតខ្ចោះជាងនេះ ដែលធ្វើឱ្យមានតុល្យភាពរវាងភាពជាក់លាក់នៃទស្សនៈវិស័យពិធីសាសនា ជាមួយនឹងភាពស្មុគស្មាញនៃទស្សនៈវប្បធម៌ដែរឬទេ?

## និមិត្តរូបនៃទេវរាជ

អ្នកជំនាញខាងផ្នែកនរវិទ្យា ឈ្មោះថា Geertz បានកំណត់អត្តសញ្ញាណនិមិត្តរូបរបស់ទេវរាជដោយបានយល់ឃើញ និងណែនាំថានិមិត្តរូបទេវរាជ គឺជាលក្ខណៈសំខាន់នៃស្តេចនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ Geertz បានបង្ហាញពីនិមិត្តរូបនៃការរៀបចំពិធទេវរាជ ដោយការវិភាគទំនាក់ទំនងរវាងស្តេច និងឆ្លុះបញ្ចាំងស្ថាប័នអ្វីៗដែលនៅជុំវិញព្រះអង្គ និងទំនាក់ទំនងរវាងរាជវាំង និងអាណាចក្រទាំងមូល។

ទីមួយនោះគឺៈ ការគោរពរបស់ស្តេចទេវរាជ ពាក់ព័ន្ធទៅនឹងទំនាក់ទំនងសំខាន់ៗចំនួនបីគឺៈ ស្តេច និងបុព្វជិត, ស្តេច និងវត្ថុនានា និងភាពជាស្តេចរបស់ព្រះអង្គផ្ទាល់។ លោក Geertz បែងចែកភាពជាស្តេចនៃអាណាចក្រ តាមឋានានុក្រមប្រពៃណីជាបីទម្រង់ដូចជាៈ

១. អ្នកដឹកនាំបុព្វជិតចិន នៅកន្លែងដែលស្តេចធ្វើជាអធិបតីក្នុងសកម្មភាពសាសនា

២. អ្នកតំណាងរបស់សាសនាឥណ្ឌា ដែលស្តេចពឹងផ្អែកលើពួកព្រាហ្មណ៍ ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយព្រះខាងលើ និងលើមន្ត្រីក្រោមឱវាទ។

៣. ចុងក្រោយគឺជា ស្តេចនៃអាណាចក្រអង្គរ ដែលស្តេច និងទេព មានទំនាក់ទំនងគ្នា និងរួមគ្នាតែមួយ ហើយពួកព្រាហ្មណ៍ទាំងអស់ គឺជាផ្នែកចូលរួមបង្កើតស្តេចឱ្យទៅស្តេចទេវរាជ។

ស្តេចបានកំណត់ការគ្រប់គ្រងដោយមានទំនោរខ្លាំងទៅលើការប្រមូលផ្តុំទេពមណ្ឌលរបស់ព្រះអង្គ ដែលស្ថិតក្នុងរចនាសម្ព័ន្ធអំណាចដ៏ស្មុគស្មាញ ហើយព្រះមហាក្សត្របានប្រើប្រាស់

កម្លាំងប្រមូលផ្តុំដើម្បីរក្សារចនាសម្ព័ន្ធរាជាណាចក្រ។ ព្រាហ្មណ៍បានយកតម្រាប់តាមព្រះមហាក្សត្រ ដោយគោរពប្រត្តិបត្តិទេព ហើយក៏គោរពក្រាបបង្គំស្តេចប្រៀបបាននឹងទេពដូចគ្នា។ ស្តេចសម័យអង្គរបែងចែកខ្លួនទ្រង់ជាពីរអង្គ (ជាទេព និងស្តេច) ដើរតួទៅតាមកាលអាកាសផ្សេងគ្នា។ ស្តេចនៅក្នុងពិធីសាសនា ត្រូវរក្សាភាពស្ងប់ស្ងាត់ និងគង់ជាប់ដោយឡែក ចំណែកការបង្ហាញខ្លួនជាទេពគឺនៅចំពោះមនុស្សជាច្រើនបំផុតតាមដែលអាចធ្វើទៅបាន ជាអ្នករក្សានូវទេពរបស់ខ្លួន និងក្លាយខ្លួនជារដ្ឋដែលប្រើប្រាស់ភាសាបាលី «ជាមណ្ឌលគំរូ ក្នុងចំណោមមណ្ឌលគំរូជាច្រើន រូបតំណាងព្រះមហាក្សត្របានពិពណ៌នាអំពីសភាវៈខាងក្រៅរបស់ព្រះអង្គ ហើយអ្វីដែលបានពណ៌នាអំពីសភាវៈខាងក្នុងរបស់ព្រះអង្គនោះគឺៈ ភាពស្រស់ស្អាតនៃភាពជាទេពរបស់ទ្រង់»[9]។ ព្រះមហាក្សត្រកាន់តែមានភាពពិសិដ្ឋ អាណាចក្រកាន់តែរីកចម្រើន ហើយព្រះអង្គកាន់ឃ្លាតចាកឆ្ងាយចេញពីនយោបាយនៃ ហើយការអភិវឌ្ឍន៍នៃអាណាចក្រត្រូវបានជំរុញដោយការត្រង់ត្រាប់តាមនៃអ្នកក្រោមបង្គាប់រហូតដល់អ្នកដែលមានឋានៈខ្ពង់ខ្ពស់ ហើយបានធ្វើឱ្យអាណាចក្រនៃការគ្រប់គ្រងរបស់ព្រះអង្គកាន់តែអស្ចារ្យ។ ក៏ប៉ុន្តែនៅពេលដែលការគ្រប់គ្រងខ្លាំងឈាននឹងដល់ចំណុចកំពូល ព្រះមហាក្សត្រត្រូវបានផ្តាច់ខ្លួន និង «វិសាលភាពក្នុងវិចារណញ្ញាណ» របស់ទ្រង់ចេញពីអ្វីៗទាំងអស់យ៉ាងពិតប្រាកដ ដោយសារចំណុចមួយចំនួននៅក្នុងឋានានុក្រម ធ្វើឱ្យទ្រង់មិនអាចឆ្លងផុតទៅដល់ចំណុចកំពូលដែលជាកន្លែង «ឆាបឆេះយ៉ាងសន្ធោសន្ធៅនៃអានុភាពដ៏អស្ចារ្យ ដែលស្ថិតនៅកន្លែង ដ៏ឆ្ងាយសែនឆ្ងាយ»[10]។

ទី២ៈ ទំនាក់ទំនងរវាងប្រាសាទនិងរដ្ឋធានី លើសពីប្រពៃណីឥណ្ឌា។ នៅក្នុងការពិភាក្សាអំពីអត្ថន័យនៃពាក្យថា «ទេវរាជ» ជារឿយៗតែងមានការបកស្រាយជាពាក្យពីរផ្សេងគ្នា ដោយអ្នកខ្លះអះអាងថាពាក្យ «ទេវ Deva» និងពាក្យ «រាជ Raja» មានន័យថា ស្តេចទេវ

---

[9] Clifford Geertz, *Negara: The Theatre State in Nineteenth-Century Bali*, Cambridge: Princeton Press, 1980, p.130.
[10] Ibid., p.132-133.

រាជ ហើយអត្ថន័យដែលសំខាន់នៃពិធីនោះ គឺដើម្បីថ្វាយសេចក្ដីបរិសុទ្ធដល់ស្ដេចដែលឡើងសោយរាជ្យ។ អ្នកខ្លះជឿថា អត្ថន័យដែលសំខាន់នៃពិធីដើម្បីថ្វាយសេចក្ដីបរិសុទ្ធដល់ស្ដេចដែលឡើងសោយរាជ្យ ខណៈពេលដែលខ្លះទៀតជឿថា ពាក្យ «ទេវ Deva» និងពាក្យ«រាជ Raja» មានន័យថា «ស្ដេចទេវរាជ» ហើយអត្ថន័យសំខាន់នៃពិធីនេះគឺជា ពិធីសាសនាគោរពបូជា ហើយស្ដេចគ្រាន់តែធ្វើពិធីនេះឧទ្ទិសថ្វាយដល់ព្រះសិវៈប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងការស្វែងយល់របស់ខ្ញុំ អត្ថន័យវិភាគរបស់ពាក្យ «ទេវរាជ» គឺមិនបានផ្លាស់ប្ដូរអត្ថន័យសំខាន់បំផុតរបស់ «ទេវរាជ» ណាមួយដោយបំបែកជាពីរអត្ថន័យផ្សេងគ្នាដាច់ស្រឡះពេកនោះទេ។ ខ្លឹមសារគឺ ទេពប្រៀបបានជាស្ដេច ហើយចំណែកឯស្ដេចប្រៀបបាននឹងទេពទេព ឬស្ដេចមានជីវិតរមែងស្លាប់ដូចគ្នាលើភពផែនដី ជាជាងការលើកឡើងថាប្រពៃណីដែលថាមាននៅនាំងនៃការបែងចែកយ៉ាងតឹងរ៉ឹងរវាងសន្តបុគ្គល និងមនុស្សលោក។ ហើយបើទោះបីស្ដេចដែលប្រៀបបានទៅនឹងស្ដេចនៃទេព នៅតែមិនអាចជៀសផុតអំពីសេចក្ដីស្លាប់បាន និងមិនអាចមានជីវិតអមតៈ។ ក៏ប៉ុន្តែ ពាក្យថាទេវរាជ គឺបានផ្សារភ្ជាប់គ្នារវាងទេព និងស្ដេច ហើយស្ដេចលែងនៅក្រោមបង្គាប់ព្រះទៀតហើយ។ ស្ដេចអាចក្លាយជាអវតាររបស់ព្រះ ដោយទទួលមរតកទេវរាជពីធម្មជាតិ ហើយចាប់ផ្ដើមគំនិតផ្ដួចផ្ដើម។ ទោះបីជា «ទេវរាជ» គឺផ្ដើមចេញពីវប្បធម៌ឥណ្ឌាក្ដី វប្បធម៌នៃប្រទេសទាំងពីរ (ខ្មែរ និង ឥណ្ឌា) គឺមានការបែងចែក ដើមកំណើតនៃពាក្យផ្សេងគ្នា។ លក្ខណៈពិសេសមួយបែបនៃវប្បធម៌ ធម៌ហិណ្ឌូ Hindu Dharma គឺសាសនាគ្រប់គ្រងនយោបាយ ហើយនយោបាយជាចំណុះនៃសាសនា ហើយតួនាទីរបស់បុព្ជិតគឺស្ថិតនៅថ្នាក់កំពូលនៃប្រព័ន្ធវណ្ណៈ។ ក៏ប៉ុន្តែ ដើមកំណើតរបស់ «ទេវរាជ» គឺបាននាំយកសាសនា និងនយោបាយមកជាមួយគ្នាយ៉ាងចុះសម្រុង ដោយស្ដេចគង់ប្រថាប់នៅពីមុខ និងមានបុព្ជិតនៅពីក្រោយ ធ្វើការរួមគ្នាដើម្បីធានាបាននូវការប្រមូលផ្ដុំអំណាច និងស្ថិរភាពនៃរបបនៃការគ្រប់គ្រង។

ទី៣៖ នយោបាយនៃនិមិត្តសញ្ញារបស់ «ទេវរាជ»។ លក្ខណៈរបស់រូបចម្លាក់ដែលស្ថិតចំកណ្តាល រដ្ឋនៃវប្បធម៌ឥណ្ឌានីយកម្ម ហើយនេះជាការបត់បែនគ្រប់ទីកន្លែងក្នុងជីវិតសង្គមណាមួយដែលបានជ្រាបចូលក្នុងជីវិតទាក់ទងនឹងនយោបាយនាសម័យអង្គរ ជាមួយនឹងទេព ស្តេច និងរដ្ឋដែលយកតម្រាប់តាម និងមានភាពប្រទាក់ក្រឡាគ្នាទៅវិញទៅមក។ «ប្រសិនបើរដ្ឋមួយបានកសាងឡើងដោយស្តេច ស្តេចបានសាងឡើងដោយទេព»[11]។ គួរឲ្យកត់សម្គាល់ដែរថា ការកសាងដើម្បីបង្កើតកម្លាំងស្នូលនៃភាពជាស្តេចរបស់ឥណ្ឌូ-អាស៊ីអាគ្នេយ៍ ហើយការយល់ស្របពីភាពបរិសុទ្ធរបស់ស្តេច ត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងភាពស្រដៀងគ្នា ដោយសារការយកតម្រាប់តាមគ្នា ក្នុងន័យថាការធ្វើត្រាប់តាមស្តេចទេវរាជភាគច្រើនបានលេចឡើងក្នុងទឹកដីតែមួយ ដែលសុទ្ធសឹងតែទាមទារកាន់កាប់ទឹកដីដូចគ្នា ដោយមានការបែងចែកអំណាចជាក់ស្តែង អាស្រ័យទៅលើសកម្មភាពទេពកោសល្យរបស់ព្រះមហាក្សត្រនិមួយៗ។ «មានជាប់ពាក់ព័ន្ធមួយចំនួនសម្រាប់ទម្រង់នយោបាយនៅក្នុងរឿងនេះ ប៉ុន្តែក្នុងចំណោមអ្វីដែលសំខាន់ជាងនេះទៅទៀតនោះគឺថា អធិបតេយ្យភាព ក៏ដូចជាទេវរាជ និងមានច្រើនជាងទាំងពីរយ៉ាងនេះទៀត។ ..... ព្រះមហាក្សត្រទាំងអស់គឺមិនអាចប្រៀបផ្ទឹមបាន ប៉ុន្តែព្រះមហាក្សត្រអង្គខ្លះកាន់តែមិនអាចប្រៀបផ្ទឹម និងអង្គណាផ្សេងទៀត ហើយវាគឺជាទំហំនៃជំនឿការគោរពប្រត្តិបត្តិដែលបង្កើតឱ្យមានភាពខុសគ្នា[12]។

ការបកស្រាយរបស់រដ្ឋមានវិស័យផ្តល់ឱ្យដូចជា អ្នកផ្តាច់មុខផ្នែកហឹង្សា គណៈកម្មាធិការប្រតិបត្តិថ្នាក់គ្រប់គ្រង ភ្នាក់ងារដែលមានការអនុញ្ញាត និងស្ថាប័ន សុទ្ធតែមានសមត្ថភាពបកស្រាយតែម្ខាងនៃ «ទេវរាជ» ប៉ុន្តែគ្មានការឯកភាពពីពួកគេ ជាមួយនឹងគោលគន្លឹះនៃ «ទេវរាជ» នោះទេ «ការសិក្សាបែបនេះបានស្តារអារម្មណ៍របស់យើង បញ្ជាឱ្យមានកម្លាំង ក្នុងការបង្ហាញការយកចិត្តទុកដាក់ និងរឿងទេវកថាឡើងវិញ»[13]។ ខណៈពេលដែលនយោបាយ មានហឹង្សា

---

[11] Clifford Geertz, *Negara: The Theatre State in Nineteenth-Century Bali*, Cambridge: Princeton Press, 1980, p.124.
[12] Ibid., pp.124-125.
[13] Ibid., p.121.

និងទិដ្ឋភាពការបង្ហូរឈាម ជាប្រពៃណីរបស់ទ្រឹស្តីនយោបាយ អ្វីដែលលោក Geertz បានការសង្កត់ធ្ងន់គឺជាផ្នែកមួយដែលត្រូវបានគេមើលរំលងជាញឹកញាប់នៃការប្រារព្ធពិធី និងពិធីសាសនា « រចនាសម្ព័ន្ធនៃចលនា ការបង្ហូរឈាមបច្ចុប្បន្ន អ្នកប្រារព្ធពិធីបច្ចុប្បន្ន រួមជានគរផងដែរ និងមានដូចជារចនាសមព័ន្ធនៃគោលគំនិត ដើម្បីពិពណ៌នាថាទាំងនោះជា បណ្តុំមួយទុកតម្កល់គំនិតជាច្រើន »[14]។ ហើយនៅពីក្រោយការប្រារព្ធពិធីនយោបាយ និងពិធីសាសនា គឺជាលក្ខណៈនិមិត្តរូបនៃសកម្មភាពនយោបាយ (និមិត្តរូបគឺជានយោបាយ ការចម្លងឡើងវិញគឺជារដ្ឋ)។ មនុស្សម្នាក់មិនអាចយល់ពីរដ្ឋដោយមិនបានយល់ពីនគរនោះទេ ហើយមនុស្សម្នាក់ក៏មិនអាចយល់ពី «ទេវរាជ» ដោយមិនបានយល់អំពីនិមិត្តរូបរបស់ «ទេវរាជ»នោះដែរ។

លោក Geertz មានទស្សនៈសំខាន់បំផុតរបស់ខ្លួន គឺប្រើប្រាស់និមិត្តរូបជាការចង្អុលបង្ហាញដើម្បីទាញយកអត្ថន័យ «ទេវរាជ» ចេញពីប្រវត្តិសាស្ត្រដ៏លម្អិតរាប់ពាន់ មិនត្រឹមតែពិពណ៌នាអំពីពិធីសាសនាយ៉ាងត្រឹមត្រូវមុនគេបង្អស់ ថែមទាំងជោគជ័យ ក្នុងការបកស្រាយពីការប្រើប្រាស់ «ពិធីទេវរាជ» ដើម្បីផ្សារភ្ជាប់អរិយធម៌អង្គរ ជាមួយនឹងអរិយធម៌អាស៊ីអាគ្នេយ៍បុរាណផ្សេងទៀត ដែលជាកន្លែងដ៏ស៊ីជម្រៅនៃប្រវត្តិសាស្ត្រ និងជាឈុតឆាកដ៏សំខាន់បំផុតនៃតំបន់ដែលត្រូវបានបញ្ចូលគ្នាយ៉ាងល្អិតល្អន់។ ទោះបីជាការសន្និដ្ឋានរបស់លោក Geertz គឺសឹងតែល្អឥតខ្ចោះក្តី ក៏នៅតែមានការខ្វះចន្លោះបន្តិចបន្តួចដែលការបកស្រាយពីនិមិត្តរូបរបស់ទេវរាជនោះមានភាពមិនប្រក្រតី និងមិនសូវស៊ីសង្វាក់គ្នា។ និមិត្តរូបអាចលើកយកមកពន្យល់ពីសម័យកាល និងអារ្យធម៌ ប្រពៃណីរបស់ស្តេចទេវរាជ ក៏ប៉ុន្តែអ្វីដែលមានតែមួយ និងជាភាពមិនយកលំនាំតាមអ្នកណា របស់«ទេវរាជ» នោះគឺត្រូវបានមើលរំលងទៅវិញ។

- **ពិធីទេវរាជ ប្រៀបដូចជាការរៀបចំអាណាចក្រ**

ទិដ្ឋភាពរបស់ពិធីទេវរាជ គឺបានឆ្លុះបញ្ចាំងអំពីសារៈសំខាន់នៃទេវរាជ ដែលជាចំណុចពិសេសមួយក្នុងប្រវត្តិសាស្ត្រ។ ខណៈពេលដាក់ចូលទៅក្នុងបរិបទមួយដ៏អស្ចារ្យ ដែលលាត

[14] Ibid., p.135.

សន្និងអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ និងប្រវត្តិសាស្ត្ររាប់ពាន់ឆ្នាំមកហើយនោះ គឺមានការពិពណ៌នាអំពីវិសាលភាពទូលំទូលាយរបស់ទេវរាជតែមួយគត់ ហើយជាក់ស្តែងគឺពិបាកក្នុងការក្តោបន័យ។ ការបង្ហាញទិដ្ឋភាពនៃនិមិត្តរូបរបស់ទេវរាជ របស់លោក Geertz គឺលោកបានព្យាយាម ដើម្បីបង្កើតទស្សនៈរួមបញ្ចូលគ្នាទាំងពីរ រវាងពិធីសាសនា និងវប្បធម៌។ ហើយតាមរយៈនិមិត្តរូបទាំងនោះអាចបំបែកផ្នែកខ្លះនៃទេវរាជពីប្រវត្តិសាស្ត្រ ក៏ប៉ុន្តែនៅតែមិនទាន់ច្បាស់លាស់នោះទេ។ វាគ្រាន់តែជាការបញ្ចូលគ្នានូវលក្ខណៈនៃភាពជាក់ស្តែងរបស់ពិធីសាសនា លក្ខណៈនៃវប្បធម៌ និងលក្ខណៈនិមិត្តរូបនៃនយោបាយប៉ុណ្ណោះ ទើបការយល់ដឹងដ៏ត្រឹមត្រូវអំពីទេវរាជអាចសម្រេចបាន។ ដូចនេះទើបស្នើសុំអត្ថបទនេះ ដើម្បីបកស្រាយអំពី «ទេវរាជ» ឡើងវិញ ដោយការមើលឃើញ និងសិក្សាចាប់ពីទស្សនៈរបស់អាណាចក្រ ឆ្ពោះទៅប្រវត្តិសាស្ត្រទាំងស្រុង។ ដំបូងឡើយ «ទេវរាជ» គឺប្រៀបដូចជាស្ថាប័នមួយដែលបានផ្សារភ្ជាប់នឹងអ្វីៗជាច្រើន ដែលមានបន្ថែមដោយមនុស្ស និងផ្នែករបស់វត្ថុជាច្រើនទៀត។ ប្រជាជនជាធម្មតាពាក់ព័ន្ធនឹងស្តេច បុព្វជិត និងជំនឿសាសនា ដោយស្តេចគឺជាអ្នកបង្កើត និងជាម្ចាស់នៃពិធីទេវរាជ ហើយបុព្វជិតតែងតែជាអ្នកដឹកនាំពិធី ជាមួយនឹងទេពសិវៈ ដែលជា «ម្លប់នៃសន្តតិវង្ស» នាសម័យអង្គរ អាចប្រារព្ធពិធីទេវរាជ និងពិធីថ្វាយព្រះលិង្គ ហើយជាគោលការណ៍នៃពិធីគឺត្រូវបានប្រារព្ធដោយភាពត្រឹមត្រូវនៃតួនាទីរបស់បុព្វជិតទាំងឡាយក្នុងការប្រារព្ធពិធី។ ប្រពៃណីទំនៀមទម្លាប់ដើមដំបូងបង្អស់របស់ស្តេចទេវរាជ ត្រូវបានគ្របដណ្តប់ដោយជំនឿព្រះសិវៈ ហើយបានប្រែមកចូលក្នុងវប្បធម៌ព្រះវិស្ណុ និងព្រះពុទ្ធសាសនាមហាយានវិញ នាំទៅរកនាមថា «ព្រះវិស្ណុ និង ព្រះពុទ្ធ»។ ឥទ្ធិពលនេះបានបន្តមកដល់សម័យទំនើប ដូចករណីព្រះពុទ្ធបដិមានៅប្រាសាទព្រះគោ ក្នុងទីក្រុងភ្នំពេញ ដែលគេគិតថាជារូបសំណាករបស់ព្រះបាទនរោត្តម។ វាត្រូវបានគេចាត់ទុកថាជាការចាប់បដិសន្ធិពិតប្រាកដនៃរូបភាពរបស់ស្តេចទេវរាជ ហើយប្រពៃណីរបស់ស្តេចទេវរាជត្រូវបានបង្កប់នៅក្នុង «សង្គមដែលនិយមព្រះពុទ្ធសាសនា» របស់ព្រះបាទនរោត្តមសីហនុ។ សមាសធាតុរូបរាងរបស់រូបសំណាក

លិង្គ ត្រូវបានទុករក្សានូវជាវត្ថុគង់នៅតាំងពីសម័យបុរាណ ក្នុងព្រះបរមរាជវាំង។ ដំបូងឡើយ រូបសំណាកលិង្គបានសាងសង់ឡើងនៅសតវត្សទី៩ ក្នុងអំឡុងពេលដែលពិធីទេវរាជត្រូវបាន ចាប់ផ្តើមបង្កើតឡើងដំបូងនាសម័យអង្គរ។ មិនថានៅក្នុងព្រះពុទ្ធសាសនាមហាយាន ពិធីទេវ រាជនៅតែបានផ្សារភ្ជាប់គ្នាជាមួយរូបសំណាកលិង្គ។ រូបសំណាកលិង្គ អាចជួសជុលបានតែនៅ ក្នុងប្រាសាទដែលបានកសាងឡើងដោយស្តេចប៉ុណ្ណោះ ហើយមិនអាចផ្លាស់ទីបាន ក្រៅពី ដាក់នៅក្បែរស្តេចនោះទេ ដោយសារព្រះលិង្គ និងស្តេចមានទំនាក់ទំនងគ្នាទៅវិញទៅមក។

- **ការឯកភាពគោលបំណងរបស់ប្រព័ន្ធរៀបចំពិធីទេវរាជ**

សារៈសំខាន់ដំបូងរបស់ពិធីទេវរាជ ជាពិធីដាច់ដោយឡែកមួយដែលបានធ្វើឱ្យ ប្រទេសកម្ពុជាទទួលបានឯករាជ្យពីការគ្រប់គ្រងរបស់ជ្វា ជាការបង្កើតមណ្ឌលនិមិត្តសញ្ញាថ្មី មួយជំនួសឱ្យជ្វា ហើយបានស្របតាមមូលដ្ឋាន ដើម្បីជាមាគ៌ានៃការអភិវឌ្ឍបន្ថែមទៀតនៃ អាណាចក្ររបស់ស្តេចទេវរាជក្រោយៗទៀត។ ក្នុងពេលនោះដែរ ពិធីទេវរាជបានពាំនាំមកនូវ អត្ថន័យជាច្រើនដូចការ បង្កើតរដ្ឋថ្មីមួយ និងការផ្តួលរំលំការគ្រប់គ្រង ដោយមានភាពត្រឹមត្រូវ នៃច្បាប់របស់ព្រះមហាក្សត្រជាចំណែកនៅក្នុងនោះ។ ដូចដែលពេលវេលាបានជំរុញ ទោះជា យ៉ាងនេះក្តី អត្ថន័យផ្សេងទៀតជាច្រើនរបស់ពិធីទេវរាជលែងជាបញ្ហាចម្បងដែលត្រូវលើក ឡើង ហើយភាពស្របច្បាប់នៃការគ្រប់គ្រងរបស់ស្តេចបានលេចចេញជារូបរាងបន្តិចម្តងៗ សូម្បីតែគោលបំណងតែមួយគត់នៃពិធីសាសនា។ ទោះបីជាសម័យអង្គរជាសម័យកាលដែល ពោរពេញទៅដោយអំណាចខ្លាំងក្លាក៏ដោយ ក៏នៅតែមានការផ្លាស់ប្តូរអំណាច ជាមួយនឹងការ ដណ្តើមអំណាចព្រះមហាក្សត្រ មានទាំងព្រះមហាក្សត្រជាជនបរទេសផង និងស្តេចដែល បានជំនួសតំណែង និងសាសនាទាំងស្រុង តែយ៉ាងណាព្រះមហាក្សត្រគ្រប់អង្គត្រូវប្រឈម មុខនឹងបញ្ហាដូចគ្នា ក្នុងការបង្ហាញពីរបៀបកាន់អំណាចដ៏ត្រឹមត្រូវរបស់ព្រះអង្គ។ ព្រះមហា ក្សត្រត្រូវតែបង្ហាញអំពីភាពស្របច្បាប់នៃសមត្ថភាពរបស់ព្រះអង្គ ដែលបានមកពីទេពរបស់ ព្រះអង្គតាមរយៈអត្ថន័យនៃការប្រារព្ធពិធីសាសនា។ «នៅក្នុងសាសនានៅតំបន់អាស៊ី (អាស៊ី

អាគ្នេយ៍) (ព្រះពុទ្ធសាសនា) សម្រាប់ការជជែកគ្នាដំបូងអំពីទ្រឹស្តីនៃការរៀបចំរចនាសម្ព័ន្ធរដ្ឋ និងបានផ្សារភ្ជាប់ទៅនឹងភាពដ៏សំខាន់បំផុតគឺ ធម៌ ដែលបានផ្តល់ឱ្យរដ្ឋទាំងពីរគឺមូលដ្ឋាននៃការរួបរួមក្នុងសង្គម។...... វាបានចង្អុលបង្ហាញអ្វីដែលជាការគ្រប់គ្រង នៅក្នុងការយល់ឃើញជាទូទៅបំផុត ហើយចំណុចមួយគួរទទួលយកនោះគឺ អ្វីដែលជាចរិកលក្ខណៈបុគ្គលដែលពោរពេញដោយអត្ថន័យក្នុងពិភពលោកយើងនេះ។ តាមរយៈសាសនានេះដែរ គឺបានបង្ហាញនូវតួនាទីនៃសមត្ថភាពគ្រប់គ្រងរបស់ព្រះមហាក្សត្រនៅក្នុងនោះ ដោយគ្រងមរតកពីទេពរបស់ព្រះអង្គ និងបុព្វបុរសរបស់ទ្រង់ ដោយអត្ថន័យពិធីសាសនាលើសង្គមទាំងមូល ឬបុគ្គល[15]។ ដូចដែល លោក សុង លីតាវ បានអះអាងថា ព្រះពុទ្ធសាសនាបានគ្រប់គ្រងសង្គមយ៉ាងខ្លាំងនៅអាស៊ីអាគ្នេយ៍តាមរយៈគោលការណ៍ព្រះធម៌ ហើយព្រះមហាក្សត្រត្រូវប្រើប្រាស់កត្តាទាំងនេះដើម្បីបង្ហាញអំពីភាពជាស្តេចរបស់ព្រះអង្គ។

- **មួយវិញទៀតគឺ ស្ថេរភាពនៃប្រព័ន្ធការរៀបចំព្រាហ្មពុទ្ធទីបេ**

ក្រឡេកមើលទៅលើប្រវត្តិសាស្ត្រ អង្គរគឺជាសម័យកាលដែលមានអំណាចខ្លាំងក្លាបំផុតនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ជាមោទនភាពមួយដែលបានធ្វើឱ្យកម្ពុជាក្លាយជាប្រទេសតែមួយគត់ក្នុងពិភពលោកដែលមានរូបជាប្រវត្តិសាស្ត្រសម័យបុរាណនៅលើទង់ជាតិកម្ពុជា។ នៅពេលដែលគិតដល់អង្គរ នឹងយើងគិតដល់មហាអំណាចដ៏អស្ចារ្យ យើងនឹងនឹកឃើញពាក្យទាំងនេះគឺភាពរុងរឿង សន្តិភាព និងការអភិវឌ្ឍន៍។ ប៉ុន្តែនៅពេលដែលយើងក្រឡេកទៅមើលប្រវត្តិសាស្ត្រវិញ ឃើញថាមានផ្នែកខ្លះមានសភាពខ្មៅងងឹតទម្រាំប្រទេសមានសន្តិភាព។ ព្រះមហាក្សត្រដ៏សែនជោគជ័យរបស់អាណាចក្រអង្គរ។ ខ្លះជាស្តេចដែលជាជនបរទេស ជារឿយៗ បានកាត់ផ្តាច់ទំនាក់ទំនងរបស់ពួកទ្រង់ជាមួយអ្នកកាន់តំណែងមុនៗ ទៅតាមមធ្យោបាយផ្សេងៗដូចជា៖ ការបង្កើតទម្រង់ថ្មីទៀតរបស់រូបសំណាកលិង្គ, ការសាងសង់បរមរាជវាំង, ការបង្កើតរាជធានីថ្មីនៅក្នុងទីក្រុងឆ្ងាយៗ ហើយសូម្បីតែជំនឿសាសនាចាស់ក៏ត្រូវបានផ្តួលរំលំទាំងស្រុង

---

[15] Song Lidao, *Shensheng yu Shisu: Nanchuanfojiaoguojiadezongjiaoyuzhengzhi* (Divinity and Secularism: Religion and Politics in Theravada Buddhism Countries), Beijing: Press of Religions, 2000, p.3.

ហើយប្តូរទៅជាសាសនាថ្មី ទោះបីបន្ទាប់ពីនោះមានជម្លោះផ្ទៃក្នុងក៏ដោយ។ ព្រះមហាក្សត្រដ៏ជោគជ័យ បានជ្រើសរើសឱ្យមានការឡើងសោយរាជ្យរបស់ទ្រង់ ដោយមានព្រាហ្ម (បុព្វជិត) ជាអ្នកអនុវត្តការប្រារព្ធពិធី ហើយបុព្វជិត និងព្រះមហាក្សត្របានរួមគ្នាក្នុងពិធីទេវរាជ ដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការពិតដែលថាដំណើររឿងរបស់ក្រុមបុព្វជិតគឺជា ប្រធានបទយ៉ាងសំខាន់បំផុតក្នុងបរិបទបង្ហាញក្នុងពិធីទេវរាជ។ ពិធីទេវរាជមិនត្រឹមតែជា ច្បាប់គ្រប់គ្រងអំណាចប៉ុណ្ណោះទេ ប៉ុន្តែស្ត្រីនៅក្នុងរាជវាំង មន្ត្រីក្នុងសាល និងមនុស្សនៅខាងក្រៅប្រព័ន្ធតុលាការទាំងអស់គ្នាក៏បានរួមគ្នាក្នុងការបង្កើតទេវរាជនេះដែរ។ ថ្វីត្បិតបន្ទាប់ពីការលុកលុយរបស់សៀម អាណានិគមបារាំង និងពីរទសវត្សដ៏ច្របូកច្របល់ក៏ដោយ ក៏នៅតែមានវត្តមានរបស់ពិធីទេវរាជក្នុងការឡើងគ្រងរាជ្យរបស់ព្រះបាទនរោត្តមសីហមុនីនៅកម្ពុជាដែរ។ សក្ខីកម្មចំពោះការពិតមួយដែលលើកឡើងថា «ការឡើងសោយរាជ្យប្រហែលជាហួសសម័យ រួមទាំងក្បួនច្បាប់ផង ប៉ុន្តែអាជ្ញាធរនយោបាយនៅតែទាមទារឱ្យមានក្របខណ្ឌវប្បធម៌ដែលកំណត់ឱ្យច្បាស់លាស់ និងជំរុញការទាមទារ ហើយនិងភាពផ្ទុយគ្នានៅក្នុងនោះ។ ពិភពលោកទាំងមូលបានបកស្រាយថា ពិភពលោកទាំងមូលបានក្លែងបន្លំនយោបាយ...... អ្វីដែលបានបាត់បង់នៅឆ្នាំ១៧៩៣ (យោងតាមឯកសារាជានិយម) បានគឺជាទិដ្ឋភាពជាក់លាក់នៃទំនាក់ទំនងរវាងអំណាចរយៈពេលខ្លីដែលបំលាស់ទី និងការបំលាស់ទីរយៈពេលខ្លីនៅតំបន់ភ្នំមិនមែនមានន័យថាមានតែមួយនោះទេ»[16]។

ជាទីបញ្ចប់ ប្រព័ន្ធទេវរាជគឺជានយោបាយនិងសាសនា។ ប្រព័ន្ធទេវរាជមិនមែនជានៅក្នុងការអភិវឌ្ឍនៃប្រវត្តិសាស្ត្រ។ ក៏ប៉ុន្តែមានឥទ្ធិពលខ្លាំងមកពីឥណ្ឌា ចិន យូណាន ចេនឡា ចម្ប៉ា និងឥណ្ឌូណេស៊ី និងសូម្បីតែវប្បធម៌ផ្ទាំងថ្ម នៃអាស៊ីអាគ្នេយ៍ និងប៉មពីរ៉ាមីតនៃអាស៊ីបូព៌ា។ យោងទៅតាមទំនៀមទំលាប់របស់ឥណ្ឌា ស្តេចដែលប្រៀបធៀបខ្លួនទៅនឹងអាទិទេពនឹងត្រូវសហគមន៍ទាំងមូលចំអកថា មិនសមហេតុផល។ ប៉ុន្តែភាពពិសិដ្ឋ និងអាថ៌កំបាំងរបស់

---

[16] Clifford Geertz, *Local Knowledge: Further Essays in Interpretive Anthropology*, Basic Books, Inc., 1983, p.143.

ស្តេចនៅតែដើរតួនាទីនៅក្នុងស្ថាប័ននៃ Tirthankaras ដែលអំណាចនយោបាយត្រូវបានចងភ្ជាប់ជាមួយអាថ៌កំបាំងសាសនា ដែលអ្នកដឹកនាំនយោបាយសុទ្ធតែជាព្រះក្នុងកម្រិតផ្សេងៗគ្នា និងកន្លែងដែលពិសិដ្ឋលើសពីការផ្តល់ភាពស្របច្បាប់ដល់ការគ្រប់គ្រងនយោបាយ។ មានតួនាទីសំខាន់ជាងក្នុងការរក្សាការគ្រប់គ្រងនយោបាយឱ្យនៅជាប់នឹងសង្គម និងជាចំណុចស្នូលនៃសង្គម។ ទិដ្ឋភាពសំខាន់បំផុតនៃអំណាចព្រះ គឺវាកេងប្រវ័ញ្ចលើមនុស្ស វត្ថុ និងថាមពលនៃសង្គម ហើយបើគ្មានថាមពលទេសង្គមគឺជាគ្រាប់ខ្សាច់ដែលខ្ចាត់ខ្ចាយ មិនអាចបង្កើតកម្លាំងស្អិតរមួតបាន។ អំណាចដែលមានស្ថេរភាព និងចាស់ទុំទាមទារឱ្យមានការបង្កើតនូវអំណាចព្រះ ទោះក្នុងទម្រង់បែបណាក៏ដោយ។ «ការពាក់ព័ន្ធនៃការពិតប្រវត្តិសាស្ត្រសម្រាប់ការវិភាគសង្គមវិទ្យាមិនស្ថិតនៅលើការលើកឡើងដែលថាគ្មានអ្វីនៅក្នុងបច្ចុប្បន្ន មានតែនៅក្នុងអតីតកាល ដែលមិនមែនជាការពិត ឬការប្រៀបធៀបងាយៗមួយរវាងស្ថាប័នដែលបាត់បង់ និងរបៀបដែលយើងរស់នៅឥឡូវនេះ។ វាស្ថិតនៅលើការយល់ឃើញដែលថា ទោះបីជារចនាសម្ព័ន្ធ និងការបង្ហាញពីការផ្លាស់ប្តូរជីវិតក៏ដោយ ភាពចាំបាច់ខាងក្នុងដែលធ្វើឲ្យវាមិនមាន...... ភាពប្លែពីធម្មតាមិនបានចេញពីនយោបាយសម័យទំនើបទេ តែទោះជាយ៉ាងណាក៏ដោយ ភាពគ្មានន័យខ្លឹមសារប្រហែលជាបានបញ្ចូល, អំណាចមិនត្រឹមតែគ្រឿងស្រវឹងប៉ុណ្ណោះទេ ប៉ុន្តែនៅតែលើកតម្កើង»[17]។

[17] Ibid., pp.142-143.

**References**

1、Lawrence Palmer Briggs, *The Ancient Khmer Empire*, Philadelphia: The American Philosophical Society.

2、George Cœdès, The Indianized States of Southeast Asia, Honululu: University of Hawaii Press, 1996.

3、Clifford Geertz, *Negara: The Theatre State in Nineteenth-Century Bali*, Cambridge: Princeton Press, 1980.

4、Clifford Geertz, *Local Knowledge: Further Essays in Interpretive Anthropology*, Basic Books, Inc., 1983.

5、Hermann Kulke, *The Devaraja Cult* (tr. I.W.Mabbett), Ithaca: Cornell University Southeast Asia Programme, 1978.

6、I.W.Mabbett, "Devarāja", *Journal of Southeast Asian History*, Vol. 10, No. 2 (Sep., 1969), pp. 202-223.

7、Song Lidao, *Shensheng yu Shisu: Nanchuanfojiaoguojiadezongjiaoyuzhengzhi* (Divinity and Secularism: Religion and Politics in Theravada Buddhism Countries), Beijing: Press of Religions, 2000.

8、Zhang Hongyun, *Dongnanyashenwangwenhuayanjiu*(Research of God-King Culture in Southeast Asia), Beijing: Social Science Press of China, 2017.

# ជំនឿសាសនា

*បេក្ខជនបណ្ឌិត **ស៊ុំ សុខា***
*វគ្គ២ ជំនាន់២ មុខជំនាញ៖ រដ្ឋបាលសាធារណៈ*

## សេចក្ដីផ្ដើម

ក្នុងសង្គមមនុស្សទាំងមូល មានជំលោះទាស់ទែងគ្នា កាប់សម្លាប់គ្នា ធ្វើសង្គ្រាមប្រឆាំងគ្នាទៅវិញទៅមក ក៏ព្រោះតែការមិនចុះសម្រុងគ្នាផ្អែកមនោគមវិជ្ជា និង «ជំនឿសានា» នោះដែរ។ តាមការសិក្សាពីប្រវត្តិសាស្ត្រពិភពលោកបានបង្ហាញថា តាំងពីសម័យបុរេប្រវត្តិរហូតមកដល់បច្ចុប្បន្ន ជាពិសេសក្នុងមជ្ឈឹមសម័យ មនុស្សលោកភាគច្រើនជួបប្រទះនឹងវិបត្តិសង្គ្រាម ការកាប់សម្លាប់គ្នា ក៏ព្រោះតែយក «ជំនឿសាសនា» ជាមនោគមវិជ្ជាសម្រាប់ទាក់ទាញមហាជនឱ្យចូលរួមក្នុងសម្ព័ន្ធមិត្ត ឬ គាំទ្រទស្សនៈយុទ្ធសាស្ត្ររបស់ពួកគេ និង ដើម្បីបំណងរបស់ពួកគេ។ លោក កាណាតទី (Canatti) ដែលជាទេវវិទូដ៏ល្បីល្បាញមួយរូបជាតិអូទ្រីស បានធ្វើការសិក្សាយ៉ាងស៊ីជម្រៅបំផុតទៅលើជីវិត ជាពិសេសសិក្សាទៅលើដំណើរចុងបញ្ចប់នៃជីវិតរបស់មនុស្ស។ លោកបានធ្វើការសន្និដ្ឋានថា ក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ការបាត់បង់ជីវិតមនុស្សភាគច្រើន គឺស្ថិតនៅលើការកាប់សម្លាប់ដោយសង្គ្រាមបង្ហូរឈាមគ្នា និង បញ្ហាវិបត្តិផ្សេងៗទៀតរវាងមនុស្ស និង មនុស្ស ក៏ដោយសារតែការប្រកាន់យកមនោគមវិជ្ជា និង «ជំនឿសាសនា» នេះដែរ។ តាមទស្សនៈលោក សេចក្ដីស្លាប់គឺមិនមែនសំដៅទៅលើតែការបាត់បង់ជីវិតតែមួយមុខប៉ុណ្ណោះទេ ប៉ុន្តែ ក៏សំដៅផងដែរទៅលើការបាត់បង់អ្វីផ្សេងៗទៀត ដែលមនុស្សមាន និង ដែលមនុស្សត្រូវការនៅក្នុងជីវិត។ ដូចគ្នានេះដែរ ក្នុងទ្រឹស្ដីរបស់លោក ហានធីងតុន (Hantington) ជាតិអាល្លឺម៉ង់ បានឱ្យតម្លៃដែរថា គ្រោះថ្នាក់របស់មនុស្សលោក (សេចក្ដីស្លាប់) គឺស្ថិតនៅលើការជួបប្រទះគ្នារវាង «អារ្យធម៌ និង អារ្យធម៌» មានន័យថា វាក្យស័ព្ទ «អារ្យធម៌» មានពាក់ព័ន្ធទាំងស្រុងទៅនឹងផ្នែកជំនឿសាសនានេះផងដែរ។ [១]

## ១-ជំនឿ

### ១.១-អត្ថន័យទូទៅអំពីជំនឿ

«ជំនឿ» ជាបាតុភូតមួយ ដែលមានការចាប់អារម្មណ៍តាមបែបធម្មជាតិរបស់មនុស្ស។ គ្មាន «ជំនឿ» មនុស្សនឹងគ្មានជីវិតរស់នៅឡើយ ប៉ុន្តែ «ជំនឿ» គឺត្រូវតែមានគោលការណ៍ និង លក្ខខណ្ឌរបស់វា។ ការយល់ដឹងជាច្រើនត្រូវបានបង្កើតឡើងដោយផ្អែកនៅលើ «ជំនឿ» ឧទាហរណ៍ ការជឿទៅលើព្រះអាទិទេព ថាជាអង្គនិម្មិត ឬ ទិព្វពិភពលោកិយ និង មនុស្សផងទាំងពួងនៅលើផែនដី។ «ជំនឿ» គឺជាការជឿដោយអរូបី ដោយភាពអច្ឆរិយៈ។ ភាពអរូបី និង ភាពអច្ឆរិយៈ បានបង្កើតជាក្ដីសង្ឃឹមក្នុងជីវិតរស់នៅរបស់មនុស្សលោក។ ការរួបរួមគ្នារបស់មនុស្ស ភាគច្រើនឈរនៅលើ «ជំនឿ»

---

[១] ដកស្រង់ចេញពីគេហទំព័រ https://en.wikipedia.org/wiki/Belief, នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២

ប៉ុន្តែ វាក៏បានបង្កើតឱ្យសង្គមមួយមានលក្ខណៈយុត្តិធម៌ផង និង ភាពអយុត្តិធម៌ផងដែរប្រសិនបើពួកគេយកលក្ខខណ្ឌសាមគ្គីភាពបែបនេះ ធ្វើជាទិសដៅក្នុងការទទួលបាននូវដំណោះស្រាយអ្វីមួយនោះ។ និមិត្តសញ្ញាក្នុងការប្រមើលមើល ឬ ការអង្កេតមើលពី «ជំនឿ» ដែលមនុស្សជឿទៅលើនោះ គឺស្ថិតនៅលើបាតុភូតធម្មជាតិ បាតុភូតសង្គមជាដើម។

«ជំនឿ» ក៏អាចជាកម្មវិធីសង្គម សម្រាប់ទាក់ទាញប្រជាពលរដ្ឋក្នុងលទ្ធិប្រជាធិបតេយ្យ។ មូលដ្ឋានសំខាន់នៃលទ្ធិប្រជាធិបតេយ្យ គឺស្ថិតនៅលើការបោះឆ្នោតជ្រើសរើសជាមេដឹកនាំ រីឯអំណាចស្ថិតនៅលើប្រជាពលរដ្ឋ ព្រោះពួកគេជាអ្នកផ្តល់សន្លឹកឆ្នោតឱ្យ។ ដូច្នេះ ដើម្បីទទួលបានសន្លឹកឆ្នោតបេក្ខជន ឬ អ្នកនយោបាយ ត្រូវអនុវត្ត ឬ បំពេញកាតព្វកិច្ចយ៉ាងណា (ឃោសនា) ទៅលើសង្គមនោះឱ្យសក្តិសមទៅនឹងប្រពៃណី ទំនៀមទម្លាប់ និង ជំនឿសាសនារបស់ពួកគេ។[២]

## ១.២-ជំនឿបុគ្គល

មនុស្សម្នាក់ៗត្រូវការជាចាំបាច់នូវ «ជំនឿ»។ ជំនឿ គឺជាចំណីអារម្មណ៍បែបធម្មជាតិមួយរបស់មនុស្ស និង ស្ថិតក្នុងជីវភាពរស់នៅរបស់មនុស្ស ក្នុងភាពអមតៈរបស់ខ្លួន។ មនុស្សលោកគ្មាន «ជំនឿ» មានន័យថាគ្មានមនោគតិអ្វីទាំងអស់ និង គ្មានក្តីសង្ឃឹមក្នុងជីវិត ហើយបើកាលណាគ្មានក្តីសង្ឃឹមក្នុងជីវិត មនុស្សអាចប្រព្រឹត្តនូវអំពើអសីលធម៌គ្រប់បែបយ៉ាង។ នៅចំកណ្តាលប្រទេសអឺរ៉ុបមានពួកអ្នក «គ្មានជំនឿ» ជាច្រើន ប៉ុន្តែ ពួកនោះជឿទៅលើភាពសច្ចៈ[៣]។

## ១.៣-ជំនឿសង្គម

ជំនឿសង្គមគឺជា «ជំនឿ» មានលក្ខណៈជាស្មារតីរួម ស្មារតីសង្គម។ «ជំនឿ» រួមបែបនេះ អាចចាត់ចូលជា «ជំនឿបែបនយោបាយ» ព្រោះថា ការជឿទៅលើអ្វីមួយជាលក្ខណៈរួម វាបានបង្កើតឱ្យមានស្មារតីសង្គម មនសិការនៃក្រុម បក្ខពួក ជាតិ ឬ ក្រុមកុលសម្ព័ន្ធណាមួយ ហើយក្រុមទាំងនោះបានពូនកម្លាំងបង្រួបបង្រួមគ្នាជាធ្លុងមួយ ក្រោមជំនឿសាសនា ឬ មនោគមវិជ្ជាណាមួយ ដើម្បីការពារនូវទស្សនៈរួម មនោគតិរួម និង ការពារនូវសម្ព័ន្ធមិត្តរបស់ពួកគេ។ ដូច្នេះ ការប្រឆាំង ឬ ការរំលោភទៅលើសាសនារបស់ពួកគេ ហាក់បីដូចជាការប្រមាថទៅលើ «ដួងព្រលឹង» របស់ក្រុម បក្ខពួក ឬ សញ្ជាតិរបស់ពួកគេនោះដែរ។ «ជំនឿ» លក្ខណៈសកលបែបនេះ បានបង្កើតឱ្យមានខ្លឹមសារជាមនោគតិរួមនៅក្នុងស្មារតីស្នេហាជាតិ និង ភាពជាតិនិយមជាដើម[៤]។ ក្នុងការសិក្សាពីចិត្តសាស្ត្រមនុស្សលោកបានបង្ហាញឱ្យឃើញថា ទោះបីជាបុគ្គលនោះ ឬ ក្រុមបក្ខពួកនោះ មិនមាន «ជំនឿ» ទាំងស្រុងទៅលើសាសនាណាមួយនៃជាតិរបស់ពួកគេយ៉ាងណាក៏ដោយ ក៏ឥទ្ធិពលនៃសាសនារបស់ជាតិនោះតែងមានឥទ្ធិពលខ្លាំងទៅលើបុគ្គលនោះជាក្រឹត្យក្រម។ ក្នុងដំណើរការណ៍នយោបាយ «ជំនឿសាសនា» តែងតែមានលក្ខណៈលាយឡំគ្នាក្នុងទង្វើនយោបាយ ការដឹកនាំរដ្ឋដោយយក «ជំនឿសាសនា» ជា

---

[២]ដកស្រង់ចេញពីគេហទំព័រ https://en.wikipedia.org/wiki/Belief, -ដ.ឯ.ម-

[៣] -ដ-

[៤]-ដ-

យាន ឧទាហរណ៍ «ប្រទេសឥណ្ឌា» ជាទីកំណើតនៃការចាប់បដិសន្ធិព្រះពុទ្ធសាសនា ប៉ុន្តែ រហូតមកដល់សព្វថ្ងៃ ព្រះពុទ្ធសាសនាពុំមានការរីកចម្រើនឡើយ ដោយលទ្ធិព្រហ្មញ្ញគ្របដណ្តប់ ឬ ដោយសារឥស្លាមសាសនាចូលមកលប់បំបាត់នៅសតវត្សរ៍ទី៨-៩។ នៅសម័យអាណានិគមចាប់ពីសតវត្សរ៍ទី១៦ រហូតដល់ទី២០ ក្នុងពិភពលោក សាវ័កគ្រិស្តបានដើរតួយ៉ាងសំខាន់ក្នុងការស្វែងរកប្រទេសដាក់ក្រោមចំណុះរបស់ខ្លួន ដោយជាដំបូង ចំណុះបែបលក្ខណៈ «ជំនឿ» ហើយបន្ទាប់មកទៀត ជាលក្ខណៈនយោបាយ។

**រចនាសម្ព័ន្ធនៃសាសនាធំៗក្នុងពិភពលោក**




*ដកស្រង់ចេញពីគេហទំព័រ* https://en.wikipedia.org/wiki/World_religions, *ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១*

# ២-សាសនា

## ២.១-និយមន័យអំពីសាសនា

«សាសនា» គឺជាលទ្ធិអមតៈនៅក្នុងសង្គមមនុស្ស។ «សាសនា» កើតចេញពីព្រះអាទិទេពពីភាពអច្ឆរិយៈ។ តាមធម្មជាតិ «សាសនា» មិនមែនជាការងាររបស់មនុស្សលោកនោះទេ ប៉ុន្តែ ជាកិច្ចការរបស់ព្រះ (អាទិទេពវិចារណញ្ញាណ)។ «សាសនា» គឺជាទំនៀមដែលកើតចេញពីការឆ្លុះបញ្ចាំងអំពីភាពវើរវាយរបស់មនុស្ស ទៅលើទិដ្ឋភាពទូទៅនៃពិភពលោកិយ។ «សាសនា» ផ្សំឡើងដោយទម្រង់ជីវទស្សន៍ ពោល គឺការពូតផ្គុំនៃប្រាជ្ញារបស់មនុស្ស។ ការអធិដ្ឋាន, សមាធិ, ការលះបង់ ។ល។ គឺជាធាតុផ្សំចាំបាច់មួយ នៅក្នុងទម្រង់នៃទំនាក់ទំនងរវាងព្រះអាទិទេព និង មនុស្សលោក។ វិន័យ, ក្រមសីលធម៌, និង វិធានទាំងឡាយក្នុងច្បាប់សាសនា ត្រូវបានមនុស្សចាត់ទុកថាជាក្រិត្យក្រម

ដែលព្រះកំណត់ឱ្យ ហើយលក្ខខណ្ឌទាំងនោះ វាបានកំណត់ឱ្យមនុស្សមានអត្តចរិត និង ចរិយាធម៌ថ្លៃថ្នូរនៅក្នុងសង្គមរបស់ខ្លួន។

តាមវចនានុក្រមខ្មែរ ភាគ១ និង ភាគ២ របស់សម្តេចព្រះសង្ឃរាជ ជួន ណាត ច្បាប់បោះពុម្ពផ្សាយក្នុងគ្រាទី៥ របស់ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៨ បានពន្យល់ន័យនៃពាក្យ «សាសនា» នេះថា គឺជាពាក្យប្រើក្លាយមកពីពាក្យ «សាសន» ហើយដែលពាក្យ «សាសន» នេះ មានប្រភពមកពីពាក្យបាលី និង សំស្ក្រឹត មានន័យថាជា *«ពាក្យបណ្តាំ, ពាក្យផ្តាំផ្ញើ; ពាក្យប្រៀនប្រដៅ, ការប្រៀនប្រដៅ; សាសនា, លទ្ធិ*...។ល។[៥]

តាមសព្វវចនាធិប្បាយព្រីតាននីកា ស្តីអំពី សាសនា (Britannica Encyclopedia of World Religions) ត្រង់និយមន័យនៃសាសនា (Religions, Definition of,)[៦] បានអធិប្បាយថា ការប៉ុនប៉ងណាមួយ ដើម្បីបង្កើតការពិពណ៌នាអំពីសាសនាដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់គ្រប់សាសនាទាំងអតីតកាល និង បច្ចុប្បន្នកាល ភាគច្រើនសង្កត់ធ្ងន់លើការលំបាកក្នុងការកំណត់ន័យឱ្យពាក្យ «សាសនា» នេះ ហើយបន្ទាប់មក បន្ថែមនិយមន័យយ៉ាងសម្រិតសម្រាំងអំពីបញ្ហាសាសនា។ តាមពិតការកំណត់ន័យឱ្យពាក្យ «សាសនា» មិនពិបាកទាល់តែសោះ។ អត្ថបទទាំងនោះ បង្ហាញតែអំពីថាមានការព្រមព្រៀងតិចតួចក្នុងចំណោមអ្នកប្រាជ្ញ ដែលនិយមន័យរបស់ពួកគេ ឆ្លុះបញ្ចាំងតែពីចំណាប់អារម្មណ៍ជាក់លាក់របស់ពួកគេប៉ុណ្ណោះ ដូចជា និយមន័យនៃសាសនាដែលកំណត់ថា សាសនាជាតំណាងនៃទំនាក់ទំនងសង្គម នោះគឺច្បាស់ជាមានឫសគល់នៅក្នុងវិទ្យាសាស្ត្រសង្គម។ ប្រសិនបើមនុស្សម្នាក់ចាប់អារម្មណ៍លើចិត្តវិទ្យា មនុស្សនោះមុខជាកំណត់សាសនា ថាជានិមិត្តរូបនៃតថភាពខាងផ្លូវចិត្តរបស់ខ្លួនដោយមិនដឹងខ្លួន។ ប្រសិនបើមនុស្សម្នាក់ មានការទោរទន់ចិត្តច្រើនទៅលើទេវវិទ្យា (theology) ឬ ទៅលើបរមត្ថវិជ្ជា (metaphysic) នោះ មនុស្សនោះអាចអន្ទោកអន្ទោលឱ្យកំណត់សាសនាថាជាភាពខ្ពង់ខ្ពស់បំផុត ជាអារម្មណ៍ឯករាជដាច់ខាត ឬ ជាតំណាងនៃភាពពិសិដ្ឋ។ ដោយសារនិយមន័យពីរដំបូងគឺអាស្រ័យលើទ្រឹស្តីនៃសាសនា ភាពគ្រប់គ្រាន់នៃទ្រឹស្តីសង្គមវិទ្យា ឬ ចិត្តវិទ្យាដែលពាក់ព័ន្ធ នឹងកំណត់ពីភាពគ្រប់គ្រាន់នៃនិយមន័យ។ ចំពោះនិយមន័យនៃទេវវិទ្យា និង បរមត្ថវិជ្ជាសំដៅទៅលើតថភាពដ៏អាថ៌កំបាំងនោះ មធ្យោបាយសម្រាប់ពិនិត្យមើលភាពគ្រប់គ្រាន់របស់ពួកគេគឺមានភាពខ្វះខាត។ បើយើងទទួលយកពួកគេក៏ដោយសារជំនឿ ឬ ដោយសារការប្តេជ្ញាចិត្តចំពោះប្រពៃណីមួយប៉ុណ្ណោះ។ [៧]

## ២.២-អត្ថន័យសាសនាតាមទស្សនាទាននៃសាសនទិទ្ធនានា

តាមទស្សនៈទេវៈវិទូ «សាសនា» គឺជា «យាន» ទំនាក់ទំនងរបស់មនុស្សទៅនឹងប្រភពនៃការចាប់បដិសន្ធិលោកិយ។ នៅក្នុងការបង្រៀនបែបគ្រិស្តសាសនាអូតូដុក បានពន្យល់អំពីភាពខុសគ្នារវាង «ចំណេះដឹងពីព្រះ» (ចំណេះបានទទួលបានពីព្រះ) និង «ចំណេះដឹងរបស់ព្រះ» (ចំណេះដឹងបែប

---

[៥] ជួន ណាត, *«វចនានុក្រមខ្មែរ ភាគទី១- ភាគទី២»*, បោះពុម្ពគ្រាទី៥, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ឆ្នាំ១៩៦៨, ទំព័រ១៣៥៤

[៦] SAFRA E. Jacob and CAUZ-Aguilar Jorge, "***Encyclopedia of World Religions***", Published by Encyclopedia Britannica, Inc., USA, UK, India, France, Korea, Australia, Taiwan, Japan, 2006, Page: 915-916

[៧] SAFRA E. Jacob and CAUZ-Aguilar Jorge, "***Encyclopedia of World Religions***", Op. Cit.,

ព្រះ) ដូច្នេះ មនុស្សអាចសិក្សាពីគម្ពីរ ហើយអាចទទួលបានចំណេះដឹងពីអ្វីដែលនៅក្នុងព្រះវិហារ។ ការពន្យល់ពីបាតុភូតនាំឱ្យកើតមាននូវ «សាសនា» តាមការសិក្សាបែបទស្សនវិជ្ជា បានឱ្យតម្លៃថា «សាសនា» គឺជាទិដ្ឋិភាពគតិបណ្ឌិតរបស់មនុស្ស ដែលមានប្រាជ្ញាខ្ពស់បំផុតពីធម្មជាតិ និង កំណើតជីវិតមនុស្សនោះប្រកបទៅដោយភាពអាថ៌កំបាំង ហើយកំណើតរបស់ពួកគេ ផ្សំទៅដោយជីវសរីរាង្គ (ធាតុ) ដែលមានគុណភាពខ្ពស់បំផុត។ ក្នុងវិទ្យាសាស្ត្រ ទស្សនវិជ្ជាបានទាត់ចោលនូវអ្វីដែលជាភាពអច្ឆរិយៈ និង អ្វីដែលចាត់ទុកថាជាអារម្មណ៍និម្មិតសច្ចៈរបស់មនុស្ស ឬ អារម្មណ៍ទទួលបានដោយគ្មានបទពិសោធន៍។ [៨]

និយមន័យភាគច្រើនអំពីពាក្យ «សាសនា» មិនមានប្រយោជន៍ច្រើនទេ ព្រោះវាមានភាពស្រពិចស្រពិល ឬ មិនច្បាស់លាស់។ ជាឧទាហរណ៍, ឧបមាថាសាសនាត្រូវបានគេកំណត់ថាជា «ទស្សនៈពិភពលោក (worldview)»; តើ «ទស្សនៈពិភពលោក (worldview)» ទាំងអស់សុទ្ធតែជាសាសនាឬ? ប្រសិនបើដូច្នេះមែន វាហាក់ដូចជាថាអ្វីៗក៏អាចក្លាយជាសាសនាបានដែរ។ ស្រដៀងគ្នានេះដែរ ប្រសិនបើសាសនាត្រូវបានគេកំណត់ថាជា «កង្វល់ដ៏ខ្ពង់ខ្ពស់បំផុត (ultimate concern)» តើសេចក្តីខ្វល់ខ្វាយទៅលើការកាន់កាប់ការងារ គឺសុទ្ធតែជាសាសនាដែរឬ? ប្រសិនបើសាសនាត្រូវបានកំណត់ថាជា «ភាពពិសិដ្ឋ» សំណួរដែលជាធម្មតាត្រូវបានសួរគឺថា «តើអ្វីទៅដែលជាភាពពិសិដ្ឋនោះ?» សញ្ញាប្រាកដដែលកំណត់និយមន័យនោះ គឺមិនមានប្រយោជន៍ខ្លាំងក្លាណាស់ណានោះឡើយ។ [៩]

និយមន័យផ្សេងទៀតអំពីពាក្យ «សាសនា» គឺហាក់ដូចជារឹតត្បិតពេក ហើយនិយមន័យដែលថា «សាសនា» គឺមានន័យថាជា «ជំនឿលើព្រះ» គឺជាឧទាហរណ៍ដ៏ល្អមួយ។ ទោះបីជាវារួមបញ្ចូលនូវសាសនាឯកាទិទេពនិយម (monotheism) ទាំងអស់ក៏ដោយ តែវាមិនបានរាប់បញ្ចូលសាសនានូវសាសនាពហុទេវនិយម (polytheism) ទាំងអស់នោះដែរហើយ សាសនាទាំងនោះដែលមិនជឿលើព្រះទៀតផង។ ការកំណត់និយមន័យ «សាសនា» ថាជាជំនឿលើ «អធិធម្មជាតិ (supernatural)» ឬក៏តថភាព «អាថ៌កំបាំង (transcendental)» ក៏មានកម្រិតផងដែរ ចាប់តាំងពីវប្បធម៌ខ្លះបដិសេធនូវតថភាពបែបនេះ។ ឧទាហរណ៍ទាំងនេះ គឺជាភស្តុតាងជាក់ស្តែងដែលលើកឡើងបង្ហាញដើម្បីសាកល្បងពីភាពគ្រប់គ្រាន់នៃនិយមន័យនៃសាសនារបស់យើង។ [១០]

និយមន័យដែលទទួលយកបានដោយសមហេតុផល គឺមាននៅក្នុងចំណោមទ្រឹស្តីអ្នកប្រាជ្ញដែលមានដូចជាថា សាសនាគឺជាប្រព័ន្ធនៃជំនឿសហគមន៍ និង ការអនុវត្តទាក់ទងនឹងមនុស្សអស្ចារ្យ (superhuman) និយមន័យនេះឃ្លាតឆ្ងាយពីការកំណត់សាសនាថាជា «ទស្សនៈពិភពលោក» ឬ ជា «បទពិសោធន៍ពិសេសមួយចំនួន»។ វាសង្កត់ធ្ងន់ថា «សាសនា» គឺជាប្រព័ន្ធសហគមន៍ ឬ រចនាសម្ព័ន្ធដែលទាក់ទងនឹងមនុស្សអស្ចារ្យ។ មនុស្សអស្ចារ្យ គឺជាអ្នកដែលអាចធ្វើអ្វីដែលមនុស្សធម្មតាមិនអាចធ្វើបាន។ អំណាចអព្ភូតហេតុរបស់ពួកគេ បានធ្វើឲ្យពួកគេមានភាពខុសប្លែកដាច់ពីមនុស្សធម្មតា។ ពួកវាអាចជាប្រុស ឬ ស្រី ឬ អាចជាប្រុសផងស្រីផង ហើយពួកគេអាចជាបុព្វបុរស, ព្រះអាទិទេព,

---

[៨] ដកស្រង់ចេញពីគេហទំព័រ https://en.wikipedia.org/wiki/Religion, -ដ.ឯ.ម-

[៩] SAFRA E. Jacob and CAUZ-Aguilar Jorge, "***Encyclopedia of World Religions***", Op. Cid.,

[១០] Ibid.,

ទេពធីតា ឬ ក៏ជាអារក្ខអ្នកតាជាដើម។ ពួកគេជាមនុស្សស្លូតបូត ឬ ជាអ្នកដែលមានចិត្តសប្បុរស ឬជាមនុស្សស្លូតបូតហើយមានចិត្តសប្បុរសទៀតផង។ អ្វីដែលសំខាន់ គឺការទាក់ទងទៅនឹងអាទិទេព ទៅនឹងជំនឿនិងការអនុវត្តសហគមន៍ជាក់លាក់, ទេវកថា និង ពិធីសាសនារបស់មនុស្សជាក់លាក់។ និយមន័យនេះ មិនរាប់បញ្ចូលលទ្ធិណាហ្ស៊ី, លទ្ធិម៉ាក្សនិយម, លទ្ធិមនុស្សនិយម, និង លទ្ធិសាសនាផ្សេងទៀត រួមទាំងលទ្ធិជាតិនិយម និង ចលនាពាក់កណ្ដាលសាសនាផ្សេងទៀតនោះដែរ។ លើកលែងតែភាពតានតឹងរបស់វាលើប្រព័ន្ធ ឬ រចនាសម្ព័ន្ធចេញ គឺនិយមន័យនេះមានលក្ខណៈអព្យាក្រឹតតាមទ្រឹស្ដី និង អាចផ្ទៀងផ្ទាត់បានដោយជាក់ស្ដែង។ [១១]

ជាងនេះទៀត ទាក់ទងនឹង «សាសនា» មានប្រភពចេញមកពីណានោះ គឺត្រូវបានអ្នកទ្រឹស្ដីកំពូលៗនាសតវត្សរ៍ទី២០ មានជាអាទិ៍ សេដ្ឋវិទូ និង ប្រវត្តិវិទូកាលម៉ាក្ស (Karl Marx)[១២], សង្គមវិទូ អេមីល ឌើកឃៀម (Émile Durkheim)[១៣] និង ចិត្តវិទូ ស៊ីយម៉ាន់ ហ្វ្រើដ (Sigmund Freud)[១៤] ចាប់អារម្មណ៍ និង ធ្វើការសិក្សាវិភាគយ៉ាងផុលផុស ព្រោះ ដំណើរស្វែងរកនេះ ទាក់ទងដោយផ្ទាល់ទៅនឹងការស្វែងរកអត្ថន័យនៃសាសនា។ ប្រសិនបើគេអាចកំណត់ប្រភពដើមនៃសាសនាបាន នោះគេនឹងអាចកំណត់អត្ថន័យរបស់វាបាន។ ដូច្នេះ សម្រាប់ចិត្តវិទូ ស៊ីយម៉ាន់ ហ្វ្រើដ (Sigmund Freud) ប្រភពដំបូងនៃសាសនាគឺ «អំពើ» សាសនាបានរីកចម្រើនចេញពីបទពិសោធន៍ជុំវិញសកម្មភាពបឋមមួយចំនួន។ សម្រាប់ សង្គមវិទូ អេមីល ឌើកឃៀម (Émile Durkheim) វិញ មានទស្សនៈថា គឺជាការលេចចេញនូវ «ភាពប្រមូលផ្ដុំខាងសតិសម្បជញ្ញៈ» ដូចដែលសង្គមខ្លួនឯងបានធ្វើនូវនិមិត្តសញ្ញាសក្ការៈ និង ជាទម្រង់តូតែម (totemic) ដូច្នោះដែរ។ សម្រាប់នរវិទូ ស៊ឺរ អេដវ៉ាដ បើណេតត៍ ថៃល័រ (Sir Edward Burnett Tylor)[១៥] បានលើកឡើងបង្ហាញថា ប្រភពដើមនៃសាសនា គឺត្រូវបានរកឃើញនៅក្នុងការប៉ុនប៉ងរបស់មនុស្សដំបូង ដើម្បីពន្យល់នូវបទពិសោធន៍។ សម្រាប់អ្នកប្រាជ្ញផ្សេងទៀតជំនឿលើអធម្មជាតិនិយម (Mysticism) គឺជាប្រភពដើម ជាការពិត ជាខ្លឹមនៃសាសនា។ [១៦]

តាមអត្ថន័យសាកល ពាក្យ «សាសនា» នេះ ត្រូវនឹងពាក្យអង់គ្លេស ឬ បារាំងថា «Religion» ជាពាក្យមានប្រភពមកពីឡាតាំងថា «religionem» ដែលមានន័យថា *«ការគោរពចំពោះអ្វីដែលពិសិដ្ឋ, ជាគុណភាពចំពោះព្រះ, ជាការយល់ត្រូវ, ជាកាតព្វកិច្ចខាងសីលធម៌ និង ជាភាពស័ក្ដិសិទ្ធ»*។ តាម

---

[១១] SAFRA E. Jacob and CAUZ-Aguilar Jorge, "***Encyclopedia of World Religions***", Op. Cid.,

[១២] លោក កាល់ ម៉ាក្ស (Karl Heinrich Marx) កើតនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៨១៨ និង ទទួលមរណភាពនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ១៨៨៣ គឺជាទស្សនវិទូ, ជាសេដ្ឋវិទូ, ប្រវត្តិវិទូ, សង្គមវិទូ ជាតិអាឡឺម៉ង់... ព័ត៌មានលម្អិតពីលោក កាល់ ម៉ាក្ស (Karl Heinrich Marx) នេះ សូមចូលអាននៅក្នុងគេហទំព័រ https://en.wikipedia.org/wiki/Karl_Marx។

[១៣] លោក អេមីល ឌើកឃៀម (David Émile Durkheim) កើតនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៨៥៨ និង ទទួលមរណភាពនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩១៧ គឺជាសង្គមវិទូជាតិបារាំង... ព័ត៌មានលម្អិតពីលោក អេមីល ឌើកឃៀម (David Émile Durkheim) នេះ សូមចូលអាននៅក្នុងគេហទំព័រ https://en.wikipedia.org/wiki/%C3%89mile_Durkheim។

[១៤] លោក ស៊ីយម៉ាន់ ហ្វ្រើដ (Sigmund Freud) កើតនៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៨៥៦ និង ទទួលមរណភាពនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៣៩ គឺជាចិត្តវិទូជាតិអូទ្រីស... ព័ត៌មានលម្អិតពីលោក ស៊ីយម៉ាន់ ហ្វ្រើដ (Sigmund Freud) សូមអាននៅក្នុងគេហទំព័រ https://en.wikipedia.org/wiki/Sigmund_Freud។

[១៥] លោក ស៊ឺរ អេដវ៉ាដ បើណេតត៍ ថៃល័រ (Sir Edward Burnett Tylor FRAI) កើតនៅថ្ងៃទី០២ ខែតុលា ឆ្នាំ១៨៣២ និង ទទួលមរណភាពនៅថ្ងៃទី០២ ខែមករា ឆ្នាំ១៩១៧ គឺជានរវិទូជាតិអង់គ្លេស... ព័ត៌មានលម្អិតពីលោក ស៊ឺរ អេដវ៉ាដ បើណេតត៍ ថៃល័រ (Sir Edward Burnett Tylor FRAI) នេះ សូមអាននៅក្នុងគេហទំព័រ https://en.wikipedia.org/wiki/Edward_Burnett_Tylor។

[១៦] SAFRA E. Jacob and CAUZ-Aguilar Jorge, "***Encyclopedia of World Religions***", Op. Cid.,

ទស្សនៈរបស់លោក ស៊ីសេរ៉ូ (Cicero)[១៧] យល់ថា «*សាសនា*» គឺជាការអាន ឬ សូធ្យតាម (lego read) ម្ដងហើយម្ដងទៀត ប្រកបដោយការយកចិត្តទុកដាក់, គឺជាការគោរពបូជាចំពោះព្រះអាទិទេព, ការសម្ដែងដោយភាពត្រឹមត្រូវនៃពិធីសាសនា ក្នុងការគោរពបូជាដល់ព្រះអាទិទេព។ [១៨] ចំណែក លោក ជូលៀស សេសា (Julius Caesar)[១៩] វិញមានទស្សនៈថា ពាក្យ «សាសនា» មានន័យថា «*ជាកាតព្វកិច្ចនៃពាក្យសម្បថ*» ដែលពាក្យនេះ គេឃើញប្រើនៅក្នុងកិច្ចពិភាក្សាអំពីទាហានដែលត្រូវបានចាប់ខ្លួន រួចហើយ គេក៏បានឱ្យពួកទាំងនោះធ្វើសម្បថ។ [២០] ចំណែកធម្មជាតិវិទូ ភ្លីនី ឌិ អែលឌ័រ (Pliny the Elder)[២១] វិញយល់ថា ពាក្យ «*សាសនា*» នេះ ត្រូវបានគេប្រើនៅលើសត្វជំរី ក្នុងខណៈដែលពួកគេធ្វើពិធីសក្ការបូជាទៅដល់ព្រះអាទិត្យ និង ព្រះច័ន្ទ។ [២២] អ្នកប្រាជ្ញសម័យទំនើបដូចជាលោក ថម ហាប់ភើ (Tom Harpur)[២៣] និង លោក ចូសេប ចន ខេមបល (Joseph John Campbell)[២៤] មានចំណូលចិត្តលើការទាញយកពីការចងផ្លូវ, ការតភ្ជាប់... ដែលចំណូលចិត្តនេះ ត្រូវបានធ្វើឱ្យលេចធ្លោឡើងដោយលោក អូហ្គូស្ទីន អហ្វ ហ៊ីបផូ (Augustine of Hippo)[២៥] ហើយក្រោយមក បំណកស្រាយដែលបានផ្ដល់ដោយ លោក ឡេកថេនធៀស (Lactantius)[២៦] តាមរយៈស្នាដៃមួយ មានចំណង

---

[១៧] លោក ស៊ីសេរ៉ូ (Cicero) ជាទស្សនវិទូជាតិរ៉ូម៉ាំង មានឈ្មោះពិតប្រាកដថា Marcus Tullius Cicero លោកកើតនៅថ្ងៃទី០៣ ខែមករា ឆ្នាំ១០៦ និង ទទួលមរណភាពនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ៤៣មុនគ្រិស្តសករាជ... ព័ត៌មានលម្អិតពីលោក ស៊ីសេរ៉ូ (Cicero) នេះ សូមអាននៅក្នុងគេហទំព័រ https://en.wikipedia.org/wiki/Cicero។

[១៨] វីគីពីឌា (Wikipedia), «សាសនា (***Religion***), ដកស្រង់ចេញពីគេហទំព័រ https://en.wikipedia.org/wiki/Religion, នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២

[១៩] លោក ជូលៀស សេសា (Julius Caesar) ជារដ្ឋបុរស និង ឧត្ដមសេនីយ៍រ៉ូម៉ាំង មានឈ្មោះពិតប្រាកដថា Gaius Julius Caesar លោកកើតនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ១០០ និង ទទួលមរណភាពនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ៤៤មុនគ្រិស្តសករាជ... ព័ត៌មានលម្អិតពីលោក ជូលៀស សេសា (Julius Caesar) នេះ សូមអាននៅក្នុងគេហទំព័រ https://en.wikipedia.org/wiki/Julius_Caesar។

[២០] វីគីពីឌា (Wikipedia), «សាសនា (***Religion***), -ដ.ឯ.ម-

[២១] លោក ភ្លីនី ឌិ អែលឌ័រ (Pliny the Elder) មានឈ្មោះពិតថា Gaius Plinius Secundusលោកកើតនៅឆ្នាំ២៣/២៤ និង ទទួលមរណៈភាពនៅក្នុងឆ្នាំ៧៩ នៃគ្រិស្តសករាជ គឺជាអ្នកនិពន្ធជនជាតិរ៉ូម៉ាំង អ្នកធម្មជាតិនិយម និង ទស្សនវិទូធម្មជាតិ និងជាមេបញ្ជាការកងទ័ពជើងទឹក និងកងទ័ពនៃចក្រភពរ៉ូមដំបូង... ព័ត៌មានលម្អិតពីលោក ភ្លីនី ឌិ អែលឌ័រ (Pliny the Elder) នេះ សូមអាននៅក្នុងគេហទំព័រ https://en.wikipedia.org/wiki/Pliny_the_Elder។

[២២]វីគីពីឌា (Wikipedia), «សាសនា (***Religion***), -ដ.ឯ.ម-

[២៣] លោក ថម ហាប់ភើ (Tom Harpur) ឈ្មោះពិតថា Thomas William Harpur លោកកើតនៅក្នុងឆ្នាំ១៩២៩ និង ទទួលមរណភាពនៅក្នុងឆ្នាំ២០១៧ គឺជាអ្នកប្រាជ្ញព្រះគម្ពីរជនជាតិកាណាដា និងជា បូជាចារ្យ (Anglican) ដែលត្រូវបានតែងតាំងជាអ្នកគាំទ្រទ្រឹស្ដីទេវកថារបស់ព្រះគ្រីស្ទ ... ព័ត៌មានលម្អិតពីលោក ថម ហាប់ភើ (Tom Harpur) នេះ សូមចូលអាននៅក្នុងគេហទំព័រ https://en.wikipedia.org/wiki/Tom_Harpur។

[២៤] លោក ចូសេប ចន ខេមបល (Joseph John Campbell) កើតនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩០៤ និង ទទួលមរណភាណនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៨៧ គឺជាអ្នកនិពន្ធជនជាតិអាម៉េរិក ជាសាស្ត្រាចារ្យផ្នែកអក្សរសាស្ត្រនៅមហាវិទ្យាល័យ Sarah Lawrence និងបានសរសេរនូវស្នាដៃ ទេវកថាប្រៀបធៀប និង សាសនាប្រៀបធៀប។ ស្នាដៃរបស់លោក បានគ្របដណ្ដប់ទិដ្ឋភាពជាច្រើននៃបទពិសោធន៍របស់មនុស្ស... ព័ត៌មានលម្អិតពីលោក ចូសេប ចន ខេមបល (Joseph John Campbell) នេះ សូមចូលអាននៅក្នុងគេហទំព័រ https://en.wikipedia.org/wiki/Joseph_Campbell។

[២៥] ព័ត៌មានពីលោក «***អូហ្គូស្ទីន អហ្វ ហ៊ីបផូ (Augustine of Hippo)***» នេះ ដកស្រង់ចេញពីគេហទំព័រ https://en.wikipedia.org/wiki/Augustine_of_Hippo, នៅ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០។

[២៦] ព័ត៌មានពីលោក «***ឡេកថេនធៀស (Lactantius)***» នេះ ដកស្រង់ចេញពីគេហទំព័រ https://en.wikipedia.org/wiki/Lactantius, នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០។

ជើងថា «គ្រឹះស្ថានព្រះអាទិទេព» នោះ។ ការប្រើប្រាស់នៅមជ្ឈិមសម័យ គឺបានផ្លាស់គ្នាជាមួយនឹងរបៀបរៀបរយក្នុងការបង្កើតសហគមន៍ ដែលមានសម្ព័ន្ធភាពជាមួយនឹងបណ្ដារបៀបរៀបរយនៃវត្តអារាមនានា ក្នុងនោះ គេបានឮពាក្យមួយចំនួននៅក្នុងវិន័យសាសនា ដូចជា «ផ្កាកបញ្ចាមាស (Golden Fleece)» និង ពាក្យ «អប្បបូទ្ធិ (knight) ជាដើម។ [២៧]

ដោយភាពទូលំទូលាយ «សាសនា» គឺជាអ្វីមួយដែលត្រឹមត្រូវ ឬ គោលលទ្ធិ។ និយមន័យចំពោះពាក្យ «សាសនា» នេះ គឺត្រូវបានកំណត់នៅក្នុងលក្ខខណ្ឌនៃជំនឿ ដែលមនុស្សបានប្រកាន់យកយ៉ាងខ្ជាប់ខ្ជួន ហើយនឹងអ្វីដែលមនុស្សបានទទួលយកមកបដិបត្តិយ៉ាងខ្ជាប់ខ្ជួនចំពោះសាសនានោះ។ «សាសនា» ជាទូទៅត្រូវបានកំណត់នៅក្នុងលក្ខខណ្ឌនៃជំនឿរបស់សាសនានោះ ហើយដែលនិយាយឱ្យងាយគឺការចែករំលែក។ «សាសនា» គឺត្រូវបានកំណត់នៅក្នុងលក្ខខណ្ឌនៃអ្វីដែលត្រូវបានអះអាងថា សាសនាទាំងអស់ធ្វើ ឬ អ្វីដែលមុខងារសង្គមនៃសាសនាត្រូវបានប្រកាន់យក។ ជាការពិតណាស់ និយមន័យមួយចំនួនគឺមានទំហំតូចជាងគោលបំណង។ [២៨] ពិភពលោករបស់យើងមានភាពប្រឡំបល់គ្នាពីពិពិធភាពនៃប្រពៃណីសាសនា។ កំណើននៃក្រុមអ្នកតំណាងសហធម្មចារី ឬ ក្រុមតំណាងនៃប្រពៃណីទំនៀមទម្លាប់ទាំងនេះ គឺអាចត្រូវបានគេឃើញនៅក្នុងទីក្រុងធំៗណាមួយ។ ដូច្នេះសំណួរដ៏សាមញ្ញមួយគឺថា តើសាសនាជាអ្វី? ចម្លើយដែលមានទំនួលខុសត្រូវ នឹងត្រូវបានឆ្លុះបញ្ចាំងពីអ្វីដែលនរណាម្នាក់រកឃើញ នៅក្នុងប្រពៃណីដែលយល់ស្របជាសកលថា អ្វីជាសាសនានោះ។ [២៩] ការអះអាងរបស់លោក ម៉ាក្ស (Marx's claim) ដែលថា សាសនាគឺជាការអាភៀនរបស់មនុស្ស [៣០] នោះ គឺមិនត្រូវបានស្នើឡើងថាជានិយមន័យ និង អព្យាក្រឹតភាពនៃសាសនាទេ ហើយសូម្បីគ្រាន់តែបង្ហាញពីអព្យាក្រឹតភាពក៏វាមិនអាចបានដែរ ព្រោះវាជានិយមន័យដែលបង្ហាញពីចរិតខាងមុខងារ ជាងខ្លឹមសារត្រឹមត្រូវនៃនិយមន័យអំពីសាសនានោះ ហើយនិយមដែលថា «សាសនា គឺជាសកម្មភាពនៃការទទួលយកសិទ្ធិមុនព្រះ» នោះ ក៏មិនមែនជានិយមន័យដែលមានអព្យាក្រឹតភាពដែរ តែវាជាផ្នែកមួយនៃការងារ ឬ មុខអាជីពទៅវិញ។ ជាមូលដ្ឋានសម្រាប់ការឆ្លើយសំណួរនឹងសំណួរនេះ គឺត្រូវការនិយមន័យដែលមានភាពអព្យាក្រឹត។ និយមន័យអព្យាក្រឹត នឹងមិនសន្មតនូវចម្លើយជាក់លាក់ណាមួយជាមុន ចំពោះភាពត្រឹមត្រូវនៃសំណួរបែបទស្សនវិជ្ជានោះឡើយ។ វានឹងមិនសន្មតជាមុនថាប្រពៃណីសាសនាជាក់លាក់ណាមួយ គឺពិត ឬ មិនពិត ឬថា គ្មានប្រពៃណីសាសនាណាមួយពិត ឬមិនពិតនោះទេ។ សម្រាប់ហេតុផលដែលមានភាពច្បាស់លាស់ វានឹងល្អប្រសិនបើនិយមន័យនោះអាចមានទាំងពីរ គឺទាំងមុខងារផង និង ទាំងការទទួលស្គាល់នូវចំណុចសំខាន់ ដែលធ្វើឡើងដោយសេចក្ដីព្យាយាម ដើម្បីផ្ដល់និយមន័យដ៏ច្រើននោះផង ដូចជាថា «សាសនា» គឺជាប្រព័ន្ធគោលគំនិត

---

[២៧] វីគីពីឌា (Wikipedia), «សាសនា (*Religion*), ដកស្រង់ចេញពីគេហទំព័រ https://en.wikipedia.org/wiki/Religion, នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១

[២៨] វីគីពីឌា (Wikipedia), «សាសនា (*Religion*), ដកស្រង់ចេញពីគេហទំព័រ https://en.wikipedia.org/wiki/Religion, នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១

[២៩] ក្នុងលក្ខខណ្ឌជាក់លាក់ ការនិយាយនេះគឺផ្ដោតលើសាសនាយូដា (Judaism), គ្រិស្តសាសនា (Christianity), សាសនាអ៊ីស្លាម (Islam), សាសនាហិណ្ឌូ (Hinduism), ព្រះពុទ្ធសាសនា (Buddhism), សាសនាជេន (Jainism), សាសនាសេមីត (Semitic), សាសនានៅអាស៊ីខាងត្បូង (South Asian), និង សាសនានៅឥណ្ឌា (Indian religion)។ សូមមើល YANDELL E. Keith, "***Philosophy of Religion: A Contemporary Introduction***", Op. Cit., P: 16 & P: 368

[៣០] YANDELL E. Keith, "***Philosophy of Religion: A Contemporary Introduction***", Op Cit., P: 16

ដែលផ្តល់នូវការបកស្រាយអំពីពិភពលោក និង ទីកន្លែងនៃការរស់រានមានជីវិតរបស់មនុស្សនៅក្នុងពិភពលោក ដោយផ្អែកទៅលើដំណើររឿងដែលថា តើជីវិតគួររស់នៅដោយរបៀបណា ហើយផ្តល់នូវបំណកស្រាយនោះ ដោយបង្ហាញពីបំណកស្រាយ និង របៀបរស់នៅនៃជីវិតនេះ នៅក្នុងសំណុំនៃពិធីសាសនា សេនាសនៈ និង ការបដិបត្តិ។ ឯនិយមន័យពីមុខងារនោះវិញ គឺថា «សាសនា» គឺត្រូវបានគេចាត់ទុកថាជាការផ្តល់ឱ្យមនុស្សនូវរឿងរ៉ាវនៃពិភពលោករបស់ពួកគេ និង កន្លែងដែលពួកគេរស់នៅក្នុងពិភពលោក ការបកស្រាយដែលពាក់ព័ន្ធនឹងការរស់នៅប្រចាំថ្ងៃ ហើយដែលត្រូវបានផ្តល់ឱ្យជីវិតនៅក្នុងសេនាសនៈ បដិបត្តិ និង ពិធីសាសនា ហើយវាក៏ទទួលស្គាល់ពីសារសំខាន់នៃសកម្មភាពសាសនា ថែមទាំងទទួលស្គាល់ពីសារសំខាន់នៃជាតុនានា ក្នុងគោលលទ្ធិក្នុងប្រពៃណីសាសនានោះផងដែរ។ ប្រសិនបើលទ្ធិដែលគ្មានពិធីសាសនានោះទេ គឺវានឹងទទេ ផ្ទុយទៅវិញ បើពិធីសាសនាគ្មានគោលលទ្ធិទៅវិញ នោះគឺខ្វាក់ជាប្រាកដ។ ជាងនេះទៀត គេក៏គួរបន្ថែមទៀតថា តាមរយៈ «ពិធីសាសនា» នៅទីនេះ គ្មាននរណាម្នាក់គិតថា គ្រាន់តែដើម្បីបូជាចំពោះសាសនាកាតូលិក ឬ ព្រះធម៌ដ៏ខ្ពង់ខ្ពស់របស់ព្រះសម្មាសម្ពុទ្ធ ឬក៏ របស់សាសនាអង់គ្លីខេន (Anglican) ឬ សាសនាលូថេរ៉ាន (Lutheran) នោះឡើយ។ ការប្រារព្ធពិធីរបស់ ព្លីម៉ោធ ប្រេធរេន (Plymouth Brethren) ចំពោះ Lord's Supper ឬក៏ ការប្រារព្ធពិធីរបស់សម្តេចប៉ាប Baptist ទៅដល់បរិស័ទប៉ាបដែលពេញវ័យ គឺជាពិធីសាសនាមួយក្នុងន័យថា ជាសកម្មភាពចាប់ផ្តើមខាងសាសនា ដែលប្រកបដោយអត្ថន័យទទួលខុសត្រូវខាងលទ្ធិសាសនា ដែលនិយមន័យនេះមានភាពអព្យាក្រឹត ក្នុងន័យដែលបានកំណត់នាពេលថ្មីៗនេះ។ ការព្យាបាលបែបវិទ្យាសាស្ត្រសង្គមនៃសាសនា មានទំនោរផ្តោតលើសេនាសនៈ ពិធីសាសនា និង ការបដិបត្តិ ទស្សនៈនេះក៏ថែមទាំងចាត់ទុកសមូហភាពជាបុរាណវត្ថុវប្បធម៌ ឬ បុគ្គលម្នាក់ៗ ជាប្រភពនៃអត្ថន័យផ្ទាល់ខ្លួន។ ការពិភាក្សាបែបទស្សនវិជ្ជាអំពីសាសនា គឺមានទំនោរផ្តោតលើគោលលទ្ធិដែលសាសនាផ្តល់ឱ្យ និង ពេលជរមាន។ វិធីសាស្ត្រទាំងនេះ គឺជាការបន្ថែមមិនមែនជាការប្រកួតប្រជែងទេ ទោះបីជាអ្នកសិក្សាស្រាវជ្រាវតែងតែទទួលយក ឬ សូម្បីតែបដិសេធក៏ដោយ សារសំខាន់នៃអ្វីដែលពួកគេធ្វើ គឺមិនបានកើតឡើងក្នុងការសិក្សាទេ។

និយមន័យមួយទៀតដែលមានលក្ខណៈខុសគ្នា ប៉ុន្តែ អាចទទួលយកបាន គឺបង្ហាញចរិតលក្ខណៈនៃសាសនា ក្នុងការធ្វើរោគវិនិច្ឆ័យ និង ការព្យាបាល។ សាសនាមួយស្នើឱ្យមានការវិនិច្ឆ័យ (រឿងរ៉ាវនៃអ្វីដែលវាត្រូវទទួលយកបញ្ហាជាមូលដ្ឋាន សម្រាប់ប្រឈមមុខនឹងអ្វីដែលមនុស្សជាតិកំពុងទទួលយក) និង ការព្យាបាល (វិធីនៃការដោះស្រាយបញ្ហានោះជាអចិន្ត្រៃយ៍ និង ដែលគួរឱ្យចង់បាននោះ) បញ្ហាជាមូលដ្ឋានមួយដែលចែករំលែកដោយមនុស្សគ្រប់រូប និង ដំណោះស្រាយជាមូលដ្ឋានមួយដែលថា ទោះយ៉ាងណាក៏ដោយ ការសម្របខ្លួនទៅនឹងវប្បធម៌ខុសគ្នា និង ករណីផ្សេងគ្នាគឺមានសារៈសំខាន់ដូចគ្នានៅទូទាំងសាកលលោក។ សាសនាមានភាពខុសគ្នាខ្លាំង នៅពេលដែលការធ្វើរោគវិនិច្ឆ័យ និង ការព្យាបាលរបស់ពួកគេខុសគ្នា។ ឧទាហរណ៍ សាសនាខ្លះជាឯកាទិទេពនិយម (monotheism) ហើយសាសនាខ្លះទៀតមិនដូច្នេះទេ។ ដូច្នេះ ការធ្វើរោគវិនិច្ឆ័យខ្លះត្រូវបានផ្តល់ជូនក្នុងលក្ខខណ្ឌនៃការផ្តាច់ខ្លួនពីព្រះ ហើយការព្យាបាលត្រូវបានបង្ហាញថា ការព្រួយបារម្ភនៃការដកចេញនូវភាពចម្លែកនោះ ខណៈដែលការធ្វើរោគវិនិច្ឆ័យ និង ការព្យាបាលផ្សេងទៀតមិនធ្វើសំដៅទៅលើព្រះនោះឡើយ។

## សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមកឃើញថា ជំនឿសាសនា មានសារសំខាន់ណាស់ចំពោះមនុស្ស រហូតដល់គេជឿថា «ជំនឿសាសនា» ធ្វើឱ្យមនុស្សមានភាពសច្ចៈថែមទៀត ហើយបើកាលណាមនុស្សមានជំនឿទៅលើព្រះ មនុស្សមុខជានឹងបានជួបជាមួយព្រះជាម្ចាស់ជាពុំខានទៀតផង។ ដូច្នេះ គេអាចនិយាយបានថា «ជំនឿសាសនា» គឺជាប្រភព ឬ ជាជម្រុក ដែលផ្ទុកទៅដោយមនោគមវិជ្ជា លទ្ធិ ប្រពៃណី ទំនៀមទម្លាប់ និង ពហុជំនឿផ្សេងៗ។ មនុស្សក្នុងពិភពលោកបានចាត់ទុក «ជំនឿសាសនា» ថាជាផ្លូវ ឬ ជាត្រីវិស័យ សម្រាប់បំភ្លឺដំណើរជីវិតរស់នៅរបស់ខ្លួន។ សាសនាបង្រៀនអំពីព្រះ ប៉ុន្តែ បើមនុស្សគ្មាន «ជំនឿ» ទេនោះ ពួកគេនឹងមិនអាចមានចំណេះដឹងបែបព្រះបានឡើយ ព្រោះថា «មនុស្សគ្មានជំនឿ» មិនអាចទទួលយកបាននូវចំណេះដឹង «គតិបណ្ឌិត» បែបអាថ៌កំបាំងរបស់ព្រះបានទេ។ ក្នុងដំណើរការណ៍នយោបាយទៀតសោត «ជំនឿសាសនា» តែងតែមានលក្ខណៈលាយឡំគ្នា ក្នុងទង្វើនយោបាយ រហូតដល់មានជាតិសាសន៍ខ្លះបានយក «ជំនឿសាសនា» ជាយានក្នុងការដឹកនាំរដ្ឋថែមទៀតផង។ សូម្បីតែទស្សនៈវិទូក៏បានយកចិត្តទុកដាក់ខ្លាំងក្នុងរឿងជំនឿសាសនានេះ ដោយមួយចំនួនរហូតដល់ចាត់ទុកថា «ជំនឿ» ជាមនោគតិ ឬ ជាចលករដំបូង ដែលធ្វើឱ្យមានការកកើតឡើងនូវលោកិយ ហើយពួកគេថែមទាំងមានទស្សនៈថា អ្វីៗទាំងអស់ដែលជាការពន្យល់បែបជំនឿសាសនានោះ គឺមានមូលដ្ឋានស្ថិតនៅលើបទពិសោធន៍ពិតៗ ឬ មានស្ថិតនៅក្នុងប្រាជ្ញាពិតរបស់មនុស្ស។ ការរីកចម្រើននៃវិទ្យាសាស្ត្រកើតចេញពីប្រាជ្ញា និង បទពិសោធន៍របស់មនុស្ស ដែលសន្សំពីជំនាន់មួយទៅជំនាន់មួយនោះ អាចមានបដិវាទកម្មទៅនឹងជំនឿសាសនា ហើយថា ពន្យល់នៃសាសនាក្នុងជំនឿនោះក៏អាចមានភាពសច្ចៈដែរ។ ការរីកចម្រើននៃវិទ្យាសាស្ត្រ អាចមានបដិវាទកម្មទៅនឹងជំនឿ ហើយបញ្ហាទាំងអស់នៅតែជាអាថ៌កំបាំងរហូតមកដល់បច្ចុប្បន្ន ដែលនោះអាចជាអាថ៌កំបាំងរបស់ធម្មជាតិ។ ពួកសម្ភារៈនិយមមានសុទិដ្ឋិនិយមខ្លាំង ដោយបញ្ចេញទស្សនៈថា ពិភពលោកនឹងមិនមានអាថ៌កំបាំងឡើយ ប្រសិនបើប្រាជ្ញារបស់មនុស្សមានការរីកចម្រើនដល់កំពូល ចេះបង្កើតបច្ចេកវិទ្យាទំនើបៗក្នុងវិចារណញាណនៃការស្រាវជ្រាវ។ ចំណែកពួកមនោនិយមបានឱ្យតម្លៃថា អ្វីទាំងអស់ដែលកើតមានឡើង ដែលមនុស្សមាន គឺជាការប្រទានឱ្យដោយព្រះអាទិទេព ដូច្នេះ ប្រវត្តិជីវិតនៃមនុស្សលោកត្រូវតែមានដែនកំណត់របស់វា ហើយស្ថិតនៅក្នុងរង្វង់នៃព្រំដែនដែលព្រះប្រទានឱ្យ។ វិវាទរវាង «ប៉ូលគតិ» ទាំងពីរ បានធ្វើដំណើរទៅរកលក្ខណៈរួមមួយគឺ ពួកគេបានឱ្យតម្លៃថា «ភាពសច្ចៈ» អាចទទួលស្គាល់បាន គឺស្ថិតនៅលើការពិភាក្សា ដែលត្រូវតែសន្មតយកប្រាជ្ញារបស់មនុស្សជាលក្ខខណ្ឌត្រួតពិនិត្យ ហើយមានការបង្ហាញនឹងបញ្ជាក់ច្បាស់លាស់ដោយបទពិសោធន៍។ ទស្សនៈបែបនេះ ត្រូវបានគេលើកយកមកធ្វើការសិក្សាជាលក្ខណៈ «ទស្សនវិជ្ជាបែបសាសនា»។ ដូច្នេះបានជា «សាសនា» មានកាតព្វកិច្ចក្នុងការស្ថាបនានូវ «ជំនឿ» មួយប្រកបទៅដោយ «សនិទានភាព» ហើយបានជានៅក្នុងសាសនាក៏បានបង្កើតឱ្យមានឡើងនូវព្រះទាំងឡាយ ដែលមានភិនភាគជាមនុស្សលោកសុទ្ធសាទ ដូចជា ព្រះពុទ្ធ, ព្រះគ្រិស្ត, ព្រះអាឡាហ៍ជាដើម[៣១]។

[៣១] ដកស្រង់ចេញពីគេហទំព័រ https://en.wikipedia.org/wiki/Religion, នៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០២១

# គន្ថនិទ្ទេស


## ឯកសារជាស្នាដៃនិពន្ធ

០១- ខ្លួត ធីតា, «*ការស្វែងយល់អំពីបេតិកភ័ណ្ឌព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរ* », ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, ឆ្នាំ២០០២

០២- ខ្លួត ធីតា, «*ព្រះពុទ្ធបដិមានៅកម្ពុជា* », ការផ្សាយរបស់រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ, ឆ្នាំ២០១៣

០៣- ខ្លួត ធីតា,«*ព្រះពុទ្ធសាសនា និង ការអភិវឌ្ឍសង្គមខ្មែរ* », ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, ឆ្នាំ *១៩៩៦*

០៤- យឹម សន (សម្តេចព្រះពុទ្ធជ័យមុនី), «*សារៈសំខាន់វត្តអារាមព្រះពុទ្ធសាសនា*» បទបង្ហាញក្នុងសិក្ខាសាលា ស្តីពី ព្រះវិហារបុរាណ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨

០៥- ជួន ណាត (ជោតញ្ញាណោ), «*វចនានុក្រមខ្មែរភាគទី១-២* », ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, បោះពុម្ពផ្សាយគ្រាទី៥, ភ្នំពេញ, ឆ្នាំ១៩៦៨។

០៦- ឈឹង ប៊ុនឈា (ព្រះទេពសត្ថា), «*ព្រះពុទ្ធសាសនា និង ការអភិវឌ្ឍសង្គមខ្មែរតាំងពីអតីតកាលរហូតដល់បច្ចុប្បន្នកាល*» បទអន្តរាគមន៍ក្នុងសិក្ខាសាលាជាតិ ស្តីពី «*ស្ថានភាពសាសនានៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន*» រៀបចំឡើងដោយ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា ២០០២

០៧- ហួត តាត, «*ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា*» សង្ខេប, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, ព.ស. ២៥១៥

## ឯកសារជាលិខិតបទដ្ឋានគតិយុត្តិ

០៨- ព្រឹទ្ធសភានៃព្រះរាជណាចក្រកម្ពុជា៖ «*រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា* », ការផ្សាយរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា, ភ្នំពេញ, ឆ្នាំ២០១៣។

០៩- សេចក្តីសម្រេចលេខ៨២ សសរ. ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពី «*គោលការណ៍គ្រប់គ្រងវត្តអារាម និង ទ្រព្យគុកណ្ឌសង្ឃ* », ការផ្សាយរបស់រាជរដ្ឋាភិបាល, ភ្នំពេញ, ឆ្នាំ១៩៩៣

១០- សារាចរលេខ០៤ ក.ធ.ស/សរ. ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០១ ស្តីពី «*តួនាទី និង ភារកិច្ចអាចារ្យ-គណៈកម្មការវត្ត* », ការផ្សាយរបស់ក្រសួងធម្មការ និងសាសនា, ភ្នំពេញ, ឆ្នាំ២០០១

## ឯកសារជាទស្សនាវដ្តី, សារព័ត៌មាន និងព្រឹត្តបត្តិ

១១- សមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ, «*ទស្សនាវដ្តីពន្លឺពុទ្ធចក្រ លេខ១ ដល់ លេខ៥*», ការផ្សាយរបស់សមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ, ភ្នំពេញ, ឆ្នាំ១៩៦១

១២- សមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ, «*ទស្សនាវដ្តីពន្លឺពុទ្ធចក្រ លេខ៦ ដល់ លេខ៨*», ការផ្សាយរបស់សមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ, ភ្នំពេញ, ឆ្នាំ១៩៦២

១៣- សមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ, « *ទស្សនាវដ្តីពន្លឺពុទ្ធចក្រ លេខ៩ ដល់ លេខ១២*», ការផ្សាយរបស់សមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ, ភ្នំពេញ, ឆ្នាំ១៩៦៣
១៤- សមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ, « *ទស្សនាវដ្តីពន្លឺពុទ្ធចក្រ លេខ១៣ ដល់ លេខ១៦*», ការផ្សាយរបស់សមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ, ភ្នំពេញ, ឆ្នាំ១៩៦៤
១៥- សមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ, « *ទស្សនាវដ្តីពន្លឺពុទ្ធចក្រ លេខ១៧ ដល់ លេខ២០*», ការផ្សាយរបស់សមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ, ភ្នំពេញ, ឆ្នាំ១៩៦៥
១៦- សមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ, « *ទស្សនាវដ្តីពន្លឺពុទ្ធចក្រ លេខ២១ ដល់ លេខ២៤*», ការផ្សាយរបស់សមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ, ភ្នំពេញ, ឆ្នាំ១៩៦៦
១៧- សមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ, « *ទស្សនាវដ្តីពន្លឺពុទ្ធចក្រ លេខ២៥ ដល់ លេខ២៨*», ការផ្សាយរបស់សមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ, ភ្នំពេញ, ឆ្នាំ១៩៦៧
១៨- សមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ, « *ទស្សនាវដ្តីពន្លឺពុទ្ធចក្រ លេខ២៩ ដល់ លេខ៣២*», ការផ្សាយរបស់សមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ, ភ្នំពេញ, ឆ្នាំ១៩៦៨
១៩- សមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ, « *ទស្សនាវដ្តីពន្លឺពុទ្ធចក្រ លេខ៣៣ ដល់ លេខ៣៦*», ការផ្សាយរបស់សមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ, ភ្នំពេញ, ឆ្នាំ១៩៦៩

## ឯកសារជាភាសាបរទេស

២០- ADAMSON Peter and TAYLOR C. Richard, "***Arabic Philosophy*"** Published by CAMBRIDGE University Press, USA and UK, 2005
២១- BANE Theresa, "***Encyclopedia of Demons in World Religions and Culture***" Published by McFarland & Company, Inc., Publisher. USA, 2012
២២- BELLAH N. Robert, "***Religion in Human Evolution***" Published by The Belknap Press of Harvard University Press, USA and UK, 2011
២៣- BUSWELL E. Robert Jr., "***Encyclopedia of Buddhism*"** Published by Macmillan Reference USA, 2004
២៤- EDELGLASS William & GARFIELD L. Jay, "***Buddhist Philosophy*"** Published by OXFORD University Press Inc., USA, 2009
២៥- EISENDRATH-Young Polly and MURAMOTO Shoji, "***Awakening and Insight Zen Buddhism and Psychotherapy*"** Published by Brunner-Routledge Taylor & Francis Group, USA and Canada, 2002
២៦- ELLWOOD S. Robert and ALLES D. Gregory, "***The Encyclopedia of World Religions***" Published by DWJ Books LLC, USA, 2007
២៧- EMMANUEL M. Steven, "***A Companion to Buddhist Philosophy*"** Published by John Wiley & Sons Inc., USA and UK, 2013
២៨- GETHIN Rupert, "***The Foudations of Buddhism***" Published by OXFORD University Press, USA, 1998
២៩- GILSON Etienne, Translated by MAURER Armand, "***Christian Philosophy*"** Published by Pontifical Institute of Mediaeval Studies, Canada, 1993

៣០- HARRISON Peter, “***Science and Rligion”*** Published by Cambridge University Press, USA and UK, 2010

៣១- KHALED El-Rouayheb and SABINE Schmidtke, “***Islamic Philosophy”*** Published by OXFORD University Press, USA, 2017

៣២- LEEMING A. David, MADDEN Kathryn, and MARLAN Stanton, “***Encyclopedia of Psychology and Religion***” Published by Springer Science+Business Media LLC. USA, 2010

៣៣- MARTY J. Elsa and TALIAFERRO Charles, “***A Dictionary of Philosophy of Religion***” Published by Charles Taliaferro, Elsa J. Marty and Contributors, USA, 2010

៣៤- PETERSON L. Michael and VANARRAGON J. Raymond, “***Contemporary Debates in Philosophy of Religion***” Published by Blackwell Publishing Ltd., USA and UK, 2004

៣៥- Robert E. Buswell, Jr., William M. Bodiford, Donald S. Lopez, Jr., Carl W. Belser, John S. Strong, Eugene Y. Wang and Gardner Cowles : “ENCYCLOPEDIA OF ***BUDDHISM”*** Published by Macmillan Reference USA and The Gale Group, Inc., USA, 2004

៣៦- Rupert Gethin : “***The Foundations of Buddhism”*** Published by Oxford New York OXFORD UNIVERSITY PRESS, USA, 1998

៣៧- SAFRA E. Jacob and CAUZ-Aguilar Jorge, “***Britannica Encyclopedia of World Religions***” Published by OXFORD University Press, USA, 2017

៣៨- SCHREIBER-Fischer Ingrid, EHRHARD Karl-Franz, and DIENER S. Michael, “***The Encyclopedia of Eastern Philosophy and Religion***” Published by Encyclopedia Britannica Inc., USA, 2006

៣៩- Sonia Jasrotia: “***BUDDHISM IN SOUTHEAST ASIA”*** First Edition, Published by Shubhi Publication, India, 2018

៤០- TALIAFERRO Charles, DRAPER Paul, and QUINN L. Philip., “***A Companion to Philosophy of Religion”*** Published by Blackwell Publishing Ltd., USA and UK, 2010

៤១- YANDELL E. Keith “***Philosophy of Religion”*** Published by Routledge, USA and Canada, 1999

## ឯកសារដកស្រង់ពីគេហទំព័រ

២៨- https://en.wikipedia.org/wiki/Religion

២៩- https://en.wikipedia.org/wiki/Augustine_of_Hippo

៣០- https://en.wikipedia.org/wiki/Lactantius

៣១- https://en.wikipedia.org/wiki/Cicero

៣២- https://en.wikipedia.org/wiki/Julius_Caesar

៣៣- https://en.wikipedia.org/wiki/Pliny_the_Elder

៣៤- https://en.wikipedia.org/wiki/Tom_Harpur

៣៥- https://en.wikipedia.org/wiki/Joseph_Campbell
៣៦- https://en.wikipedia.org/wiki/Karl_Marx
៣៧- https://en.wikipedia.org/wiki/%C3%89mile_Durkheim
៣៨- https://en.wikipedia.org/wiki/Sigmund_Freud
៣៩- https://en.wikipedia.org/wiki/Edward_Burnett_Tylor

# បម្រែបម្រួលបរិមាណអ៊ីយ៉ុងស្យានួនិងនីត្រាត
# ក្នុងមើមដំឡូងមីតាមពូជ និងអាយុកាលលូតលាស់

**បេក្ខជនបណ្ឌិត ម៉ក់ ថណ្ណៈ**
ជំនាញ **គីមីវិទ្យា**

## សេចក្តីផ្តើម

ដំឡូងមីជាដំណាំអាចរស់ឡើងវិញ។ រុក្ខជាតិនេះដូចជាស្លឹកនិងមើមត្រូវបានប្រើជាអាហារមនុស្ស ចំណីសត្វនិងសម្រាប់ឧស្សាហកម្ម។ មើមវាសម្បូរកាបូអ៊ីដ្រាត 80%-90% ប្រូតេអ៊ីនតិចតួចប្រហែល 1-2% អាស៊ីដអាមីនេតិចតួចបំផុតមានលីស៊ីន(lysine) មេស្យូនីន(methionine) ទ្រីបតូហ្វាន (tryptophane) (Julie A et al. 2008)។

ដំឡូងមីងាយដុះលើដីខ្សត់ជីជាតិ ធន់នឹងភាពរាំងស្ងួត មើមអាចកប់ទុកក្នុងដីរហូតដល់បីឆ្នាំជាអាហារបម្រុងទុក (Bradbury and Holloway, 1988)។ ប្រភេទដំឡូងមីត្រូវចាត់ថ្នាក់តាមកំហាប់ស្យានួពីទាប(ដំឡូងមីផ្អែម, sweet cassava)ទៅខ្ពស់(ដំឡូងមីល្វីង,bitter cassava) (Cock,1985)។ មានកត្តាខ្លះៗដូចជាជំងឺប៉េស្តដូវរាំងស្ងួតអូសបន្លាយបានធ្វើឲ្យមើមកើនកំហាប់ស្យានួ។ ដំឡូងមីល្វីងធន់នឹងភាពរាំងស្ងួត តម្លៃថោកគេដាំដុះច្រើន។ ផ្នែកទាំងអស់នៃដំឡូងមីមានស្យាណូហ្សែនគ្លីកូស៊ីដលើកលែងតែគ្រាប់។ សមាសធាតុនេះត្រូវបានសំយោគក្នុងស្លឹក ហើយបន្តទៅមើម។ ស្យាណូហ្សែនគ្លីកូស៊ីដមានច្រើនក្នុងស្លឹកនិង សំបកទី២នៃមើម(900-2000mg HCN/Kg)(Cardoso et al., 2005)។រុក្ខជាតិប្រហែល2650ប្រភេទផ្ទុកស្យាណូហ្សែនគ្លីកូស៊ីដ(cyanogenglycoside) អាចបំបែកដោយអង់ហ្ស៊ីមបេតាគ្លុយកូស៊ីដាស($\beta$-glycosidase)ទៅជាស្ករនិងស្យាណូអ៊ីឌ្រីន(cyanohydrin)។ ស្យាណូអ៊ីឌ្រីនបំបែកយ៉ាងរហ័សទៅជាHCNនិងអាល់ដេអ៊ីដឬសេតូន(FSANZ, 2005 cited by Hosel, 1981; Moller and Seigler,1999)។ HCN ពុលអាចធ្វើឲ្យខ្វិនសាច់ដុំនិងប៉ះពាល់ផ្លូវដង្ហើម ជំងឺពុំរ៉ៃពេលខ្លះបណ្តាលឲ្យស្លាប់។ ប្រព្រឹត្តិកម្មមើមដំឡូងមីមិនបានត្រឹមត្រូវចំពោះពូជល្វីងធ្វើឲ្យសល់ស្យានួច្រើនអាចបំពុលបាន(Mlingi et al., 1994)។ ក្រៅពីស្យានួ នីត្រាតគឺជាសមាសធាតុអាសូតមួយដែលរុក្ខជាតិត្រូវការ។ អាសូត និងសមាសធាតុមាននៅគ្រប់កន្លែងក្នុងធម្មជាតិដូចជាក្នុងដី ក្នុងទឹក និងស្រូបដោយរុក្ខជាតិ។ នីត្រាតនេះត្រូវបំប្លែងជាប្រូតេអ៊ីននិងសមាសធាតុដទៃទៀត។ បរិមាណដ៏ច្រើននៃនីត្រាតមានក្នុងដំណាំចំណីសត្វ និងបន្លែ។ ការកើនឡើងនៃកម្រិតនីត្រាតធ្វើឲ្យកើនដល់ការសំយោគជាតិម្សៅ និងស្យានួក្នុងមើមដំឡូងមី(Thomas Kurien et al., 1975)។ នីត្រាតអាចបំប្លែងជានីទ្រីតដែលបង្កគ្រោះថ្នាក់ដល់សុខភាព។

ដំឡូងមីគឺជាដំណាំយុទ្ធសាស្ត្រទីពីររបស់កម្ពុជាបន្ទាប់ពីដំណាំស្រូវ។ កម្ពុជាផលិតដំឡូងមីលំដាប់ទី៨នៅលើពិភពលោកនិងលំដាប់ទី៤នៅក្នុងតំបន់(កម្ពុជាថ្មី 20 មករា 2018)។ រាល់ផលិតផលដំឡូងមីត្រូវបានប្រើប្រាស់ក្នុងស្រុក និងនាំចេញទៅក្រៅប្រទេសដែលច្រើនជាងពាក់កណ្តាលជាផលិតផលដំឡូងមីស្រស់ 40%ជាចំណិតដំឡូងមីស្ងួត និងប្រហែល 10%ទៀតជាប្រភេទម្សៅមី(ក្រសួងពាណិជ្ជកម្មឆ្នាំ2012)។ ការធ្វើពាណិជ្ជកម្មដំឡូងមីលើទីផ្សារត្រូវកំណត់HCNឲ្យតិចជាង0.015%។ ពូជដំឡូងមីដែលកសិករយកមកដាំចែកជាពីរក្រុមគឺពូជសម្រាប់បរិភោគមើម(ប្រភេទផ្អែម)និងពូជសម្រាប់ឧស្សាហកម្ម(ប្រភេទល្វីង)។

## វិធីសាស្ត្រស្រាវជ្រាវ

ដាំដំឡូងមីប្រាំពូជនៅកសិដ្ឋានក្រុមហ៊ុនមួយនៅភូមិអូរទាក់ធ្នឹម ឃុំដូនបា ស្រុកកោះក្រឡ ខេត្តបាត់ដំបង ទំហំចំការ ៣៧០ហិចតាដាំដំឡូងមីចម្រុះពូជ។ ការពិសោធរកបម្រែបម្រួលកំហាប់អ៊ីយ៉ុងស្យានួ និងនីត្រាតក្នុងមើមដំឡូងមីស្រស់តាមអាយុនិងប្រភេទពូជចែកជាពីរវគ្គទី១អាយុ៤ខែនិងទី២អាយុ៨ខែ។

## វិធីយកភាគសំណាកមើមដំឡូងមីស្រស់

ការយកភាគសំណាកមើមដំឡូងមីស្រស់ គឺយកមើមដំឡូងមីល្អបំផុតក្នុងមួយពូជជ្រើសយកពីរមើម ហើយយកនៅម៉ោងពីរ លាងសម្អាតដាក់ក្នុងស្បោងប្លាស្ទិកបិទជិតដាក់ក្នុងធុងត្រជាក់ ហើយនាំមកាន់ទីពិសោធន៍រក្សាទុកក្នុងទូទឹកកកនៅសីតុណ្ហភាព -18 °C រយៈពេល ២៤ ម៉ោងរង់ចាំធ្វើពិសោធន៍បន្ត។

## វិធីសាស្ត្រក្រដាសពីក្រាត

វិធីសាស្ត្រក្រដាសពីក្រាតសម្រាប់ការរកស្យានួក្នុងមើមដំឡូងមីអាស្រ័យលើអង់ហ្ស៊ីមក្នុងកោសិកាមើមដំឡូងមីទៅបំបែកម៉ូលេគុលស្យាណូហ្សែនគ្លុយកូស៊ីដឬលីណាម៉ារីនដែលមានក្នុងភាគសំណាកមើមដំឡូងមីស្រស់នោះ។ អ៊ីដ្រូហ្សែនស្យានួដែលបានផ្តាច់ចេញបានទៅប្រតិកម្មជាមួយក្រដាសពីក្រាតពណ៌លឿងទៅជាពណ៌ចាស់ជាង(ពណ៌ត្នោត)។ ការប្រែប្រួលពណ៌ក្រដាសនេះត្រូវបានយកទៅប្រើដើម្បីវាស់កំហាប់HCN ដែលបានផ្តាច់ចេញពីភាគសំណាកមើមដំឡូងមីស្រស់។ វិធីសាស្ត្រក្រដាសពីក្រាតមិនមែនជាវិធីសាស្ត្រប្រាកដខ្លាំងណាស់នោះទេតែបើមិនមានលទ្ធភាពរកវិធីសាស្ត្រឲ្យប្រសើរជាងនេះទេ វិធីសាស្ត្រក្រដាសពីក្រាតនេះគឺជាជម្រើសមួយដ៏ល្អណាស់។ វិធីសាស្ត្រនេះគឺមានភាពជាក់លាក់ ល្បឿងត្រូវបានកាត់បន្ថយ( Bradbury et al. 1999 )។

Bradbury et al (1999)បានរៀបចំក្រដាសពីក្រាតដើម្បីរកសមាសធាតុស្យាណូហ្សែនសរុបនៅក្នុងមើមដំឡូងមី។ វិធីនេះវាស់អ៊ីយ៉ុងស្យានួដែលបំបែកបានក្នុងអាស៊ីតខ្សោយ ផ្អែកលើរេដុកម្មនៃសូដ្យូមពីក្រាតដោយHCN បង្កើតបានផលិតផលមានពណ៌ដែលអាចវាស់បានដោយឧបករណ៍ស្ប៉ិចត្រូហ្វូតូម៉ែត។ រេដុកម្មនៃសូដ្យូមពីក្រាតនេះមានឥទ្ធិពលតែជាមួយស្យានួសេរីតែប៉ុណ្ណោះ ហើយអាស្រ័យលើក្រដាសដែលស្រូបសូលុយស្យុងសូដ្យូមពីក្រាត។

### .ការផ្តាច់អ៊ីយ៉ុងស្យានួពីមើមដំឡូងមី និងអត្តសញ្ញាណកម្មវាដោយក្រដាសពីក្រាត

(១). ថ្លឹងម្សៅដំឡូងមី 0.1g ដាក់ចូលបំពង់សាក(6 mL)ចំនួនបួន។

(២). បូមសូលុយស្យុងតំប៉ុងហ្វូស្វាត 800 uL ដាក់ចូលបំពង់សាកទាំងបួន។

(៣). យកគម្របភ្ជាប់ក្រដាសពីក្រាត(1×5cm) មកគ្របបំពង់សាកទាំងនោះភ្លាម។

(៤). ទុកប្រតិកម្មក្នុងចង្ក្រានមីក្រូរលកនៅសីតុណ្ហភាព 40 °C រយៈពេល 24H។

(៥). សង្កេតឃើញពណ៌ដាំនៅលើក្រដាសពីក្រាត។

### .ការវាស់រកអាប់ស៊ីបបង់និងការគណនារកកំហាប់

(១). ដកក្រដាសពីក្រាតប្រតិកម្មដាក់ចូលកែវវាស់មាឌ(100 mL)បួនមានទឹកបិត 10 mL ត្រាំទុក30 min

(២). បូមសូលុយស្យុងពណ៌ដាក់ក្នុងកែវគុយវ៉ែត 1cm វាស់រកអាប់ស៊ីបបង់នៅជំហានរលក 510nm

(៣). យកក្រដាសពីក្រាតទំហំ 1×5cm ចំនួនបួនត្រាំទឹកបិត 10mL ក្នុងកែវវាស់មាឌចំនួនបួន រយៈពេល 30 minធ្វើសូលុយស្យុង Blank ។

(៤). វាស់រកអាប់ស៊បបង់ ។

(៥). គណនារកកំហាប់អ៊ីយ៉ុងស្យានួប្រតិកម្ម(X) និងកំហាប់អ៊ីយ៉ុងស្យានួក្នុងមើមដំឡូងមី(C)

តាមសមីការ៖ Y = 0.0077X - 0.0134 $X = \frac{Y + 0.0134}{0.0077}$, Y អាប់ស៊បបង់ពិត $(Y = Abs._{sample} - Abs._{blank})$

$C = \frac{X \times V}{m}$ X (ជាកំហាប់អ៊ីយ៉ុងស្យានួធ្វើប្រតិកម្ម) C (ជាកំហាប់អ៊ីយ៉ុងស្យនួក្នុងមើមដំឡូងមី0.1g)

m(ជាម៉ាសមើមដំឡូងមី) = 0.1g, V(មាឌទឹកបិតប្រើសម្រាប់រំលាយជាតិពណ៌)=10 mL ។

## ពិសោធន៍រកកំហាប់អ៊ីយ៉ុងនីត្រាតតាមវិធីសាស្ត្រនីត្រាតកម្មនៃអាស៊ីដសាលីស៊ីលិក

មកដល់ពេលនេះយើងមានវិធីសាស្ត្រអាស៊ីដសាលីស៊ីលិកគឺមិនមានកត្តាជ្រៀតជ្រែក គួរឲ្យជឿជាក់ និងមានស្ថេរភាព។ ធ្វើប្រតិកម្មរវាងនីត្រាតជាមួយអាស៊ីដសាលីស៊ីលិកក្នុងមជ្ឈដ្ឋានអាស៊ីដស៊ុលហ្វួរិកខាប់។ បន្ទាប់មកយើងបំប្លែងឲ្យទៅជាមជ្ឈដ្ឋានបាស(pH>12)នោះសូលុយស្យុងឡើងពណ៌លឿងដែលត្រូវនឹងសម្រូបអតិបរមានៅប្រវែងរលក410nm។ អាប់ស៊បបង់នេះគឺសមាមាត្រទៅនឹងកំហាប់នីត្រាត។ ដូច្នេះកំហាប់នីត្រាតនៅក្នុងជាលិការុក្ខជាតិត្រូវបានគណនាដោយផ្អែកលើអាប់ស៊បបង់របស់វា។ វិធីសាស្ត្រនេះត្រឹមត្រូវអាចទទួលយកបានសម្រាប់ការកំណត់រកកំហាប់នីត្រាតក្នុងរុក្ខជាតិ(Lufei Zhao and Yong Wang, 2017)។

យោងតាម **Cataldo et al. (1975)** វិធីសាស្ត្រនីត្រាតកម្មនៃអាស៊ីដសាលីស៊ីលិកក្នុងមជ្ឈដ្ឋានអាស៊ីដស៊ុលហ្វួរិកខាប់មានបម្រែបម្រួលពណ៌រហ័សហើយអាចរកកំហាប់អ៊ីយ៉ុងនីត្រាតនៅក្នុងជាលិការុក្ខជាតិបានលឿន។ វិធីសាស្ត្រនេះត្រូវបានគេប្រើប្រាស់ជាច្រើនតាំងពីឆ្នាំ 1976 រហូតដល់បច្ចុប្បន្ននេះ។

### វិធីផ្តាច់យកអ៊ីយ៉ុងនីត្រាតពីសាច់មើមដំឡូងមីស្រស់

(១). ថ្លឹងមើមដំឡូងមីកិន 1g ដាក់ក្នុងបំពង់សាកមានគម្រប។

(២). បូមយកទឹកបិតពុះ 5 mL ដាក់ចូលបំពង់សាកមានមើមដំឡូងមីកិន ហើយក្រឡុកវាយ៉ាងខ្លាំង បន្ទាប់មកបន្ថែមទឹកបិតពុះ 5 mLហើយត្រាំក្នុងទឹកកំពុងពុះ រយៈពេល 60min ហើយដកមកក្រឡុកម្តងៗ។

(៣). ទុកឲ្យត្រជាក់ រួចដាក់ចូលឧបករណ៍រង្វិលចាកផ្ចិត ល្បឿន 1500ជុំ/sec. ក្នុងរយៈពេល 30min ។

(៤). ផ្ទេរយកអង្គធាតុរាវថ្លាខាងលើរក្សាទុកក្នុងទូទឹកកករង់ចាំប្រតិកម្មបន្ត។

### វិធីវាស់រកអាប់ស៊បបង់ និងគណនារកកំហាប់អ៊ីយ៉ុងនីត្រាត

(១). រៀបចំប្រតិកម្មអ៊ីយ៉ុងនីត្រាត(0.2mL)ជាមួយសូលុយស្យុងអាស៊ីដសាលីស៊ីលិក 0.8mL 5.0%ក្នុងអាស៊ីដស៊ុលហ្វួរិកខាប់ ក្នុងកែវវាស់មាឌចំនួនបួន(សម្រាប់១ពូជៗ) បន្ទាប់ពីប្រតិកម្មស្រាកស្រានលេចចេញពណ៌ក្រហមត្នោតប្រហែល 40min ទើបបន្ថែមសូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីដ 8mL កំហាប់ 5.0 M យឺតៗលេចចេញពណ៌លឿងខ្ចីភ្លាម។

(២). រក្សាទុកឲ្យត្រជាក់នៅសីតុណ្ហភាពបន្ទប់ សង្កេតឃើញពណ៌មានសភាពប្រែប្រួល ពីលឿងខ្ចីទៅលឿងទឹកក្រូច និងទៅពណ៌ត្នោតអាស្រ័យកំហាប់ និងបន្តរក្សាទុករហូតដល់ 60 min ដើម្បីឲ្យពណ៌មានស្ថេរភាព។

(៣). វាស់អាប់ស៊បបង់នៅជំហានរលក 410 nm។

(៤).គណនារកកំហាប់អ៊ីយ៉ុងនីត្រាត(X)តាមសមីការស្តង់ដា៖

Y=0.0017X+0.0283, $X = \frac{Y - 0.0283}{0.0017}$, Y ជាអាប់ស៊បបង់ពិត $(Y = Abs._{sample} - Abs._{blank})$

(៥).គណនារកកំហាប់អ៊ីយ៉ុងនីត្រាតក្នុងមើមដំឡូងមីតាមរូបមន្ត $C = \frac{X \times V_1}{m \times V_2}$

X (ជាកំហាប់អ៊ីយ៉ុងនីត្រាតធ្វើប្រតិកម្ម) C (ជាកំហាប់អ៊ីយ៉ុងនីត្រាតក្នុងមើមដំឡូងមី1g)

m(ជាម៉ាសមើមដំឡូងមី) = 1g, $V_1$(មាឌទឹកបិតប្រើសម្រាប់ផ្តាច់អ៊ីយ៉ុងនីត្រាត)=10 mL,

$V_2$(មាឌសូលុយស្យុងនីត្រាតយកទៅធ្វើប្រតិកម្ម)=0.2 mL

## ការវិភាគតាមស្ថិតិវិទ្យា

ការវិភាគស្ថិតិតាម One-Way-ANOVA រកភាពខុសគ្នារវាងកំហាប់អ៊ីយ៉ុងស្យានួនិងនីត្រាតនៅក្នុងសាច់នៃមើមដំឡូងមីទាំងប្រាំពូជ (p<.001)។

## លទ្ធផល

### កំហាប់អ៊ីយ៉ុងស្យានួសរុបក្នុងសាច់មើមដំឡូងមីផ្នែកទាំងបីតាមពូជនិងអាយុ

តារាងទី១៖ កំហាប់អ៊ីយ៉ុង $CN^-$ (ppm)ក្នុងសាច់មើមដំឡូងមីអាយុបាន៤ខែ

| ប្រភេទ ភាគសំណាក | ពូជទី១ ដំឡូងឈើ | ពូជទី២ ត្រួយស្វាយ | ពូជទី៣ ត្រួយស | ពូជទី៤ ស្លឹកកញ្ឆា | ពូជទី៥ ជាងក្រហម | Significance (p) |
|---|---|---|---|---|---|---|
| P(Ⅱ) | 615.58 | 8816.88 | 2706.49 | 1846.10 | 2277.92 | p<.001 |
| P(Ⅲ) | 638.31 | 4433.77 | 2495.45 | 2200.00 | 501.95 | p<.001 |
| P(Ⅳ) | 781.17 | 3732.47 | 2553.90 | 2700.00 | 492.21 | p<.001 |
| មើមដំឡូងមី | 678.36 | 5661.04 | 2585.28 | 2248.70 | 1090.69 | |

P(Ⅱ)៖សាច់ផ្នែកក្បាលនៃមើម P(Ⅲ)៖សាច់ផ្នែកកណ្តាលនៃមើម P(Ⅳ)៖សាច់ផ្នែកចុងនៃមើម

ពូជដំឡូងឈើមានកំហាប់អ៊ីយ៉ុងស្យានួតិចជាងគេ រីឯពូជស្លឹកត្រួយស្វាយមានកំហាប់អ៊ីយ៉ុងស្យានួច្រើនជាងគេបង្អស់។

តារាងទី២៖ កំហាប់អ៊ីយ៉ុង $CN^-$ (ppm)ក្នុងសាច់មើមដំឡូងមីអាយុបាន៨ខែ

| ប្រភេទ ភាគសំណាក | ពូជទី១ ដំឡូងឈើ | ពូជទី២ ត្រួយស្វាយ | ពូជទី៣ ត្រួយស | ពូជទី៤ ស្លឹកកញ្ឆា | ពូជទី៥ ជាងក្រហម | Significance (p) |
|---|---|---|---|---|---|---|
| P(Ⅱ) | 469.48 | 4531.17 | 2079.87 | 1508.44 | 556.17 | p<.001 |
| P(Ⅲ) | 635.07 | 3826.62 | 2070.13 | 2161.04 | 1268.18 | p<.001 |
| P(Ⅳ) | 651.30 | 3264.94 | 2037.66 | 2398.05 | 872.08 | p<.001 |
| មើមដំឡូងមី | 585.28 | 3874.24 | 2062.55 | 2022.51 | 898.81 | |

P(Ⅱ)៖សាច់ផ្នែកក្បាលនៃមើម P(Ⅲ)៖សាច់ផ្នែកកណ្តាលនៃមើម P(Ⅳ)៖សាច់ផ្នែកចុងនៃមើម

រាល់ពូជទាំងអស់មានកំហាប់អ៊ីយ៉ុងស្យានួថយចុះតាមកំនើននៃអាយុ

### កំហាប់អ៊ីយ៉ុងនីត្រាតសរុបក្នុងសាច់មើមដំឡូងមីផ្នែកទាំងបីតាមពូជ និងអាយុ

តារាងទី៣៖ កំហាប់អ៊ីយ៉ុង $NO_3^-$ (ppm)ក្នុងសាច់មើមដំឡូងមីអាយុបាន៤ខែ

| ប្រភេទ ភាគសំណាក | ពូជទី១ ដំឡូងឈើ | ពូជទី២ ត្រួយស្វាយ | ពូជទី៣ ត្រួយស | ពូជទី៤ ស្លឹកកញ្ឆា | ពូជទី៥ ជាងក្រហម | Significance (p) |
|---|---|---|---|---|---|---|
| PII | 5792.65 | 5182.35 | 4557.35 | 4432.35 | 5447.05 | p<.001 |
| PIII | 6755.88 | 5263.24 | 4800.00 | 4755.88 | 6116.18 | p<.001 |
| PIV | 6388.24 | 5101.47 | 3777.94 | 3439.71 | 5858.82 | p<.001 |
| មើមដំឡូងមី | 6312.26 | 5182.35 | 4378.43 | 4209.31 | 5807.35 | |

P(Ⅱ)៖សាច់ផ្នែកក្បាលនៃមើម P(Ⅲ)៖សាច់ផ្នែកកណ្តាលនៃមើម P(Ⅳ)៖សាច់ផ្នែកចុងនៃមើម

ពូជដំឡូងឈើមានកំហាប់អ៊ីយ៉ុងនីត្រាតច្រើនជាងគេ រីឯពូជស្លឹកកញ្ឆាមានកំហាប់អ៊ីយ៉ុងនីត្រាតតិចជាងគេបង្អស់។

តារាងទី៤៖ កំហាប់អ៊ីយ៉ុង $NO_3^-$ (ppm)ក្នុងសាច់មើមដំឡូងមីអាយុបាន៨ខែ

| ប្រភេទ ភាគសំណាក | ពូជទី១ ដំឡូងឈើ | ពូជទី២ ត្រួយស្វាយ | ពូជទី៣ ត្រួយស | ពូជទី៤ ស្លឹកកញ្ឆា | ពូជទី៥ ជាងក្រហម | Significance (p) |
|---|---|---|---|---|---|---|
| PII | 3101.47 | 4623.53 | 3182.35 | 3844.12 | 5241.18 | p<.001 |
| PIII | 2719.12 | 5020.59 | 2888.24 | 2770.59 | 4675.00 | p<.001 |
| PIV | 2866.18 | 4579.41 | 3535.29 | 3189.71 | 5645.59 | p<.001 |
| មើមដំឡូងមី | 2895.59 | 4741.18 | 3201.96 | 3268.14 | 5187.26 | |

P(Ⅱ)៖សាច់ផ្នែកក្បាលនៃមើម P(Ⅲ)៖សាច់ផ្នែកកណ្តាលនៃមើម P(Ⅳ)៖សាច់ផ្នែកចុងនៃមើម

រាល់ពូជទាំងអស់មានកំហាប់អ៊ីយ៉ុងនីត្រាតថយចុះតាមកំនើននៃអាយុ

## វិធីជម្រះអ៊ីយ៉ុងស្យានួនិងនីត្រាតពីមើមដំឡូងមីស្រស់

តារាងទី៥៖ កំហាប់អ៊ីយ៉ុងស្យានួនិងនីត្រាតសល់ក្នុងសាច់មើមដំឡូងមី ស្ងោរ ចំហុយ និងធ្វើម្សៅមី

| ប្រភេទភាគសំណាក | ចំហុយ(ពូជ២) | ស្ងោរ(ពូជ២) | ម្សៅមី |
|---|---|---|---|
| សាច់មើមដំឡូងមី($CN^-$) | 3505.195ppm | 3057.143ppm | 93.50ppm |
| សាច់មើមដំឡូងមី($NO_3^-$) | 4042.647ppm | 1880.883ppm | 373.55ppm |

វិធីផលិតជាម្សៅដំឡូងមីអាចជម្រះអ៊ីយ៉ុងទាំងពីរបានច្រើនបំផុត

## អនុសាសន៍៖

១. អ្នកបរិភោគគួរតែស្វែងយល់ពីវិធីសាស្ត្រនៃការសម្អាតដំឡូងមីប្រកបដោយប្រសិទ្ធភាព និងជួយជំរុញឲ្យប្រើប្រាស់វិធីសាស្ត្រជម្រះជាតិពុលទាំងនេះមុនពេលយកដំឡូងមីទទួលទាន។

២. តាមការសិក្សាស្រាវជ្រាវឃើញថា ការយកមើមដំឡូងមីធ្វើឲ្យទៅជាម្សៅមីគឺអាចបញ្ចៀសនូវជាតិពុលទាំងពីរនេះបានយ៉ាងមានប្រសិទ្ធភាព បន្ទាប់មកវិធីស្ងោរក៏អាចជម្រះជាតិពុលបានច្រើនគួរសមដែរ រីឯវិធីចំហុយវិញពុំគួរអនុវត្តន៍ទេ។

៣. ដើម្បីជៀសវាងឥទ្ធិពលនៃផលប៉ះពាល់លើសុខភាព ពោលគឺការបំពុលដោយអ៊ីយ៉ុងស្យានួ និងនីត្រាត ប្រជាពលរដ្ឋអ្នកប្រើប្រាស់ទាំងអស់គួរត្រូវបានទទួលការបណ្តុះបណ្តាល និងណែនាំឲ្យយល់ដឹងនូវបញ្ហា

នេះ និងណែនាំពីវិធីសាស្ត្រប្រសើរជាងគេក្នុងការជម្រុះជាតិពុលអ៊ីយ៉ុងទាំងពីរនេះពីមើមដំឡូងមីស្រស់។

៤. ការដាំដំឡូងមីសម្រាប់ឧស្សាហកម្មគួរជ្រើសរើសពូជដែលមានកំហាប់ស្យានួខ្ពស់ ព្រោះវាផ្តល់ទិន្នផលខ្ពស់ ហើយធន់នឹងភាពរាំងស្ងួត។

## ឯកសារយោង


- Bradbury, M.G., Egan, S.V. and Bradbury, J.H.(1999) Determination of all forms of cyanogens in cassava root and cassava products using picrate paper kits. J. Sci. Food Agricul., 79, 593-601.
- Bradbury JH, Holloway WD. 1988. Cassava, M. esculenta. Chemistry of tropical root crops: significance for nutrition and agriculture in the pacific. Australian Centre for International Agricultural Research, monograph no. 6, Canberra, Australia, p 76-104.
- Cardoso AP, Mirione E, Ernesto M, Massaza F, Cliff J, Haque MR, Bradbury JH. 2005. Processing of cassava roots to remove cyanogens. J Food Comp Anal 18: 451-60.
- Cataldo. D.A., M. Maroon, L.E. Schrader and V.L. Youngs. 1975. Rapid colorimetric determination of nitrate in plant tissue by nitration of salicylic acid. P 71-80. Published online: 11 Nov 2008.
- Cock JH. 1985. Cassava: physiological basis. In: Cassava Research, Production andUtilization (Cock JH, Reyes JA, eds.),pages 33-62. Centro International de AgriculturaTropical(CIAT), Cali, Colombia.
- FSANZ (Food Standard Australia New Zealand). 2005. Cyanogenic Glycosides in Cassava and Bamboo Shoots.
- Julie A.Montagnac, Christopher R. Davis, Sherry A. Tanumihardjo, First published: 23 December 2008: Processing Techniques to Reduce Toxicity and Antinutrients of Cassava for Use as a Staple Food.
- Lufei Zhao and Yong Wang. 2017. Nitrate Assay for Plant Tissues. Bio Protoc. 2017 jan 20.
- Mlingi NLV, Bainbridge Z. 1994. Reduction of cyanide levels during sun-drying of cassava in Tanzania. Acta Hortic 375: 233-9.

# ការបង្រៀននិងរៀនមុខវិជ្ជាសិក្សាសង្គម
# នៅបឋមសិក្សា
# នៃនិក្ខេបបទថ្នាក់បណ្ឌិតវិទ្យាសាស្ត្រអប់រំ

បេក្ខជនបណ្ឌិត **សេង មុនីណា**
ជំនាញ៖វិទ្យាសាស្ត្រអប់រំ
ជំនានទី៤ វគ្គទី១ នៃរាជបណ្ឌិត្យសភាកម្ពុជា

## ១- សេចក្តីផ្តើម

នាសតវត្សទី២១ ជាសម័យកាលមួយដែលចរន្តនៃសាកលភាវូបនីយកម្ម កំពុងតែមានសន្ទុះយ៉ាងខ្លាំងក្លាគួរកត់សម្គាល់។ ចរន្តនេះ បានជំរុញឱ្យពិភពលោកស្ថិតនៅក្នុងសភាពបែបប្រកួតប្រជែងគ្នាស្ទើរគ្រប់វិស័យ។ មហាត្មៈ គន្ធី ជាទស្សនវិទូអហិង្សា ដែលបានលើកឡើងនូវគោលការណ៍សីលធម៌ទាំង៧ប្រការ ដែលផ្តោតយ៉ាងសំខាន់លើតម្លៃនៃសីលធម៌ជាចម្បង។ គោលការណ៍ទី៦របស់លោកបានលាតត្រដាងនូវតម្លៃសីលធម៌ជាសកល ដែលបង្ហាញពីតម្លៃនៃវិទ្យាសាស្ត្រគ្មានសីលធម៌ជាបាបកម្មសង្គម[១]។

សម័យសង្គមរាស្ត្រនិយម ក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះវរបិតា **នរោត្តម សីហនុ** បានប្រែក្លាយប្រទេសកម្ពុជាឱ្យមានការអភិវឌ្ឍឡើងវិញ ជាពិសេសនោះគឺវិស័យសិក្សាធិការជាតិ ដែលជាគោលដៅដ៏សំខាន់ជាងគេ មួយក្នុងចំណោមគោលការណ៍ដឹកនាំប្រទេស។ ក៏ប៉ុន្តែមិនបានយូរប៉ុន្មានសម័យនោះត្រូវបានផ្តួលរលំដោយសារតែមនោគមន៍វិជ្ជារបស់ពួកមហាអំណាចសេរីនិងកុម្មុយនីស្តនាំឱ្យរបបសាធារណរដ្ឋខ្មែរ(១៩៧០-១៩៧៥)កើតឡើង[២]។ ប៉ុន្តែវិស័យអប់រំនៅក្នុង**របបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)** ប្រព័ន្ធអប់រំត្រូវបានបំផ្លាញចោលសាលារៀនត្រូវបានបិទទ្វារ គ្រូបង្រៀនត្រូវបានគេរំលាយក្របខណ្ឌ ហើយកុមារត្រូវបានអង្គការចាត់ទុកជាកូនដោយបណ្តុះនូវមនោគមនវិជ្ជាថាត្រូវតែស្រឡាញ់ ដឹងគុណអង្គការតែមួយគត់ត្រូវតែមានឆន្ទៈនិងជឿជាក់លើអង្គការតែមួយគត់ ត្រូវយកការណ៍ពីឪពុកម្តាយរបស់ខ្លួន ហើយពេលខ្លះកុមារហ៊ានសម្លាប់ឪពុកម្តាយខ្លួនឯងដោយចោទថាជាខ្មាំងនិងកុមារខ្លះត្រូវហ៊ានធ្វើពលីកម្មចំពោះអង្គការ។ ប្រព័ន្ធអប់រំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានភាពគ្រោះថ្នាក់ចំពោះកុមារ ដោយកុមារត្រូវបានគេធ្វើការដូចជារើសអាចម៍គោ កាត់ទន្រ្ទានខេត្ត ប្រមូល

[១] សុខ សុត្ថាលះ ***មហាត្មៈ គន្ធី ទស្សនវិជ្ជាអហិង្សា*** ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ ឆ្នាំ១៩៩៦ ទំព័រទី១-៤៩
[២] ក្រសួងអប់រំ យុវជន និងកីឡា៖ ***ប្រវត្តិវិទ្យា ថ្នាក់ទី១២*** គ្រឹះស្ថានបោះពុម្ព និងការផ្សាយ ភ្នំពេញ ឆ្នាំ២០១១ ទំព័រ ១៣២

ជីលាមកមនុស្ស បញ្ជូនសម្ភារៈសឹកទៅសមរភូមិ និងកុមារខ្លះត្រូវបានគេជ្រើសរើសឱ្យចូលបម្រើការក្នុងជួរកងទ័ពខ្មែរក្រហម[៣]។ អំពើដ៏សាហាវព្រៃផ្សៃបែបនេះ ក៏ធ្លាប់កើតមាន ចំពោះកុមារបន្ទាប់ពីសម័យសង្គ្រាមលោកលើកទី២(១៩៣៩-១៩៤៥) ដែលបង្កឱ្យមានវិនាសកម្មលើពួកណាហ្ស៊ី ដែលកើតចេញពីគំនុំ កុមារត្រូវបានគេបង្ខំចេញពីកន្លែងមួយទៅកន្លែងមួយដោយប្រើអំពើហិង្សា[៤]។ របបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) បានដួលរលំផុតទៅការដឹកនាំថ្មីបន្តក្នុង**របបសាធារណរដ្ឋប្រជាមានិតកម្ពុជា(១៩៧៩-១៩៨៩)** បានបន្តកសាងប្រទេសជាតិឡើងវិញដោយត្រូវប្រឈមនឹងបញ្ហាលំបាកជាច្រើន ពិសេសក្នុងវិស័យអប់រំមានដូចជាកង្វះខាតធនធានមនុស្សធ្វើជាគ្រូបង្រៀនសម្ភារសិក្សា និងអគារជាដើម។ ដោយសារតែមានការចូលរួមពីសំណាក់អ្នកចេះដឹង ដែលនៅសេសសល់ពីសង្គមចាស់បានស្ម័គ្រចិត្តចូលមកបម្រើការជាមួយផ្នែកអប់រំទើបនាំឱ្យការសិក្សាចាប់ផ្ដើមមានសន្ទុះឡើងវិញ។ បទពិសោធមេរៀន ដែលកម្ពុជាពុំអាចភ្លេចបាននិងត្រូវបណ្ដុះស្មារតីសិស្សានុសិស្ស ពិសេសកុមារឱ្យមានចំណេះដឹងនិងត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍សីលធម៌ជាចាំបាច់ ដែលត្រូវតែមានការបណ្ដុះបណ្ដាលច្បាស់លាស់។ ខ្លឹមសារនៃគោលនយោបាយអប់រំក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានបង្កជាលក្ខណៈចាំបាច់ ដើម្បីធានាសិទ្ធិចូលរៀនដល់កុមារ ដែលដល់វ័យសិក្សានិងត្រូវប្រយុទ្ធប្រឆាំងនឹងគ្រោះមិនចេះអក្សរ បំប៉នវិជ្ជាដល់ប្រជាជនដោយបំផុសគំនិត "រៀនហើយរៀនទៀត នោះ ជាផ្នែកមួយនៃការអប់រំមនុស្សចាស់។ សាលារៀន ធ្វើជាកន្លែងផ្សារភ្ជាប់ការអប់រំទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ។ គោលបំណងរបស់ក្រសួងអប់រំ បានចខិតខំធ្វើការដើម្បីធានាដល់ការអប់រំនៅសិក្សាកម្រិត១ នូវការរៀនសូត្ររបស់កូនចៅនូវសមាសភាគទាំង៥ គឺ៖ (១) ការអប់រំបញ្ញាស្មារតី (២)ការអប់រំមនោគមវិជ្ជា សីលធម៌បដិវត្ត (៣)ការអប់រំពលកម្មបង្កបង្កើនផល (៤)ការអប់រំកាយ និង(៥)ការអប់រំសិល្បវិទ្យា។ កម្មវិធីសិក្សានៅសាលារៀន បានកំណត់យកមុខវិជ្ជាសីលធម៌មកធ្វើជាមុខវិជ្ជាសិក្សាគោលនាំមុខគេនៅកម្រិតបឋមសិក្សា[៥]។

---

[៣] ក្រសួងអប់រំ យុវជន និងកីឡា៖ *ប្រវត្តិវិទ្យា"សម័យអាណានិគមបារាំង-ព្រះរាជាណាចក្រកម្ពុជាទី២"* ភ្នំពេញ ២០១៧ ទំព័រទី៤៣

[៤] មជ្ឈមណ្ឌលឯកសារកម្ពុជា៖ ***វគ្គបណ្ដុះបណ្ដាលស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)ថ្នាក់ខេត្ត កម្រិតមធ្យមសិក្សា*** ភ្នំពេញ ឆ្នាំ២០១៥? ទំព័រទី៦

[៥] ចាន់ រដ្ឋសុផា៖ ***ប្រវត្តិអប់រំកម្ពុជាពីឆ្នាំ១៩៧៩ ដល់សព្វថ្ងៃ ភាគទី៦*** ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ ២០១២ ទំព័រទី៣-៩

ការអប់រំសីលធម៌ដល់កុមារនៅក្នុងសាលារៀនផ្តល់នូវសារៈសំខាន់ណាស់ ព្រោះយើងទាំងអស់គ្នាបានជ្រាបហើយថាសព្វថ្ងៃនេះសង្គមខ្មែរ ហាក់ដូចជាមិនសូវយកចិត្តទុកដាក់ដល់ការអភិវឌ្ឍប្រាជ្ញា ស្មារតីសីលធម៌ និងមនុស្សធម៌។ មនុស្សមួយចំនួនគិតតែអំពីទ្រព្យសម្បត្តិការងារនិងការងារនោះកើតឡើងក្នុងអំពើអសីលធម៌ក៏ដោយ ពោលគឺគេឱ្យតម្លៃតែទៅលើភាពហ៊ឺហា ខ្ពស់មុខ ខ្ពស់មាត់សម្រាប់ខ្លួននិងក្រុមគ្រួសារគេតែប៉ុណ្ណោះ។ កត្តាទាំងនេះបណ្តាលមកពីចិត្តលោភៈ ទោសៈ មោហៈ ខ្វះសីលធម៌ ដែលគ្របសង្កត់លើខ្លួនគេ ធ្វើឱ្យពួកគេមើលឃើញតម្លៃពិតរបស់សង្គមនិងរបស់មនុស្សនៅលើពិភពផែនដីនេះ។

ដូចនេះ គេសង្កេតឃើញថា នៅក្នុងសង្គមជាតិយើងគេតែងជួបប្រទះនូវការបង្កអំពើហិង្សា និងការឈ្នានីសមិនឈប់ឈរ ដែលជារូបភាពធ្វើឱ្យសង្គមជាតិយើង អាប់ឱនកិត្តិយសពីមួយថ្ងៃទៅមួយថ្ងៃ។ ដើម្បីចូលរួមចំណែកកាត់បន្ថយ ឬលុបបំបាត់នូវរាល់កត្តាអសកម្ម និងទង្វើអសីលធម៌ទាំងឡាយដូចបានរៀបរាប់ត្រួសៗខាងលើ ការអប់រំសីលធម៌ដល់កុមារនៅក្នុងសាលារៀនមានសារៈសំខាន់ខ្លាំងណាស់គឺ៖ (១) អភិវឌ្ឍបុគ្គលិកលក្ខណៈកុមារ និងយុវជនឱ្យបានល្អប្រសើរ ចេះគោរពច្បាប់ស្គាល់ពីតួនាទីរបស់ខ្លួនជាប្រជាពលរដ្ឋនាពេលអនាគតស័ក្តិសមជាទំពាំងស្នងឫស្សី និងជាសសរទ្រូងដ៏រឹងមាំរបស់ប្រទេសជាតិ។(២) អប់រំយុវជនឱ្យចេះយោគយល់គ្នា ស្គាល់តម្លៃ សន្តិភាព ស្គាល់ន័យនៃជីវិតខាងផ្លូវលោក និងផ្លូវធម៌។ (៣)អប់រំយុវជនឱ្យរៀនរស់នៅឱ្យបានសុខដុមរម្យនាជាមួយអ្នកដទៃនៅក្នុងសង្គមទោះបីមាននិន្នាការនយោបាយ សាសនា វប្បធម៌ ផ្សេងពីគ្នាក៏ដោយ និង(៤) អប់រំយុវជនឱ្យចេះឈឺឆ្អាលចំពោះសង្គមក្នុងបំណងឱ្យសង្គមមនុស្ស មានការអភិវឌ្ឍពីគ្រប់វិស័យទាំងផ្នែកស្មារតី និងសម្ភារៈ។ ជាពិសេសទៅទៀតនោះ ត្រូវបំពេញនូវតួនាទី៖ ស្គាល់ គោរពខ្លួនឯង និងអ្នកដទៃ ស្គាល់តម្លៃសិទ្ធិ សេរីភាពជាមូលដ្ឋាន ស្គាល់ពីជីវភាពពិត និងការអភិវឌ្ឍសង្គម។

# ២- ការបង្រៀន និងរៀនមុខវិជ្ជាសិក្សាសង្គមនៅបឋមសិក្សា

## ២.១- កម្មវិធីសិក្សាមុខវិជ្ជាសិក្សាសង្គមនៅបឋមសិក្សា

### ២.១.១- កម្មវិធីសិក្សាគោល

កម្មសិក្សាសីលធម៌នៅបឋមសិក្សាចាប់ពីឆ្នាំ១៩៦៨មក ត្រូវបានរៀបចំឡើងមក ជាខ្លឹមសារក្នុងសៀវភៅតែម្តង។ ដោយថ្នាក់ទី១ (កុមារដ្ឋាន) ត្រូវបានកំណត់ខ្លឹមសារឱ្យស្គាល់ពីសញ្ញាណមូលដ្ឋានគ្រឹះនៃសីលធម៌ ថ្នាក់ទី២(បរិច្ឆេណដ្ឋាន) ត្រូវបានកំណត់ខ្លឹមសារដោយស្គាល់ពីភាពជាពលរដ្ឋល្អ និងការរស់នៅល្អក្នុងសង្គម ថ្នាក់ទី៣ (អាទិកដ្ឋាន) កុមារត្រូវដឹងពីតួនាទីនិងសីលធម៌ចំពោះអ្នកដទៃបន្ថែមទៀត។

ដោយឡែកកម្មវិធីសិក្សាគោល ដែលត្រូវបានដាក់ប្រើប្រាស់ចាប់ពីឆ្នាំសិក្សា២០០៦មកដល់ឆ្នាំ២០១៥ ខ្លឹមសារនៃកម្មវិធីសិក្សាគោលបានកំណត់នូវគោលដៅ២គឺគោលដៅអប់រំជាតិ និងគោលដៅចំណេះទូទៅ។ គោលដៅអប់រំជាតិនៃកម្មវិធីសិក្សាគោល នៅក្នុងមុខវិជ្ជា

សិក្សាសង្គមមានគោលដៅដើម្បីកសាងមនុស្សឱ្យមានការរីកចម្រើន ពេញលេញ លូតលាស់គ្រប់ផ្នែកព្រមៗគ្នា ដោយមានតុល្យភាពរវាងប្រាជ្ញា ស្មារតី សញ្ចេតនា និងរូបកាយ[៦]។ រីឯគោលដៅអប់រំចំណេះទូទៅ គាំទ្រនិងទ្រទ្រង់ដល់គោលដៅអប់រំជាតិក្នុងការបណ្តុះបណ្តាលចំណេះដឹង បំណិន តម្លៃ បុគ្គលិកលក្ខណៈ ពិសោធការងារ ពិសោធជីវិត គឺធ្វើយ៉ាងណាឱ្យមានមូលដ្ឋានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសង្គមជាតិនិងសង្គមសកល។ ម្យ៉ាងទៀតវិញ វា មានគោលដៅអប់រំមនុស្សឱ្យក្លាយទៅជាពលរដ្ឋថ្លៃថ្នូរ ពលករល្អ[៧]។

ដោយឡែកមកឆ្នាំ២០១៥ ដល់បច្ចុប្បន្ន ដោយគុណភាពនៃការអប់រំទទួលឥទ្ធិពលពីកត្តាជាច្រើនទើបក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវកម្មវិធីសិក្សាគោលសម្រាប់ឆ្នាំ២០១៥មកក្រោយនូវមូលដ្ឋានទស្សនៈ និងចក្ខុវិស័យថ្មីស្របតាមនិន្នាការអប់រំសកល រដ្ឋធម្មនុញ្ញ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ច្បាប់ស្តីពីការអប់រំ ផែនការជាតិសម្រាប់អប់រំទាំងអស់គ្នា ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨ និងធ្វើការឆ្លុះបញ្ចាំងអំពីបទពិសោធនៃការអនុវត្តកម្មវិធីសិក្សាចំណេះទូទៅឆ្នាំ២០០៦ ដល់ឆ្នាំ២០២២ផងដែរ[៨]។

### ២.១.២- កម្មវិធីសិក្សាលម្អិត

កម្មវិធីសិក្សាលម្អិត ត្រូវមានខ្លឹមសារឆ្លើយតបនឹងកម្មវិធីសិក្សាគោល ដែលបានដាក់ចេញ។ ខ្លឹមសារនៃកម្មវិធីសិក្សាលម្អិតជាធាតុចូលតូច ដែលមានក្នុងមេរៀនត្រូវបំពេញនូវចំណុចចង់បានរបស់កម្មវិធីសិក្សាគោលទាំងគោលដៅអប់រំជាតិ និងគោលដៅអប់រំមូលដ្ឋាន។ មុខវិជ្ជាសីលធម៌ពលរដ្ឋ ត្រូវបានកំណត់ឱ្យនៅក្នុងសៀវភៅកម្មវិធីសិក្សាលម្អិតតែ១ចំណុចគឺថ្នាក់ទី១-៣ និងថ្នាក់ទី៤-៦។ គោលដៅលម្អិតក្នុងកម្មវិធីសិក្សា គឺផ្តោតជាសំខាន់គឺការបណ្តុះនូវគុណធម៌ផ្ទាល់ខ្លួន និងអ្នកដទៃ[៩]។ កំណែទម្រង់កម្មវិធីសិក្សាលម្អិតឆ្នាំ២០១៨ លើមុខវិជ្ជាសិក្សាសង្គមនៅបឋមសិក្សាបានលម្អិតនូវខ្លឹមសារដោយអប់រំសិស្សឱ្យស្គាល់ពីតម្លៃនៃការទទួលខុសត្រូវលើសកម្មភាព និងការសម្រេចចិត្តរបស់ខ្លួន ជឿជាក់លើខ្លួនឯង ត្រូវមានឥរិយាបថវិជ្ជមានចំពោះអ្នកដទៃ មានសីលធម៌ មានសុជីវធម៌ក្នុងការរស់នៅ ចេះដោះស្រាយបញ្ហា ក្នុងគ្រួសារ សហគមន៍ សង្គមជាតិនិងមានទំនាក់ទំនងល្អជាមួយមនុស្សដទៃទៀត[១០]។

---

[៦] ក្រសួងអប់រំ យុវជន និងកីឡា៖ ***កម្មវិធីសិក្សាគោលសម្រាប់អប់រំកម្រិតមូលដ្ឋានចំណេះទូទៅ***នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ ភ្នំពេញ ឆ្នាំ២០០៦ ទំព័រទី២

[៧] -ដ- ទំព័រទី២

[៨] ក្រសួងអប់រំ យុវជន និងកីឡា៖ ***ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងការអប់រំបច្ចេកទេស***នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ភ្នំពេញ ឆ្នាំ២០១៥ទំព័រទីiv-v

[៩] ក្រសួងអប់រំ យុវជន និងកីឡា៖ ***កម្មវិធីសិក្សាលម្អិតសិក្សាសង្គម សម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ***នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ ភ្នំពេញ ឆ្នាំ២០០៦ទំព័រទី២-២៣

[១០] ក្រសួងអប់រំ យុវជន និងកីឡា៖ ***កម្មវិធីសិក្សាលម្អិតសិក្សាសង្គម កម្រិតបឋមសិក្សា*** ប្រកាសលេខ ៥០៥. អយក. ប្រ.ក ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨ ភ្នំពេញ ទំព័រទី១-២

ការសម្រេចឱ្យមាននូវខ្លឹមសារនេះ គណៈកម្មការនិពន្ធបានរៀបរៀងជាមេរៀនដើម្បី ឱ្យសិស្សបានសិក្សាឈ្វេងយល់ទទួលបាននូវចំណេះដឹង ដើម្បីទទួលបាននូវបំណិនសម្បទា វិជ្ជាសម្បទា និងចរិយាសម្បទា[១១]។

### ២.២- សៀវភៅសិក្សាមុខវិជ្ជាសិក្សាសង្គមនៅបឋមសិក្សា

#### ២.២.១- សៀវភៅសិក្សាសង្គមសម្រាប់គ្រូ

សៀវភៅសិក្សាសង្គមសម្រាប់គ្រូ ជាឯកសារជំនួយគ្រូបានក្លាយជាជំនួយការដ៏សំខាន់ក្នុងការបំពេញ នូវចំណុចខ្វះខាតឬភាពស្រពិចស្រពិលទៅតាមមេរៀននីមួយៗ។ វាមិនមែនជាកិច្ចតែងការ ដែលគ្រូត្រូវតែអនុវត្តតាមទាំងស្រុងទេ។ សៀវភៅសម្រាប់គ្រូមុខវិជ្ជាសិក្សាសង្គម ដែលប្រើប្រាស់នៅឆ្នាំសិក្សា២០០៦មក ចេញផ្សាយឱ្យប្រើប្រាស់មុនគេគឺមានតែសិក្សាសង្គមថ្នាក់ទី១តែប៉ុណ្ណោះ។ សៀវភៅសិក្សាសង្គមសម្រាប់គ្រូ ដែលប្រើប្រាស់នៅឆ្នាំសិក្សា២០១៥មកមានដូចជា៖

ថ្នាក់ទី១ បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ៣៨០ អយក.ប្រក. ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨ និងបានបោះពុម្ពផ្សាយលើកទី១ដោយគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយនៅឆ្នាំ២០០៨។

ថ្នាក់ទី២ បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ១៧៤ អយក.ប្រក. ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ និងបានបោះពុម្ពផ្សាយលើកទី១ដោយគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយនៅឆ្នាំ២០០៨។

ថ្នាក់ទី៣ បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ៣១១៩ អយក.ប្រក. ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១០ និងបានបោះពុម្ពផ្សាយដោយគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយនៅឆ្នាំ២០២០។

ថ្នាក់ទី៦ បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ២៩១៦ អយក.ប្រក. ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៣ និងបានបោះពុម្ពផ្សាយដោយគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយនៅឆ្នាំ២០២០។

ដោយឡែកសៀវភៅសិក្សាសង្គមសម្រាប់គ្រូកម្រិតទី៤ និងទី៥ គឺពុំទាន់មានចេញផ្សាយសម្រាប់ប្រើប្រាស់នៅតាមសាលារៀនសាធារណៈនៅឡើយទេ។

#### ២.២.២- សៀវភៅសិក្សាសង្គមសម្រាប់សិស្ស

សៀវភៅសិក្សាសង្គម សម្រាប់សិស្សពីឆ្នាំសិក្សា២០០៦កន្លងទៅមានគ្រប់កម្រិតថ្នាក់ចាប់ពីថ្នាក់ទី១-៦ ដោយសៀវភៅសិក្សានៅពេលនោះត្រូវបានបោះពុម្ពជាសៀវភៅមានរូបភាពពណ៌ដ៏ស្រស់ស្អាត គ្រប់មេរៀនមានផ្ទាំងរូបភាពបង្កប់ដោយខ្លឹមសារ និងមានភាពទាក់ទាញ

[១១] ក្រសួងអប់រំ យុវជន និងកីឡា៖ ***កម្មវិធីសិក្សាលម្អិតសិក្សាសង្គម កម្រិតបឋមសិក្សា*** ប្រកាសលេខ ៥០៥. អយក. ប្រ.ក ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨ ភ្នំពេញ ទំព័រទី២

ចំណាប់អារម្មណ៍សិស្សចង់អាន ចង់មើល។ ខ្លឹមសារមេរៀនមានអក្សរតិចតែខ្លឹមសារ អត្ថន័យទូលំទូលាយ ផ្ទុយមកវិញការបោះពុម្ពសៀវភៅសិក្សាសង្គមនៅពេលក្រោយមក នេះត្រូវបានរៀបចំឡើងដោយសៀវភៅទាំងនោះមានរូបភាពសខ្មៅធម្មតា មានអក្សរច្រើន និងមិនសូវមានភាពទាក់ទាញ ហើយខ្លឹមសារក្នុងរូបភាពពុំបង្ហាញឱ្យសិស្សមានការគិតបាន ទូលំទូលាយ និងឆាប់យល់ឡើយ។

ដូច្នេះសៀវភៅសិក្សាសង្គមនៅកម្រិតបឋមសិក្សា ដែលបានបោះពុម្ពថ្មីគឺមិនមានភាពទាក់ទាញសិស្សឱ្យចូលចិត្តបើកមើល ចង់អានទេ។ ខ្លឹមសារនៃសៀវភៅត្រូវបានកែប្រែទៅតាមសម័យកាលនៃនិន្នាការអប់រំក្នុងសកលលោក ដែលមានចែងក្នុងកម្មវិធីសិក្សាគោលនៃមុខវិជ្ជាសិក្សាសង្គមឆ្នាំ២០១៨។

### ២.៣- វិធីសាស្ត្របង្រៀនមុខវិជ្ជាសិក្សាសង្គមនៅបឋមសិក្សា

#### ២.៣.១- វិធីសាស្ត្របង្រៀនសិក្សាសង្គមរបស់គ្រូឧទ្ទេស

វិធីសាស្ត្របង្រៀនមុខវិជ្ជាសិក្សាសង្គមនៅកម្រិតបឋមសិក្សា តាមរយៈឯកសារនៅក្នុងកម្មវិធីសិក្សាគោល ត្រូវបានធ្វើឡើងតាមវិធីសាស្ត្របង្រៀនបែបទំនើបមានដូចជា វិធីសហការ វិធីសម្ភាស វិធីដោះស្រាយបញ្ហា ការសិក្សាស្រាវជ្រាវមេរៀន ការសិក្សាតាមបែបរិះរក។

ឧទាហរណ៍៖ ក្នុងមេរៀនសីលធម៌ លំនាំនៃការបង្រៀនតាមបែបរិះរក៖

ជំហានទី១ ៖ កំណត់បញ្ហា (សំណួរគន្លឹះ)

ជំហានទី២ ៖ បង្កើតសម្មតិកម្ម

ជំហានទី៣ ៖ តេស្តសម្មតិកម្ម- ពិសោធ

ជំហានទី៤ ៖ សង្កេត និងវាស់វែង- លទ្ធផល

ជំហានទី៥ ៖ វិភាគ និងទាញសេចក្តីសន្និដ្ឋាន[១២]។

សរុបមក លំនាំនៃការបង្រៀនមុខវិជ្ជាសិក្សាសង្គមនៅបឋមសិក្សាតាមបែបវិធីសាស្ត្រថ្មីត្រូវមានភាពបត់បែនទៅតាមមេរៀន កម្រិតថ្នាក់ផងដែរ។ ឯកសារទាំងនេះត្រូវយកមកបណ្តុះបណ្តាលដល់គរុសិស្សនៅឆ្នាំសិក្សាទី១ និងទី២ ដែលត្រូវបំពេញកម្មសិក្សាគរុកោសល្យចំនួន ២លើកនិងជាបំណិនក្នុងការចេញទៅបម្រើការនៅសាលាគោលដៅដោយប្រើប្រាស់ វិធីសាស្ត្រឱ្យបានសមស្រប។

#### ២.៣.២- វិធីសាស្ត្របង្រៀនក្នុងសៀវភៅគ្រូ

វិធីសាស្ត្របង្រៀន ដែលមាននៅក្នុងសៀវភៅសម្រាប់គ្រូត្រូវបានរៀបចំឡើងដោយប្រើលំនាំនៃការបង្រៀនខុសៗគ្នាទៅតាមកម្រិតថ្នាក់។ ចំពោះថ្នាក់ទី១ មានវត្ថុបំណង ព័ត៌មានជំនួយ សម្ភារៈបង្រៀន លំនាំបង្រៀន និងវង្វាយតម្លៃ។ ថ្នាក់ទី២ មានខ្លឹមសារ ព័ត៌មានជំនួយ

---

[១២] លឹម វុត្ថា៖ ***វិធីសាស្ត្របង្រៀនសិក្សាសង្គមតាមបែបរិះរក(IBL)*** គ្រូឧទ្ទេសចិត្ត-គរុកោសល្យនៃសាលាគរុកោ-សល្យ និងវិក្រឹតការខេត្តសៀមរាប ២០១៩

គរុកោសល្យ "វត្ថុបំណង ព័ត៌មានជំនួយ សម្ភារៈបង្រៀន លំនាំបង្រៀន និងវង្វាយតម្លៃ"។ ថ្នាក់ទី៣ ព័ត៌មានជំនួយ វត្ថុបំណង ពាក្យគន្លឹះ សម្ភារឧបទេស លំនាំបង្រៀន"សកម្មភាព ទាក់ទងនឹងខ្លឹមសារ សកម្មភាពទាក់ទងនឹងការពង្រឹង និងពង្រីកចំណេះដឹង បណ្តាំផ្ញើ។ ថ្នាក់ទី៦ វត្ថុបំណង សម្ភារឧបទេស វិធីបង្រៀន "សកម្មភាពផ្តើម ការពិភាក្សា អំណាន ការវាយតម្លៃ បណ្តាំផ្ញើ ឬកិច្ចការផ្ទះ"។

ផ្អែកលើខ្លឹមសារនៃលំនាំបង្រៀនសិក្សាសង្គមក្នុងសៀវភៅគ្រូ បានបង្ហាញពីរបៀបនៃការបង្រៀនតាមបែបបុរាណ ដែលផ្ទុយគ្នានឹងការកំណត់ក្នុងកម្មវិធីសិក្សាលម្អិត។

## ២.៤- សមត្ថភាពគ្រូបង្រៀនកម្រិតបឋមសិក្សា

### ២.៤.១- គ្រូបង្រៀនក្របខណ្ឌរដ្ឋនៅបឋមសិក្សា

គ្រូបង្រៀននៅកម្រិតបឋមសិក្សារដ្ឋត្រូវតែជាគ្រូ ដែលបានឆ្លងកាត់ការប្រឡងនិងរៀនវគ្គគរុកោសល្យ និងបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់។ មុនឆ្នាំ២០១៤ គ្រូបង្រៀនកម្រិតបឋម-សិក្សាត្រូវមានកម្រិតវប្បធម៌ជាប់ឬធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនិងមានអាយុ១៨ឆ្នាំឡើង ហើយត្រូវប្រឡងជាប់វិញ្ញាសាសរសេរក្នុងការប្រឡងប្រជែង។ តែក្រោយឆ្នាំ២០១៤ គ្រូបង្រៀនកម្រិតបឋមសិក្សា ត្រូវតែមានកម្រិតវប្បធម៌ជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនិងមានអាយុ១៨ឆ្នាំឡើង។

### ២.៤.២- គ្រូបង្រៀនឯកជននៅបឋមសិក្សា

គ្រូបង្រៀនកម្រិតបឋមសិក្សាអាចបង្រៀននៅសាលារៀនឯកជនបាន តែគ្រូមិនមានក្របខណ្ឌពុំអាចបង្រៀននៅសាលាបឋមសិក្សារដ្ឋបានឡើយ លើកលែងតែជាគ្រូបង្រៀនកិច្ច-សន្យា។ សាលារៀនឯកជនកម្រិតបឋមសិក្សាត្រូវការជ្រើសរើសបុគ្គលិកបម្រើការជាគ្រូកម្រិតបឋមសិក្សាដោយការដាក់ពាក្យ សម្ភាស និងធ្វើតេស្តជាប់។

## ២.៥- វង្វាយតម្លៃ

ការបង្រៀននិងរៀនមុខវិជ្ជាសីលធម៌ពលរដ្ឋនៅបឋមសិក្សាបាននិងកំពុង មានការកែ-ទម្រង់នៃការបង្រៀន ក្នុងនោះដែរវិធីសាស្ត្របង្រៀនតាមបែបទំនើប បាននិងកំពុងជំរុញតែឱ្យលោកគ្រូ អ្នកគ្រូធ្វើយ៉ាងណាបង្រៀនដោយប្រើប្រាស់វិធីសាស្ត្រនោះឱ្យមានប្រសិទ្ធភាព។ តែទោះជាយ៉ាងនេះក្តី យើងសង្កេតឃើញលទ្ធផលនៃការសិក្សាសីលធម៌ពលរដ្ឋរបស់សិស្សនៅតែមានកម្រិត ដែលទាមទារឱ្យមានការចូលរួមក្នុងនាមជាអ្នកពាក់ព័ន្ធ ក្នុងការជួយជំរុញកុមារឱ្យមានសីលធម៌ល្អ ស្របតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា។

# ៣- សេចក្តីសន្និដ្ឋាន

ការអប់រំសីលធម៌ពលរដ្ឋ សម្រាប់កុមាររៀននៅបឋមសិក្សានៅតែត្រូវការជាចាំបាច់នូវអ្នកពាក់ព័ន្ធ ដែលជាធាតុចូលដ៏សំខាន់ក្នុងការលើកកម្ពស់សីលធម៌សង្គមតាមរយៈការអប់រំ ពីកុមារភាពឡើងទៅ។ ដូចនេះការយកចិត្តទុកដាក់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងការធ្វើ

កំណែទម្រង់ស៊ីជម្រៅលើការបង្រៀននិងរៀនសីលធម៌ពលរដ្ឋ ជាមួយនឹងការប្រើវិធីសាស្ត្រនៃការបង្រៀនប្រកបដោយប្រសិទ្ធភាព។ គុណភាពនៃសីលធម៌សង្គមយើង ត្រូវអាស្រ័យលើធនធានកុមារជាអ្នកបន្តវេនដោយត្រូវការជាចាំបាច់គឺអ្នកអប់រំ ដែលមានប្រសិទ្ធភាពឆ្លើយតបនិងទប់ស្កាត់បាននូវភាពអសីលធម៌។

# គន្ថនិទ្ទេស

- ស៊ន សំណាង៖ ***ប្រវត្តិសាស្ត្រសកលលោក*** ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ ឆ្នាំ?
- ក្រសួងអប់រំជាតិ៖ សីលធម៌ថ្នាក់ទី៥ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ ភ្នំពេញ ឆ្នាំ១៩៨៨
- ក្រសួងអប់រំជាតិ៖ សីលធម៌ថ្នាក់ទី១ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ ភ្នំពេញ ឆ្នាំ១៩៨៩
- យ៉ង់ ធី និងស៊ន សំណាង៖ ប្រវត្តិនៃការអប់រំបឋមសិក្សានិងមធ្យមសិក្សានៅកម្ពុជាពីសម័យបុរាណមកដល់បច្ចុប្បន្ន ១៩៩៨-១៩៩៩ ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ ឆ្នាំ ១៩៨៩
- សុខ សុត្ថាលះ មហាគ្ន: គន្ធី ទស្សនវិជ្ជាអហិង្សា ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ ឆ្នាំ ១៩៩៦
- អង្គការសហប្រជាជាតិ៖ អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែម ខែមិថុនា ២០០៩
- ខ្លូត ធីតា៖ ***មូលដ្ឋានគ្រឹះនៃសីលវិទ្យាសកលលោក*** ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ ឆ្នាំ២០០២
- ក្រសួងអប់រំ យុវជន និងកីឡា៖ ***ទស្សនាវដ្តីគ្រូបង្រៀន ភាគ១៩*** សមាគមអ្នកសិក្សាខ្មែរ ភ្នំពេញ ឆ្នាំ២០០៤
- ក្រសួងអប់រំ យុវជន និងកីឡា៖ ***ទស្សនាវដ្តីគ្រូបង្រៀន ភាគ២២***សមាគមអ្នកសិក្សាខ្មែរ ភ្នំពេញ ឆ្នាំ២០០៤
- ក្រសួងអប់រំ យុវជន និងកីឡា៖ ***កម្មវិធីសិក្សាគោលសម្រាប់អប់រំកម្រិតមូលដ្ឋានចំណេះ-ទូទៅ***នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ ភ្នំពេញ ឆ្នាំ២០០៦
- ក្រសួងអប់រំ យុវជន និងកីឡា៖ ***កម្មវិធីសិក្សាលម្អិតសិក្សាសង្គម សម្រាប់អប់រំមូលដ្ឋាន-ចំណេះទូទៅ***នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ ភ្នំពេញ ឆ្នាំ២០០៦
- ព្រះរាជក្រមលេខ នស/រកម/០៧/០១/១១៖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៦៦-៦៨
- ក្រសួងអប់រំ យុវជន និងកីឡា៖ ប្រវត្តិវិទ្យា ថ្នាក់ទី១២ គ្រឹះស្ថានបោះពុម្ព និងការផ្សាយ ភ្នំពេញ ឆ្នាំ២០១១
- ក្រសួងអប់រំ យុវជន និងកីឡា៖ ***ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងការអប់រំបច្ចេកទេស***នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ភ្នំពេញ ឆ្នាំ២០១៥

- ក្រសួងអប់រំ យុវជន និងកីឡា៖ ***កម្មវិធីសិក្សាលម្អិតសិក្សាសង្គម កម្រិតបឋមសិក្សា*** ប្រកាសលេខ ៥០៥.អយក. ប្រ.ក ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨ ភ្នំពេញ
- ក្រសួងអប់រំ យុវជន និងកីឡា៖ ***កម្មវិធីសិក្សាលម្អិតសិក្សាសង្គម កម្រិតបឋមសិក្សា*** ប្រកាសលេខ ៥០៥.អយក. ប្រ.ក ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨ ភ្នំពេញ
- លឹម វុត្ថា៖ ***វិធីសាស្ត្របង្រៀនសិក្សាសង្គមតាមបែបរិះរក(IBL)*** គ្រូឧទ្ទេសចិត្ត-គរុកោសល្យ នៃសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប ២០១៩
- ក្រសួងអប់រំ យុវជន និងកីឡា៖ ប្រវត្តិវិទ្យា"សម័យអាណានិគមបារាំង-ព្រះរាជាណាចក្រកម្ពុជាទី២" ភ្នំពេញ ២០១៧
- មជ្ឈមណ្ឌលឯកសារកម្ពុជា៖ វគ្គបណ្តុះបណ្តាលស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)ថ្នាក់ខេត្ត កម្រិតមធ្យមសិក្សា ភ្នំពេញ ឆ្នាំ២០១៥?
- ចាន់ រដ្ឋសុផា៖ ប្រវត្តិអប់រំកម្ពុជាពីឆ្នាំ១៩៧៩ ដល់សព្វថ្ងៃ ភាគទី៦ ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ ២០១២
- ហង់ជួន ណារ៉ុន៖ កំណែទម្រង់វិស័យអប់រំនៅកម្ពុជា ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ ឆ្នាំ ២០១៦

# ការរៀបចំប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈ
# របស់បណ្តាប្រទេសអាស៊ាន


បេក្ខជនបណ្ឌិត ៖ **សឺង សំណាង**

សាស្ត្រាចារ្យណែនាំ ៖ បណ្ឌិតសភាចារ្យ **ខ្លូត ធីតា**

ជំនាញ ៖ នីតិរដ្ឋបាលសាធារណៈ


## ១- សេចក្តីផ្តើម

ប្រទេសទាំងអស់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ លើកលែងតែប្រទេសថៃចេញ សុទ្ធតែធ្លាប់ស្ថិតនៅក្រោមអាណានិគមនិយមប្រទេសអឺរ៉ុប និងសហរដ្ឋអាមេរិក តាំងពីសតវត្សទី១៦-២០។ ប្រទេសទាំងអស់នោះ ស្ថិតនៅក្នុងស្ថានភាពបង្ខិតបង្ខំពីសំណាក់ប្រទេសម៉េត្រូប៉ូល ប៉ុន្តែការបង្ខិតបង្ខំនេះជម្រុញទៅរកទិសដៅអភិវឌ្ឍមួយដ៏សំខាន់សម្រាប់ប្រទេសនីមួយៗ។ លទ្ធផលដ៏ជាក់លាក់មួយ គឺបណ្តាប្រទេសអាស៊ី-អាគ្នេយ៍ទាំងនោះ បានក្លាយទៅជាចំណែកមួយ និងផ្សារភ្ជាប់ទៅនឹងដំណើរវិវត្តនៃប្រវត្តិសាស្ត្រពិភពលោក ទោះបីក្នុងន័យវិជ្ជមាន ឬអវិជ្ជមានយ៉ាងណាក៏ដោយ។ របបអាណានិគម ទោះបីនៅទីកន្លែងណាក្តី តែងតែខំប្រឹងប្រែងធ្វើសកម្មភាពជម្រុញឱ្យមានទំនើបកម្មបណ្តាប្រទេសក្នុងតំបន់។ នៅក្នុងបណ្តាប្រទេសអាស៊ី-អាគ្នេយ៍ ឥរិយាបថនៃទំនាក់ទំនងទំនើបកម្មលេចឡើងនៅលើវិស័យសេដ្ឋកិច្ច នៅលើវិស័យនយោបាយ (បង្កើតរចនាសម្ព័ន្ធថ្មី និងនីតិវិធី) ការផ្សព្វផ្សាយទស្សនៈ និងមនោគមវិជ្ជាថ្មី (សេរីនិយម ឯករាជ្យ ប្រជាធិបតេយ្យ) ។

រចនាសម្ព័ន្ធដឹកនាំរដ្ឋនៅក្នុងតំបន់បានទទួលនូវការគាំពារពីរដ្ឋធម្មនុញ្ញ ដែលជាស្ថាប័នអំណាចកំពូលនៅក្នុងប្រព័ន្ធដឹកនាំសម័យថ្មី។ អាស្រ័យដោយរដ្ឋធម្មនុញ្ញ ស្ថាប័នផ្សេងៗ ដែលមានលក្ខណៈបែបលោកខាងលិចត្រូវបានបង្កើត។ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ក្រោយពីបានទទួលឯករាជ្យ គ្មានប្រព័ន្ធនយោបាយណាមួយមានលក្ខណៈជាប្រពៃណី ទំនៀមទម្លាប់ទៀតនោះឡើយ លើកលែងតែប្រទេសព្រុយណេ។ ប៉ុន្តែទោះបីជាយ៉ាងណាក្តី ក៏ធាតុទាំងឡាយជាប្រពៃណី ទំនៀមទម្លាប់ ទោះតិចឬច្រើន តែងតែត្រូវបានថែរក្សានៅក្នុងវប្បធម៌នយោបាយ។ ប្រទេសទាំងអស់ ស្ថិតនៅក្នុងស្ថានភាពនៃការវិវត្តទំនើបកម្ម។

របបនយោបាយនៃប្រទេសទាំង១០ នៃតំបន់អាស៊ី-អាគ្នេយ៍អាចចែកជា ២ក្រុម គឺ របបប្រជាធិបតេយ្យ ថៃ ហ្វីលីពីន កម្ពុជា។ របបអាជ្ញាព្រឹត ភូមា ឥណ្ឌូនេស៊ី វៀតណាម ឡាវ ព្រុយណេ ម៉ាឡេស៊ី សឹង្ហបុរី។

ប្រទេសប្រាំមួយមានទម្រង់ជាសាធារណៈរដ្ឋ គឺ ឥណ្ឌូនេស៊ី ហ្វីលីពីន សឹង្ហបុរី វៀតណាម ឡាវ។ ប្រទេសបួនទៀតជារាជានិយម គឺ ថៃ ម៉ាឡេស៊ី ព្រុយណេ និងកម្ពុជា។ លើកលែងតែប្រទេសម៉ាឡេស៊ីមួយចេញ ដែលនៅរក្សារចនាសម្ព័ន្ធសហព័ន្ធដ៏រឹងមាំតាំងពីថ្ងៃទទួលបានឯករាជ្យ រហូតមកទល់បច្ចុប្បន្ន ប្រទេសប្រាំបួនទៀតនៃតំបន់មានរចនាសម្ព័ន្ធដឹកនាំជារដ្ឋឯកភូត មានអំណាចកណ្តាលរឹងមាំបែងចែកទៅតាមមូលដ្ឋានផ្សេងៗទូទាំងប្រទេស។

## ២-ប្រទេសថៃឡង់

ព្រះរាជាណាចក្រថៃ គឺជាប្រទេសអនុវត្តប្រព័ន្ធរដ្ឋបាលសាធារណៈ ដែលបានឆ្លងកាត់ការវិវត្តន៍ក្នុងអាយុកាលយ៉ាងតិច៨០០ឆ្នាំ ដែលក្នុងអំឡុងពេលនោះត្រូវបានរៀបចំឡើងដោយការលាយបញ្ចូលគ្នានូវប្រព័ន្ធរដ្ឋបាលសាធារណៈចំនួន ៥ ក្នុងប្រព័ន្ធការិយាធិបតេយ្យ ដែលត្រូវបានហៅថា "Master"[១] ។ Master នេះរួមមាន ព្រះមហាក្សត្រ ឥស្សរជនយោធា ពាណិជ្ជករខ្នាតធំ និងប្រជាពលរដ្ឋ។

យ៉ាងណាមិញ បច្ចុប្បន្នព្រះរាជាណាចក្រថៃ គឺជាប្រទេសដែលប្រកាន់យករបបប្រជាធិបតេយ្យដែលមានព្រះមហាក្សត្រជាព្រះប្រមុខរដ្ឋ[២] ដោយមាន សភាជាតិ គណៈរដ្ឋមន្ត្រី តុលាការ ស្ថាប័នធម្មនុញ្ញ និងភ្នាក់ងាររដ្ឋផ្សេងទៀតជាអ្នកដឹកនាំ និងប្រតិបត្តិការងាររដ្ឋដោយត្រូវស្ថិតក្រោមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រថៃ ឆ្នាំ២០០៧ និងរហូតមកទល់បច្ចុប្បន្ន គឺរដ្ឋធម្មនុញ្ញ ឆ្នាំ២០១៧ ដែលជាច្បាប់កំពូលរបស់រដ្ឋ។

ភ្នាក់ងាររដ្ឋត្រូវបានបែងចែកជា ៤ គឺ ភ្នាក់ងាររដ្ឋាភិបាល សហគ្រាសសាធារណៈ អង្គការសាធារណៈ និងភ្នាក់ងាររដ្ឋបែបថ្មីរួមមាន អង្គការរដ្ឋបាលឯករាជ្យ មូលនិធិនីតិបុគ្គល និងអង្គភាពផ្តល់សេវា។ ដោយឡែកមន្ត្រីរាជការ ដែលបម្រើការងារក្នុងស្ថាប័នដូចដែលបានរៀបរាប់ខាងលើត្រូវស្របតាមច្បាប់ស្តីពីមុខងារសាធារណៈឆ្នាំ២០០៨ ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាច្រើនផ្សេងទៀត។ ក្នុងនោះ ច្បាប់ស្តីពីមុខងារសាធារណៈរបស់ប្រទេសថៃ បានកំណត់បែងចែកមន្ត្រីរាជការជាពីរប្រភេទគឺ មន្ត្រីរាជការស៊ីវិល(Civil Servants)និងមន្ត្រីរាជវង្សានុវង្ស(Royal Household Civil Officials)[៣]។ ច្បាប់ដែលសំខាន់ក្នុងវិស័យមុខងារសាធារណៈ ជាពិសេសរដ្ឋបាលសាធារណៈមួយទៀតនោះគឺ ច្បាប់ស្តីពីរដ្ឋបាលរបស់រដ្ឋ (State Administration Act) ឆ្នាំ១៩៩១ ដែលកំណត់អំពីការបែងចែកការគ្រប់គ្រងរដ្ឋបាលសាធារណៈជាបីគឺ រដ្ឋបាលថ្នាក់កណ្តាល រដ្ឋបាលថ្នាក់ខេត្ត និងរដ្ឋបាលមូលដ្ឋាន[៤] ដែលមន្ត្រីរាជការ និងមន្ត្រីរដ្ឋាភិបាល ត្រូវពង្រាយដើម្បីប្រតិបត្តិការងារផ្តល់សេវាជូនប្រជាពលរដ្ឋ។ លើសពីនេះទៅទៀតច្បាប់ស្តីពីសារព័ត៌មានឆ្នាំ១៩៩៧ បានអនុញ្ញាតឱ្យផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការងារមុខងារសាធារណៈជូនដល់សាធារណៈជនទូទៅ ដែលជាហេតុនាំឱ្យច្បាប់នេះមានសារៈសំខាន់សម្រាប់មុខងារសាធារណៈនៃប្រទេសថៃផងដែរ។ ដូច្នេះប្រជាជនថៃ មានសិទ្ធិទទួលបាន និងតាមដាននីតិវិធីក្នុងការជ្រើសរើសបុគ្គលិកសម្រាប់វិស័យមុខងារសាធារណៈ ក៏ដូចជាព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈបានជាប្រចាំ។

## ៣-ប្រទេសហ្វីលីពីន

សាធារណៈរដ្ឋហ្វីលីពីន គឺជាប្រទេសដែលប្រកាន់យកនូវរបបសាធារណៈរដ្ឋប្រជាធិបតេយ្យពោល គឺប្រជាពលរដ្ឋមានសិទ្ធិក្នុងការបោះឆ្នោតជ្រើសរើសប្រធានាធិបតី ឱ្យធ្វើជាប្រមុខរដ្ឋដែលទទួល

[១] Evan M.Berman, Public Administration in Southeast Asia, (New York: Taylor & Francis Group), 30

[២] Constitution of Thailand, 2007, Section 2

[៣] Civil Service Act of Thailand, 2008, Section 35

[៤] State Administration Act of Thailand, 1991, Section 4

បន្ទុកក្នុងការដឹកនាំប្រទេស។ យោងតាមរដ្ឋធម្មនុញ្ញនៃសាធារណៈរដ្ឋហ្វីលីពីនឆ្នាំ១៩៨៧ ចែងអំពីការបែងចែកអំណាចរដ្ឋជា៣ គឺអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ[៥]។

**អំណាចនីតិប្បញ្ញត្តិ** មានស្ថាប័នចំនួន ២ គឺ ៖ ព្រឹទ្ធសភា និងសភាតំណាង។ ព្រឹទ្ធសភា មានសមាជិក២៤រូប និងត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោត ហើយបុគ្គលដែលមានសិទ្ធិក្នុងការឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវមានអាយុយ៉ាងតិច ៣៥ឆ្នាំ និងជាជនជាតិហ្វីលីពីន។ ចំពោះនីតិកាលរបស់ព្រឹទ្ធសភាត្រូវបានកំណត់អាណត្តិ ៦ឆ្នាំ ដោយឡែកអាណត្តិនៃសមាជិកព្រឹទ្ធសភាមានរយៈពេលយូរបំផុតត្រឹម ២អាណត្តិ។ សភាតំណាង (រដ្ឋសភា) មានអាណត្តិកំណត់រយៈពេល៣ឆ្នាំ និងមានសមាជិកយ៉ាងច្រើនបំផុតត្រឹម ២៥០រូប។ ដើម្បីក្លាយជាសមាជិកពេញសិទ្ធរបស់សភាតំណាង បុគ្គលរូបនោះត្រូវមានអាយុយ៉ាងតិច ២៥ឆ្នាំ ជាជនជាតិហ្វីលីពីន និងត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោតជាសកល[៦]។

**អំណាចនីតិប្រតិបត្តិ** គឺជាអំណាចដែលគ្រប់គ្រងដោយប្រធានាធិបតី ដែលទទួលបានការបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋ។ ក្នុងនោះ ដើម្បីមានសិទ្ធិឈរឈ្មោះបោះឆ្នោតជ្រើសរើសជាប្រធានាធិបតី និងអនុប្រធានាធិបតី បុគ្គលទាំងនោះត្រូវមានសមត្ថភាព និងគុណវុឌ្ឍិសក្តិសម ព្រមទាំងមានអាយុយ៉ាងតិចបំផុត ៤០ឆ្នាំ និងជាជនជាតិហ្វីលីពីន។ ចំពោះអាណត្តិការងាររបស់ប្រធានាធិបតីមានរយៈពេល៦ឆ្នាំ គិតចាប់ពីរសៀលថ្ងៃទី៣០ ខែមិថុនា បន្ទាប់ពីការបោះឆ្នោត រហូតដល់ ៦ឆ្នាំក្រោយ នារសៀលថ្ងៃខែដដែល និងមានសិទ្ធកាន់អំណាចបានតែមួយអាណត្តិប៉ុណ្ណោះ។ អនុប្រធានាធិបតី មានអាណត្តិការងាររយៈពេល ៦ឆ្នាំ គិតចាប់ពីរសៀលថ្ងៃទី៣០ ខែមិថុនា បន្ទាប់ពីការបោះឆ្នោត រហូតដល់ ៦ឆ្នាំក្រោយនារសៀលថ្ងៃខែដដែល និងអាចបន្តការងារយ៉ាងយូរបំផុតត្រឹម២អាណត្តិ[៧]។

**អំណាចតុលាការ** តំណាងដោយតុលាការកំពូល និងសាលាជំរះក្តីដែលបង្កើតឡើងដោយច្បាប់។ សមាសភាពក្នុងតុលាការកំពូល រួមមាន ប្រធាន១រូប និងសមាជិក១៤រូប ក្នុងនោះសមាជិក តុលាការកំពូលត្រូវមានអាយុយ៉ាងតិច ៤០ឆ្នាំ រួមជាមួយនឹងបទពិសោធន៍ ការងារដោះស្រាយបណ្តឹងនៅក្នុងតុលាការ ឬអនុវត្តការងារពាក់ព័ន្ធនឹងច្បាប់នៅសាធារណៈរដ្ឋហ្វីលីពីនរយៈពេល១៥ឆ្នាំ និងជាជនជាតិហ្វីលីពីន[៨]។

ជាមួយគ្នានេះដែរ រដ្ឋធម្មនុញ្ញនៃសាធារណៈហ្វីលីពីនក៏បានចែងអំពីស្ថាប័នឯករាជ្យចំនួន ៣ រួមមាន (១)គណៈកម្មាធិការមុខងារសាធារណៈ (២)គណៈកម្មាធិការបោះឆ្នោត និង (៣)គណៈ កម្មាធិការសវនកម្ម[៩]។ ក្នុងនោះគណៈកម្មាធិការមុខងារសាធារណៈ ទទួលបន្ទុកការងារគ្រប់គ្រងមន្ត្រីរដ្ឋការ

[៥]The Constitution of the Republic of the Philippines, 1987, Article II, Section 1

[៦]ibid, Article VI

[៧]ibid, Article VII

[៨]bid, Article VIII

[៩]ibid, Article IX, A, Section 1

នៅសាធារណៈរដ្ឋហ្វីលីពីន ដូចជា ការជ្រើសរើស ការតែងតាំង ការបណ្ដុះបណ្ដាល ការវាយតម្លៃការអនុវត្តការងារ ការលើកទឹកចិត្ត និងការដាក់ពិន័យជាដើម[៩០]។

## ៤-ប្រទេសវៀតណាម

ប្រទេសវៀតណាមបានអនុវត្តទម្រង់របនាសម្ព័ន្ធ តាមបែបចិនបុរាណដើម្បីគ្រប់គ្រងប្រទេសអស់រយៈពេលជាច្រើនសតវត្សមកហើយ សម័យអាណានិគមនិយមបារាំង(១៨៨៧)។ ក្រោយទទួលបានឯករាជ្យពីអាណានិគម និងឆ្លងកាត់សង្គ្រាមអស់រយៈពេលជាច្រើនឆ្នាំមក វៀតណាមបានព្យាយាម កែប្រែ និងរៀបចំទម្រង់ប្រព័ន្ធគ្រប់គ្រងមន្ត្រីទំនើបជាបណ្ដើរៗ ដោយសារតែទម្រង់របនាសម្ព័ន្ធប្រើប្រាស់ កន្លងមកនៅមានកម្រិតនៅឡើយ។

ក្រោមការខិតខំប្រឹងប្រែងអស់រយៈពេលជិតពីរទសវត្សកន្លងមកក្នុងឆ្នាំ២០១០ វៀតណាមបានក្លាយជាប្រទេសចំណូលមធ្យម និងបានព្យាយាមកែទម្រង់រដ្ឋបាលសាធារណៈរបស់ខ្លួនយ៉ាងខ្លាំង ពីមួយដំណាក់កាលទៅមួយដំណាក់កាលរហូតដល់បច្ចុប្បន្ន។ ចក្ខុវិស័យរបស់វៀតណាម គឺពង្រឹង និងពង្រីកប្រជាធិបតេយ្យ ភាពស្អាតស្អំ ខ្លាំងក្លា និងសេវាសាធារណៈទំនើប។ យ៉ាងណាមិញ រដ្ឋាភិបាលវៀតណាម ក៏បានជួបប្រទះបញ្ហាប្រឈមពាក់ព័ន្ធនឹងដំណើរការនៃការរៀបចំគោលនយោបាយ និងការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យមុខងារសាធារណៈ ដូចជា ការធ្វើផែនការ ការជ្រើសរើស ការតែងតាំង ការបណ្ដុះបណ្ដាល និងការអភិវឌ្ឍ បញ្ហាបៀវត្ស ការលើកទឹកចិត្ត និងវិន័យនៅកន្លែងការងារជាដើម។ លើសពីនេះទៀត បញ្ហាអំពើពុករលួយ សំណូកសូកប៉ាន់ក៏ជាបញ្ហាចម្បងផងដែរ។

គោលគំនិតក្នុងការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យមុខងារសាធារណៈ គឺអនុវត្តការងារប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល ផលិតភាព ព្រមទាំងផ្ដោតលើគុណភាព និងបរិមាណការងារ ដើម្បីសម្រេចនូវចក្ខុវិស័យសាធារណៈ សុវត្ថិភាពសាធារណៈ និងការពេញចិត្តក្នុងការធ្វើការងាររបស់មន្ត្រីជាដើម។ គោលដៅនៃការគ្រប់គ្រងធនធានមនុស្ស ក្នុងវិស័យមុខងារសាធារណៈរបស់វៀតណាម គឺរៀបចំកែសម្រួលប្រព័ន្ធវិជ្ជាជីវៈ(Professional System)នៃការគ្រប់គ្រងមន្ត្រីរដ្ឋការឱ្យមានស្តង់ដារ និងកម្មវត្ថុច្បាស់លាស់ ដើម្បីអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល ដោយផ្សារភ្ជាប់នឹងប្រព័ន្ធការងារដែលយោងទៅលើមុខតំណែង។ នៅក្នុងប្រព័ន្ធវិជ្ជាជីវៈវៀតណាម បាននិងកំពុងព្យាយាមបែងចែកកិច្ចការនយោបាយរបស់បុគ្គល និងការងារក្នុងនាមជាមន្ត្រីស៊ីវិលឱ្យដាច់ចេញពីគ្នា។

នៅក្នុងដំណាក់កាលសង្គ្រាមរាំរ៉ៃ ប្រទេសជាតិមិនទាន់ទទួលបានសន្តិភាពពេញលេញ ប្រព័ន្ធមន្ត្រីរដ្ឋការស៊ីវិលវៀតណាម គឺអនុវត្តតាមប្រព័ន្ធទំនើបរបស់សហភាពសូវៀត។ ប្រព័ន្ធនេះអនុវត្តអាស្រ័យលើប្រព័ន្ធក្របខណ្ឌ(Cadre System) ដែលបញ្ចូលគ្នារវាងប្រព័ន្ធនយោបាយ និងមន្ត្រីស៊ីវិលក្នុងការធ្វើការបម្រើវិស័យសាធារណៈ។ មកដល់បច្ចុប្បន្ន ប្រទេសវៀតណាមក៏មិនទាន់បែងចែកដាច់ពីគ្នាផងដែរ រវាងកិច្ចការនយោបាយ និងការងារជាមន្ត្រីស៊ីវិល។ ប៉ុន្តែប្រទេសវៀតណាមត្រូវបានកត់សម្គាល់ឃើញថា មានការផ្លាស់ប្ដូរពីប្រព័ន្ធអាស្រ័យលើកម្មាភិបាលទៅជាប្រព័ន្ធរដ្ឋាភិបាលមន្ត្រីស៊ីវិលដូចជាបង្កើតឱ្យមានការប្រកួតប្រជែង ការជ្រើសរើសក្នុងប្រព័ន្ធរដ្ឋាភិបាល។

---

[៩០]Republic Act No.2260 on the Civil Service Act, 1959

នៅក្នុងប្រព័ន្ធគ្រប់គ្រងមន្ត្រីស៊ីវិល ច្បាប់គ្រប់គ្រងមន្ត្រីស៊ីវិលឆ្នាំ២០០៨ និងឆ្នាំ២០១១ បាន ចំណាត់ ថ្នាក់មន្ត្រីជាបីប្រភេទគឺ មន្ត្រីសាធារណៈ(Public Officials) មន្ត្រីស៊ីវិល(Civil Servants) និងនិយោជិតសាធារណៈ(Public Employee)។ មន្ត្រីសាធារណៈ ត្រូវបានបោះឆ្នោត និងតែងតាំង ក្នុងមុខតំណែង ខណៈពេលដែលមន្ត្រីស៊ីវិលត្រូវបានជ្រើសរើស និងធ្វើការក្នុងភ្នាក់ងាររដ្ឋបាលដែល មានមូលដ្ឋានអចិន្ត្រៃយ៍តិច ឬច្រើន។ អ្នកទាំងនោះធ្វើការក្នុងស្ថាប័នបក្ស អង្គការនយោបាយសង្គម ភ្នាក់ងាររដ្ឋបាល រីឯនយោជិតសាធារណៈវិញ ត្រូវបានជ្រើសរើស និងធ្វើការក្នុងការផ្តល់សេវាសាធារ ណៈ។

វៀតណាម បានបែងចែកការគ្រប់គ្រងធនធានមនុស្សជាពីរ គឺ ៖ ខាងក្រៅ (Hardware) និង ខាងក្នុង(Software)។ ខាងក្រៅរួមមាន ៖ ការធ្វើផែនការធនធានមនុស្ស វិភាគ និងពិពណ៌នាតំណែង មុខងារ ការជ្រើសរើស និងតែងតាំង ការបណ្តុះបណ្តាល ការអភិវឌ្ឍ ការវាយតម្លៃលើការងារ វិន័យ និងការងារបៀវត្សរបស់មន្ត្រីសាធារណៈ។ ចំណែកឯខាងក្នុងវិញ មានដូចជា ៖ ការលើកទឹកចិត្តមន្ត្រី គ្រប់គ្រងគោលការណ៍រក្សាការសម្ងាត់របស់រដ្ឋ បញ្ហាជម្លោះផលប្រយោជន៍ គណនេយ្យភាពមន្ត្រីសាធារ ណៈ ការឆ្លើយតបលើឥរិយាបទមន្ត្រី ដោយមិនលំអៀង និងអព្យាក្រិត។

# សន្និដ្ឋាន

ប្រទេសណាក៏មានរដ្ឋបាលដែរ ព្រោះបើគ្មានរដ្ឋបាលទេ គេពុំអាចគ្រប់គ្រង ឬបែងចែកការងារ ទូទៅ ឬការងារប្រចាំថ្ងៃបានឡើយ។ រដ្ឋបាលគ្រប់គ្រងប្រទេស វាមិនសុទ្ធសឹងតែគោរពច្បាប់ទាំងអស់ ឡើយ។ រដ្ឋផ្តាច់ការ ដែលរដ្ឋបាលពុំមានលក្ខណៈគោរពច្បាប់ ក៏ដូចគ្នាទៅនឹងរដ្ឋកុម្មុយនិស្តដែរ កាល ណារដ្ឋបាលបម្រើប្រយោជន៍ឱ្យគណបក្ស នាំឱ្យគេសន្និដ្ឋានថា រដ្ឋបាលនោះមិនសូវគោរពច្បាប់ ឬធ្វើឱ្យ បានត្រឹមត្រូវតាមច្បាប់។ លក្ខណៈនៃរដ្ឋបាលមិនគោរពច្បាប់ គឺផ្អែកទៅលើកត្តាផ្សេងៗដូចជា រដ្ឋបាល គឺជាឧបករណ៍របស់រដ្ឋ ឬជាឧបករណ៍របស់គណបក្ស បើកាលណារដ្ឋនោះជារដ្ឋផ្តាច់ការនាំឱ្យរដ្ឋបាល នោះពុំគោរពច្បាប់ទេ។ ជួនកាលទៀត រដ្ឋនោះគ្មានច្បាប់រដ្ឋបាល (ច្បាប់រៀបចំអង្គភាព) តែម្តង។ ម្យ៉ាងវិញទៀត បើប្រទេសនោះមានច្បាប់រដ្ឋបាលដែរ តែយោងលើប្រជារាស្ត្រខ្វះការយល់ដឹងច្រើន ពេក រាស្ត្រមិនហ៊ានប្តឹង មិនហ៊ានតបតទៅនឹងកិច្ចការរបស់រដ្ឋ ព្រោះខ្លាចមានផលវិបាកទៅថ្ងៃក្រោយ នេះក៏ត្រូវរាប់បញ្ចូលទៅក្នុងការមិនគោរពច្បាប់រដ្ឋបាលដែរ។

នៅប្រទេសដែលរដ្ឋបាលមិនគោរពច្បាប់ គេច្រើនទម្លាក់ក្នុងការងាររដ្ឋបាលគេដែរ គេធ្លាប់ ប្រើតៗគ្នាកន្លងមក។ ដូចនេះ ដោយសារមានទម្លាប់របស់គេនេះហើយ ដែលអាចធ្វើឱ្យការងាររបស់គេ ដំណើរការទៅបានធម្មតា។ ផ្ទុយទៅវិញ នៅប្រទេសដែលរដ្ឋបាលគោរពច្បាប់ គេមានក្រមរដ្ឋបាល របស់គេច្បាស់លាស់ គេមានតុលាការរដ្ឋបាលរបស់គេសម្រេច ពិនិត្យមើលលើគំរោងការងាររដ្ឋបាល ដែលសម្អាងពីច្បាប់។

# គន្ថនិទេស


១-កៅ មុយថង ៖ "រដ្ឋបាលសាធារណៈទំនើប" បោះពុម្ពលើកទី២ ឆ្នាំ២០១២
២-បណ្ឌិតសភាចារ្យ ខ្លួត ធីតា ៖ ទស្សនវិជ្ជាច្បាប់ បោះពុម្ពលើកទី១ ឆ្នាំ២០០៩
៣-គង់ ភីរុន ៖ "នីតិរដ្ឋបាលអំពីរចនាសម្ព័ន្ធ" បោះពុម្ពផ្សាយលើកទី១ ឆ្នាំ១៩៩៧
៤-ហៀង សាង ៖ "នីតិរដ្ឋបាលទូទៅ" ឆ្នាំ២០១១
៥-ឡឿក ពិដោរ ៖ "នីតិរដ្ឋបាលទូទៅ" ឆ្នាំ២០០៩
៦- Civil Service Commission, "*Mandate,*" (n.d.), http://www.csc.gov.ph/2014-02-20-02-22-48/2014-02-20-02-29-25.html (Accessed May 17, 2021).
៧-Civil Service Commission, *The Revised Administrative Code of 1987 on the Civil Service Commission,* (Public Assistance and Information Office, 1989), 5.
៨-Civil Service Commission, "*Our Approach,*" (n.d.), http://csi.csc.gov.ph/about-us/our-approach/ (Accessed May 24, 2021).
៩-Civil Service Commission, "*The Civil Service Institute,*" (n.d.), http://csi.csc.gov.ph/about-us/ (Accessed May 25, 2021).
១០-Civil Service Commission, "*Our Partners,*" (n.d.), http://csi.csc.gov.ph/about-us/our-partners/ (Accessed May 25, 2021).
១១-Civil Service Commission, "Historical Highlights," (n.d.), http://ncr.csc.gov.ph/slider/85-about-the-csc/372-historicalhighlights.html (Accessed May 30, 2021).
១២-Civil Service Commission, "*Processing of Examination Application (Career Service Examination-Paper and Pencil Test)(Professional or subprofessional Test) ,*" (n.d.), http://csc.gov.ph/2014-02-27-07-36-50/2014-02-27-07-37-12.html(Accessed May 30, 2021).
១៣-Circular Letter on Clarification on the Availment of Incentives under Executive Order No.366 of Affected Personnel on Extended Service, 2009.

# សារៈសំខាន់នៃការគ្រប់គ្រងធនធានមនុស្ស

បេក្ខជនបណ្ឌិត **ហ៊ុន ដានី**
ជំនាញ៖ រដ្ឋបាលសាធារណៈ
ជំនាន់ទី៥ វគ្គ១

ការគ្រប់គ្រងធនធានមនុស្ស មានសារៈសំខាន់និងមានភាពចំាបាច់ណាស់នៅគ្រប់របនាសម្ព័ន្ធរបស់អង្គភាព ស្ថាប័ន ដើម្បីជំរុញល្បឿននៃការអភិវឌ្ឍរបស់អង្គភាព ស្ថាប័ននោះ តាមរយៈផលិតភាព និងប្រសិទ្ធភាពនៃការអនុវត្តការងាររបស់បុគ្គលិក។ ដើម្បីឈ្វេងយល់ឱ្យបានកាន់តែច្បាស់អំពី "សារៈសំខាន់នៃការគ្រប់គ្រងធនធានមនុស្ស" យើងត្រូវសិក្សាឈ្វេងយល់អំពីទ្រឹស្តីជាមូលដ្ឋានគន្លឹះនៃការគ្រប់គ្រងធនធានមនុស្សជាមុនសិន។ «ការគ្រប់គ្រងធនធានមនុស្ស» កើតចេញពីការសំយោគគ្នារវាងពាក្យ «ការគ្រប់គ្រង» និងពាក្យ «ធនធានមនុស្ស»៖

**ការគ្រប់គ្រង៖** បើតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត** ពាក្យ «គ្របគ្រង ឬគ្រប់គ្រង» មានន័យថាបីបាច់ រក្សា ថែទាំដោយទទួលរងបន្ទុក រងខុសត្រូវលើខ្លួន។ អាចនិយាយបានថាជាការបីបាច់ ការថែរក្សា ការត្រួតត្រា ការចាត់ការសព្វសារពើ។ ចំណែកវចនានុក្រម Oxford Dictionary ក៏បានឱ្យនិយមន័យ "ការគ្រប់គ្រង" ថាជាដំណើរការនៃការរៀបចំចាត់ចែង និងត្រួតពិនិត្យទាំងផ្នែករដ្ឋបាលនិងមនុស្សនៅក្នុងអង្គភាពដោយការទទួលខុសត្រូវ។ ន័យខាងលើនេះស៊ីចង្វាក់គ្នាទៅនឹងទ្រឹស្តីរបស់លោកប៊ូន (Boone) និងលោកគើតស៍ (Kurtz-1992) បានឱ្យនិយមន័យ "ការគ្រប់គ្រង" ថាជា "ការប្រើប្រាស់ធនធានមនុស្ស និងធនធានទាំងឡាយផ្សេងទៀតដើម្បីសម្រេចឱ្យបាននូវគោលបំណង"។ នៅក្នុងទ្រឹស្តីរដ្ឋបាល (Simon-1970) "ការគ្រប់គ្រង" សំដៅលើសកម្មភាពនៃការរៀបចំចាត់ចែងនូវរាល់កិច្ចការងារទាំងឡាយក្នុងអង្គភាពដោយមានការចូលរួម និងសហការគ្នាអនុវត្តការងារដើម្បីសម្រេចបាននូវគោលដៅ។ "ការគ្រប់គ្រង" ក៏ត្រូវបានផ្តល់និយមន័យតាមមួយបែបទៀតថាជាសិល្បៈ និងជាវិធីសាស្ត្រនៃការរៀបចំចាត់ចែង សម្របសម្រួលរាល់សកម្មភាពទាំងឡាយនៅក្នុងអង្គភាពឱ្យមានដំណើរការ តាមរយៈការធ្វើសេចក្តីសម្រេចចិត្តខាងការគ្រប់គ្រង រួមបញ្ចូលទាំងស្ថានភាពហិរញ្ញវត្ថុ រចនាសម្ព័ន្ធការងារ និងធនធានមនុស្ស។

ទ្រឹស្តីការគ្រប់គ្រងបែបវិទ្យាសាស្ត្រ ត្រូវបានណែនាំដោយលោក ហ្វ្រឺឌែរីក វិនស្លូវថេល័រ (Frederick Winslow Toylor) ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ។ លោកបានធ្វើការវែកញែកអំពីអប្រសិទ្ធភាពការងារ គួរត្រូវបានត្រួតពិនិត្យឡើងវិញតាមរយៈការគ្រប់គ្រងបែបវិទ្យាសាស្ត្រ។ លោកបានកំណត់ន័យការគ្រប់គ្រងបែបវិទ្យាសាស្ត្រថា «ត្រូវដឹងពីអ្វីដែលត្រូវធ្វើ

រួចធ្វើវាឱ្យបានល្អបំផុត»។ ការគ្រប់គ្រងមានមុខងារសំខាន់ចំនួន៤ រួមមាន៖ ការធ្វើផែនការ (Planning) ការចាត់ចែង(Organizing) ការដឹកនាំ(Leading) និងការត្រួតពិនិត្យ (Controlling) ដូចក្នុងរូបភាពទី១ ។

**រូបភាពទី១ មុខងារនៃការគ្រប់គ្រង**




**ធនធានមនុស្ស៖** នៅលើពិភពលោកទាំងមូលគ្មានប្រទេសណាមួយដែលអភិវឌ្ឍប្រទេសរបស់ខ្លួនបានជោគជ័យដោយគ្មានការចូលរួមពីធនធានមនុស្សឡើយ។ ជាក់ស្តែងបទពិសោធន៍ជាអន្តរជាតិក៏បានបង្ហាញយ៉ាងច្បាស់ថា «ការអភិវឌ្ឍចាប់ផ្តើមនិងបញ្ចប់ជាមួយនឹងមនុស្ស»។ គេចាត់ទុកធនធានមនុស្ស គឺជាទ្រព្យដ៏មានតម្លៃបំផុតរបស់អង្គភាព។

បើតាមវចនានុក្រមស្ដីពីធនធានមនុស្ស និងការគ្រប់គ្រងធនធានមនុស្សបានឱ្យនិយមន័យ "ធនធានមនុស្ស" ថាជាមនុស្សដែលបម្រើការក្នុងអង្គភាព ហើយមានការថែរក្សា និងអភិវឌ្ឍជាប្រចាំដើម្បីបង្កើនផលិតភាពការងារនិងសម្រេចជោគជ័យជូនអង្គភាព។ ដូចគ្នានេះដែរនៅក្នុងទ្រឹស្ដីរដ្ឋបាលសាធារណៈ ធនធានមនុស្ស សំដៅដល់មនុស្សដែលបម្រើការក្នុងអង្គភាពឬសហគ្រាសអាជីវកម្ម ដែលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍ និងធ្វើឱ្យអង្គភាពមានដំណើរការល្អតាំងពីចំណុចចាប់ផ្ដើមរហូតដល់ចំណុចបញ្ចប់។ គេចាត់ទុកកត្តាមនុស្សជាចំណុចកណ្ដាល ឬជាបេះដូងរបស់អង្គភាព។ ក្រៅពីនេះមានកត្តាធនធានហិរញ្ញវត្ថុ កត្តាបច្ចេកវិទ្យាដែលបានរួមចំណែកនៅក្នុងដំណើរការរបស់អង្គភាព ប៉ុន្តែកត្តាទាំងនេះមិនអាចធ្វើឱ្យអង្គភាពសម្រេចគោលដៅបានឡើយប្រសិនបើគ្មានធនធានមនុស្ស ពោលគឺកត្តាទាំងនេះត្រូវពឹងផ្អែកលើកត្តាធនធានមនុស្ស និងការប្រើប្រាស់ធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបាននូវគោលដៅ (រូបភាពទី២)។

**រូបភាពទី២ សក្ដានុពលនៃធនធានមនុស្ស**




**ការគ្រប់គ្រងធនធានមនុស្ស៖** យោងអត្ថន័យខាងលើនេះការគ្រប់គ្រងធនធានមនុស្ស គឺមានភាពចាំបាច់ណាស់សម្រាប់ដំណើរការរបស់អង្គភា ដែលត្រូវបានគេឱ្យនិយមន័យថា ជាការទទួលខុសត្រូវចំពោះសកម្មភាពនៃការប្រើប្រាស់មនុស្សឱ្យប្រកបដោយផលិតភាពដើម្បីធានាផលប្រយោជន៍ និងដោះស្រាយរាល់បញ្ហាដែលទាក់ទងនឹងមនុស្សនៅក្នុងអង្គភាព។ លោក បកហ្សល និង លោក ស្ទីនែវេលដ៍ (Boxall and Steeneveld-1999) បានពណ៌នាថាការគ្រប់គ្រងធនធានមនុស្ស គឺជាការគ្រប់គ្រងមនុស្ស និងការងារដើម្បីឆ្ពោះទៅកាន់គោលដៅ ដោយសារតែរាល់សកម្មភាពការងារតែងមានទំនាក់ទំនងជាមួយមនុស្សជាសារវ័ន្ត។ ការគ្រប់គ្រងធនធានមនុស្ស មិនមានចរិតលក្ខណៈជាសកលនោះទេ គឺត្រូវបានអនុវត្តតាមគម្រូ

ផ្សេងៗគ្នាអាស្រ័យដោយបរិបទនៃអង្គភាពនីមួយៗ ដើម្បីឱ្យអង្គភាពមានការរីកចម្រើនទៅមុខ ហើយដើម្បីសម្រេចបំណងប្រាថ្នានៃការគ្រប់គ្រងធនធានមនុស្ស គេត្រូវតែសម្រេចឱ្យបាននូវបំណងប្រាថ្នានៃសមាសភាគតូចៗតាមផ្នែកក្នុងអង្គភាពជាមុនសិន។ លោកចនស្តូរីយ៍ (John Storey-1989 យល់ថាការគ្រប់គ្រងធនធានមនុស្សមានទំនាក់ទំនងជាមួយគោលនយោបាយ ទស្សនវិជ្ជា និងមនោគមវិជ្ជាផងដែរ។ លោកបានពន្យល់ថាការគ្រប់គ្រងធនធានមនុស្សផ្តោតលើទិដ្ឋភាព ០៤យ៉ាង៖ ១)ជំនឿចិត្តនិងការសន្មតរបស់ក្រុមឬអង្គភាព ២)យុទ្ធសាស្ត្រដែលនាំឱ្យមានការសម្រេចចិត្ត ៣)ប្រព័ន្ធការងារក្នុងអង្គភាព និង៤)ទំនាក់ទំនងក្នុងការងារដែលមានការពឹងអាស្រ័យគ្នាទៅវិញទៅមក។

គេអាចនិយាយបានថា "ការគ្រប់គ្រងធនធានមនុស្ស" គឺជាដំណើរការនៃការធ្វើផែនការ ការជ្រើសរើសបុគ្គលិក ការអភិវឌ្ឍបុគ្គលិក ការវាយតម្លៃ និងការផ្តល់នូវសំណងដល់បុគ្គលិកម្នាក់ៗដែលបានបម្រើការងារក្នុងអង្គភាព ដើម្បីសម្រេចឱ្យបាននូវគោលបំណងរបស់អង្គភាពប្រកបដោយប្រសិទ្ធភាព និងចំគោលដៅ។ លោកអ៊ុលរិច និងលោកឡេក (Ulrich & Lake)បានលើកឡើងថាប្រព័ន្ធនៃការគ្រប់គ្រងធនធានមនុស្សធ្វើឱ្យអង្គភាពបង្កើនសមត្ថភាពសិក្សា ដកបទពិសោធន៍ កែតម្រូវ និងទាញយកផលប្រយោជន៍ពីឱកាសថ្មីៗផងដែរ។

បច្ចុប្បន្ននេះការគ្រប់គ្រងធនធានមនុស្ស មានសារៈសំខាន់កាន់តែខ្លាំងឡើងក្នុងដំណើរការរបស់អង្គភាព ដោយសារតែមនុស្សជាអ្នកអនុវត្តការងារ ឬអាចនិយាយថាមនុស្សជាអ្នកផលិតការងារនិងធ្វើឱ្យអង្គភាពមានការរីកចម្រើនទៅមុខ។ ប្រសិនបើគ្មានការគ្រប់គ្រងធនធានមនុស្សឱ្យបានល្អទេនោះ អង្គភាពមួយក៏មិនអាចសម្រេចបានលទ្ធផលការងារទៅតាមការគ្រោងទុកនោះដែរ។ ក្នុងន័យនេះ ការគ្រប់គ្រងធនធានមនុស្សត្រូវបានគេមើលឃើញថាមានឥទ្ធិពលខ្លាំងណាស់ចំពោះអង្គភាព ដែលជួយឱ្យអង្គភាពសម្រេចបានទៅតាមគោលបំណងដោយសារៈ

- ការគ្រប់គ្រងធនធានមនុស្ស បង្កើតក្បួនច្បាប់ និងវិន័យច្បាស់លាស់ក្នុងការអនុវត្តការងារដោយមានការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់។
- លើកកម្ពស់គុណភាពការងារ និងធ្វើឱ្យប្រសើរឡើងនូវបរិស្ថានការងារ។
- ជួយបង្កើនសមត្ថភាពប្រកួតប្រជែងតាមរយៈការចាប់យកនូវការអនុវត្តល្អៗពីការគ្រប់គ្រងធនធានមនុស្ស ដើម្បីជំរុញផលិតភាព និងប្រសិទ្ធភាពការងារ ។
- ជួយទ្រទ្រង់អង្គភាពឱ្យមាននិរន្តរភាព មានបរិយាកាសការងារប្រកបដោយក្រមសីលធម៌ ទស្សនាទានវែងឆ្ងាយ និងស្តង់ដាខ្ពស់។
- ជួយបង្កើតទំនាក់ទំនងកាន់តែល្អរវាងថ្នាក់ដឹកនាំ កម្មករ និយោជិត និងអ្នកពាក់ព័ន្ធទាំងខាងក្នុង និងខាងក្រៅអង្គភាព ព្រមទាំងផ្តល់នូវសេវាដែលល្អបំផុតដល់អតិថិជន និងប្រជាជន ។

- ជួយបង្កើនការគិតគូរពីសុវត្ថិភាព និងសុខមាលភាពរបស់បុគ្គលិកក្នុងអង្គភាព។
- ជួយឱ្យមានការគិតគូរពីលក្ខខណ្ឌការងារសមស្រប និងជួយដោះស្រាយបញ្ហាបុគ្គលិកនៅពេលពួកគេជួបការលំបាកស្មុគស្មាញ ឬពេលមានជម្លោះ។
- ជួយឱ្យមានការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការងារច្បាស់លាស់ រួមជាមួយនឹងប្រព័ន្ធលើកទឹកចិត្តដែលកាន់តែប្រសើរ ដើម្បីរក្សាទុកបុគ្គលិកដែលល្អៗ។
- អភិវឌ្ឍស្មារតីការងារជាក្រុម និងលើកតម្លៃអង្គភាព។

នៅក្នុងអង្គភាពផ្ទាល់ ការងារគ្រប់គ្រងធនធានមនុស្ស បានជួយឱ្យផ្នែកទាំងឡាយនៃការងារមានភាពច្បាស់លាស់ បុគ្គលិកម្នាក់ៗមានការទទួលខុសត្រូវក្នុងការអនុវត្ត ជួយបង្កើតឱ្យមានប្រព័ន្ធនៃការទំនាក់ទំនងជាផ្លូវការ មានឋានានុក្រមនៃការធ្វើសេចក្ដីសម្រេចចិត្តយល់ច្បាស់ពីការងារដែលត្រូវធ្វើក្នុងកិច្ចការនីមួយៗ បង្កើតឱ្យមានទេពកោសល្យសម្រាប់បុគ្គលិកតាមរយៈការអភិវឌ្ឍចំណេះ ជំនាញ បទពិសោធន៍ ស្គាល់ពីតម្រូវការរបស់បុគ្គលិក។ល។ ដែលទាំងនេះជាអភិក្រមបង្កើតឱ្យមានមូលដ្ឋានគ្រឹះសម្រាប់មុខងារធនធានមនុស្ស និងមានការរៀបចំផែនការសម្រាប់អនាគត ជាពិសេសគឺការកើនឡើងនូវការវិនិយោគលើផ្នែកធនធានមនុស្ស។

ការគ្រប់គ្រងធនធានមនុស្ស បង្កើតឱ្យមានការអនុវត្តការងារដែលមានលទ្ធផលខ្ពស់ឬបង្កើនតម្លៃខ្ពស់( High Performance Work Practices)ដល់អង្គភាពនិងបុគ្គលផ្ទាល់ខ្លួន ដោយសារតែការអនុវត្តបែបនេះបានផ្ដល់នូវគម្រូដ៏ល្អមួយតាមរយៈ៖

-ការជ្រើសរើសបុគ្គលិកដែលមានលក្ខណៈបើកទូលាយ និងតាមគោលការណ៍
-ការបណ្ដុះបណ្ដាលជំនាញ បង្ហាត់បង្ហាញ និងណែនាំ
-ការតម្រង់ទិសទៅរកការងារជាក្រុម
-ការច្នៃប្រឌិត និងនវានុវត្តន៍ក្នុងការងារ
-ដំណើរការ និងនីតិវិធីគ្រប់គ្រងត្រូវបានពង្រឹងជាប់ជានិច្ច
-ការដោះស្រាយបញ្ហា និងសំណើផ្សេងៗរបស់បុគ្គលិកបានទាន់ពេលវេលា
-ការប្រើវិធីអង្កេតទៅលើឥរិយាបថ និងការប្រព្រឹត្តរបស់បុគ្គលិក
-ការបង្កើតទំនាក់ទំនងល្អ កិច្ចសហប្រតិបត្តិការ និងការចែករំលែកព័ត៌មាន
-ផ្ដល់តម្លៃតបស្នងដល់បុគ្គលិកឱ្យសមស្របទៅតាមស្នាដៃ និងទំហំការងារ។

ដោយឡែកនៅខាងក្រៅអង្គភាព ការគ្រប់គ្រងធនធានមនុស្ស មានសារៈសំខាន់ផងដែរសម្រាប់ផ្សារភ្ជាប់ទំនាក់ទំនងរវាងអង្គភាពនិងអង្គភាព រវាងស្ថាប័នមួយនិងស្ថាប័នមួយផ្សេងទៀតដើម្បីទទួលបានព័ត៌មានការងារ ការរៀបចំក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រកម្រិតជាតិ-អន្តរជាតិ ដែលជាការឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅក្នុងបរិបទនៃសកលភាវូបនីយកម្ម៕

# គន្ថនិទ្ទេស


១- ជួន ណាត *វចនានុក្រមខ្មែរ ភាគទី១ ពុទ្ធសាសនបណ្ឌិត្យ* បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧
២- ហ៊ុន សែន *សុន្ទរកថានៅក្នុងពិធីបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០២២* នៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២
៣- A.Invanovic & P.H.Collin, *Dictionary of Human Resources and Personnel Management,* London, Third edition, 2003.
៤- Della Thompson, *The Oxford Dictionary of Current English*, Second Edition, 1993.
៥- Goldfrey Edwards, *Introduction to Public Administration,* New York, 2017.
៦- Jacques Chevallier, *Science administrative*, 6th Edition, Paris, 2019.
៧- John M. Pynes, *Human Resource Management*, McGraw-Hill it'l, 11th Edition,2010.
៨- John A. Pearce II & Richard B. Robinson, *Strategic Management,* 10th Edition, 2007.
៩- Joan E. Pynes, *Human Resource Management for Public and Nonprofit Organizations*, Second Edition, 2004.
១០-Lloyd L. Byars & Leslie W. Rue, *Human Resource Management*, Ninth Edition, 2008.
១១-Manmohan Joshi, *Human Resource Management*, 2013.
១២-Michael Armstrong, *Strategic Human Resource Management,* 4th Edition, 2008.
១៣-Oxford University Press, *Strategic Human Resource Management,* 2007.
១៤-Patrick M.Wright, *Human Resource Strategy, SHRM Foundation,* 2008.
១៥-Petter Boxall, John Purcell and Patrick Wright, *Human Resource Management,* Oxford University Press, First published, 2007.
១៦-ROBERT L. MATHIS & JOHN H. JACKSON, *Human Resource Management,* Twelfth Edition, 2008.
១៧-Socrates, *HUMAN RESOURCE DICTIONARY*, INDIANA, 2006.
១៨-Stephen P. Robbins & Mary Coulter, *Management*, Eighth Edition, 2005.
១៩-The Open University of Hong Kong, *Human resource management*, 2013.
២០-University of London, *Human resource management*, 2013.
២១-Wendell L., *French Human Resource Management*, 2006.
២២-Zorlu Senyucel, *Managing the Human Resource in the 21st Century*, 2009.

# "ទ្រឹស្តីស្ត្រីបរិបទសកល និងតួនាទីក្នុងកងយោធពលខេមរភូមិន្ទ នៅកម្ពុជា"

បេក្ខជនបណ្ឌិត **ដាំ ដារីនី**
ជំនាញ រដ្ឋបាលសាធារណៈ
ជំនាន់ទី២ វគ្គ១

## ទ្រឹស្តីពាក់ព័ន្ធនឹងយេនឌ័រជាសកល

### និយមន័យស្ត្រី

" ស្រី " ពាក្យឃ្លាតមកពីពាក្យសំស្ក្រឹតថា "ស្ត្រី" គឺជាមនុស្សដែលមានភេទទីទៃពីបុរស[១]។

" ស្ត្រី " គឺសំដៅលើភេទជាស្រីដែលកំណត់ដោយកត្តាជីវសាស្ត្រ។ និយមន័យ " ស្ត្រី " គឺសំដៅលើក្មេងស្រី ស្រីជំទង់ ស្រីវ័យកណ្តាល និងចំណាស់។ "ស្ត្រី" មានសមត្ថភាពក្នុងការពពោះ ផ្តល់កំណើត មានអវៈយវៈដូចជាសុដន ស្បូនជាដើម ផ្ទុយពីបុរសដែលមានលិង្គ និងមិនអាចពពោះបាន។ ការកំណត់ពីធម្មជាតិលើអវៈយវៈភេទរបស់ទារក ដើម្បីជានាការចុះបញ្ជីកំណើតនិងភេទ[២]។

### ទ្រឹស្តីយេនឌ័រ និងភេទ

" យេនឌ័រ " គឺជាផ្នត់គំនិត ការកំណត់ ជាឥរិយាបថរបស់សង្គម សហគមន៍ ឬគ្រួសារ។ ដូចនេះយេនឌ័រគឺជាការកំណត់អំពីសិទ្ធិ តួនាទី ការទទួលខុសត្រូវ និងការសំរេចចិត្តរបស់មនុស្ស ប្រុស មនុស្សស្រី ដោយសង្គម សាសនា និងវប្បធម៌ ហើយអាចផ្លាស់ប្តូរបានទៅតាមកាលៈទេសៈ។ តួនាទីយេនឌ័រពិតជាមានសារៈសំខាន់ណាស់ ក្នុងការចូលរួមយ៉ាងសកម្មក្នុងសកម្មភាពទាំង ឡាយរបស់បុរស ស្ត្រី គ្រួសារ និងសហគមន៍ដើម្បីអភិវឌ្ឍន៍គ្រួសារ និងសហគមន៍។ គេអាចធ្វើការកំណត់បានថាយេនឌ័រជាភាពស្មើគ្នារវាងបុរស និងស្ត្រីអំពីសិទ្ធិ តួនាទី ការទទួលខុសត្រូវ និងការសម្រេចចិត្តដែលកំណត់ដោយសង្គមវប្បធម៌ ហើយអាចផ្លាស់ប្តូរបានតាមពេលវេលា និងស្ថានភាពជាក់ស្តែង[៣]។

" ភេទ " សំដៅលើភាពខុសគ្នាផ្នែកជីវសាស្ត្រ ដែលបានកំណត់រវាងបុរស និងស្ត្រី។ ត្រូវបានប្រើប្រាស់នៅពេលចង់សំដៅទៅលើបុរស និងស្ត្រី ដែលមានសរីរាង្គកាយផ្សេងពីគ្នាលក្ខណៈរូបសាស្ត្រ។ ហេតុនេះភាពខុសគ្នាបានបង្ហាញថា ភេទ គឺជាកត្តាលក្ខខណ្ឌជីវសាស្ត្រ ដូច្នេះមិនអាចកែប្រែបាន ចំណែកយេនឌ័រគឺជាកត្តាលក្ខខណ្ឌសង្គមដូច្នេះអាចកែប្រែបាន។

---

[១] ជួនណាត *វចនានុក្រមខ្មែរ ភាគ១-ភាគ២* បោះពុម្ពទី៥ ការផ្សាយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យភ្នំពេញ ឆ្នាំ១៩៦៧ ទំព័រទី១៤៨០

[២] Candida March, *A Tool Kit Concepts and Frameworks for Gender Analysis*, in 1999 OXFAM GB.

[៣] សទ្ទានុក្រមយេនឌ័រ ក្រសួងកិច្ចការនារី ឆ្នាំ២០០៦ ទំព័រទី១១

## តួនាទីស្ត្រី(យោធិននារី)ក្នុងកងយោធពលខេមរភូមិន្ទ

គោលនយោបាយការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦ គឺជាត្រីវិស័យសម្រាប់កងយោធពលខេមរភូមិន្ទក្នុងការរួមចំណែកអនុវត្តគោលនយោបាយនានារបស់រាជរដ្ឋាភិបាលកម្ពុជា កងយោធពលខេមរភូមិន្ទមានការរីកចម្រើនលើគ្រប់វិស័យទាំងផ្នែកគុណភាព សមត្ថភាព ជំនាញ និងបច្ចេកទេសព្រមទាំងបំពាក់គ្រឿងយុទ្ធោបករណ៍ទំនើបៗ ដើម្បីបំពេញតួនាទី៤យ៉ាងរបស់ខ្លួន គឺការពារផលប្រយោជន៍ដ៏ខ្ពង់ខ្ពស់របស់ជាតិ ធានាសុខសន្តិភាព សុវត្ថិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម ជូនប្រជាជន រួមចំណែកក្នុងកសាងជាតិ អភិវឌ្ឍន៍ជាតិ បង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិលើគ្រប់ផ្នែក និងចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពលើពិភពលោកក្នុងក្របខណ្ឌកងកម្លាំងរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ។ នៅក្នុងវិស័យការពារជាតិក៏បានបង្ហាញថា " កងយោធពលខេមរភូមិន្ទ ត្រូវគិតគូឡើងវិញអំពីភាពស្មើគ្នានៃយេនឌ័រ "[៤]។ គោលការណ៍សំខាន់គឺត្រូវផ្តល់តម្លៃ សិទ្ធិ និងឱកាសស្មើគ្នាសម្រាប់ស្ត្រី និងបុរសជាយោធិនក្នុងការបំពេញការងារ ការតែងតាំងតួនាទី ឋានៈ ឋានន្តរសក្តិ និងការទទួលផលប្រយោជន៍ផ្សេងៗ ដើម្បីឆ្លើយតបគោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលគឺ ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គមពង្រឹងតួនាទីស្ត្រី ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ។ យោធិនារីនៃកងយោធពលខេមរភូមិន្ទមានតួនាទីសំខាន់ៗ ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ក្នុងវិស័យអប់រំ កីឡា សេដ្ឋកិច្ច ទទួលការបណ្តុះបណ្តាលស្របទៅតាមចំណេះដឹង ជំនាញ បទពិសោធន៍ ការហ្វឹកហ្វឺនតាមសាលា ទទួលបានការផ្សព្វផ្សាយស្តីអំពីច្បាប់ គោលនយោបាយជាតិ និងអន្តរជាតិ លិខិតបទដ្ឋានគតិយុត្តនានាទាក់ទងការលើកកម្ពស់យេនឌ័រ និងចូលរួមជាកងកម្លាំងក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។ល។

## ការវិភាគយេនឌ័រក្នុងកងយោធពលខេមរៈភូមិន្ទ

ការរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមបណ្តាក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួង ស្ថាប័ននីមួយៗត្រូវរៀបចំឱ្យមានផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងរយៈពេល៥ឆ្នាំដើម្បីឆ្លើយតបទៅនឹងការលើកកម្ពស់ស្ត្រីនៅទូទាំងប្រទេស។ យោធិននារីនៅក្នុងកងយោធពលខេមរភូមិន្ទមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ទទួលបានការលើកទឹកចិត្ត និងឱកាសជាច្រើនពីថ្នាក់ដឹកនាំទាំងតួនាទី ឋានៈ ឋានន្តរសក្តិ និងតំណែងសំខាន់ៗជាច្រើន ដោយគិតទាំងអតីតភាពការងារ បទពិសាធន៍ សមត្ថភាព ជំនាញ ចំណេះដឹង កាយសម្បទា និងគុណធម៌ មិនតែប៉ុណ្ណោះគឺផ្តោតការចូលរួមគ្រប់កាលៈទេសៈក្នុងការបំរើជាតិមាតុភូមិ និងប្រជាជនកម្ពុជាគឺមានវត្តមានរបស់ស្ត្រីចូលរួមផងដែរ។ ការទទួលបានទាំងនេះដោយសារការយកចិត្តទុកដាក់ពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ថ្នាក់ដឹកនាំក្រសួងការពារជាតិ អគ្គបញ្ជាការដ្ឋាន និងមេបញ្ជាការគ្រប់លំដាប់ថ្នាក់ គឺបានផ្តល់នូវកម្លាំងកាយ ចិត្ត ក្តីសង្ឃឹមក្នុងការបំពេញការងាររួមទាំងបើកឱកាសដល់យោធិននារីចូលរួមគ្រប់ការងារសកម្មភាពដូចបុរសដែរ។ ការបង្កើតជាបណ្តាញ

---

[៤] *« ការពារព្រះរាជាណាចក្រកម្ពុជា »* សន្តិសុខ ការអភិវឌ្ឍន៍ និងកិច្ចសហការអន្តរជាតិ ក្រសួងការពារជាតិ បោះពុម្ពឆ្នាំ២០០៦

ក្រុមការងារយេនឌ័រនៅទូទាំងកងយោធពលខេមរភូមិន្ទ គឺជាយន្តការមួយដ៏សំខាន់ក្នុងការដឹកនាំត្រួតពិនិត្យលើស្ថានភាពយោធិននារីក្នុងកងយោធពលខេមរភូមិន្ទក្នុងការលើកជាអនុសាសន៍ សំណូមពរ កង្វល់នានា និងបញ្ហាប្រឈម ជូនដល់ថ្នាក់ដឹកនាំគិតពិចារណានៅពេលយោធិននារីជួបក្នុងអំឡុងពេលបំរើការងារដូចជា សមត្ថភាពនៅមានកម្រិត កាយសម្បទាមិនរឹងមាំ មានការរើសអើងនៅអង្គភាព មានការបៀតបៀន មិនអាចចូលរួមក្នុងការហ្វឹកហ្វឺន មិនបានចូលរួមក្នុងបេសសកម្មនានា ការខ្វះខាតនៅក្នុងជីវភាពប្រចាំថ្ងៃ ជួបបញ្ហាសុខភាព និងបញ្ហាដ៏ទៃទៀតកើតមានឡើងដោយថាហេតុ។ ការស្វែងរកប្រភពធនធាន រួមទាំងផ្នែកសម្ភារៈ មធ្យោបាយនានា បច្ចេកទេស និងហិរញ្ញវត្ថុគាំទ្រដើម្បីធានានិរន្តន៍ភាពឱ្យឆ្លើយតបទៅនឹងតម្រូវការនៃការបញ្ជ្រាបយេនឌ័រនៅក្នុងកងយោធពលខេមរភូមិន្ទ ទំនាក់ទំនងគ្នាពីបណ្តាក្រសួង ស្ថាប័ន រួមទាំងអង្គការជាតិ និងអន្តជាតិ និងដៃគូអភិវឌ្ឍន៍ក្នុងការលើកកម្ពស់ការបញ្ជ្រាបយេនឌ័រនៅក្នុងកងយោធពលខេមរភូមិន្ទពិតជាមានសារៈសំខាន់ណាស់។ ការពង្រឹង និងពង្រីកសមត្ថភាព ជំនាញ វិជ្ជាជីវៈ គឺមិនត្រូវគិតតែត្រឹមក្នុងប្រទេសតែត្រូវខិតខំធ្វើយ៉ាងណាជំរុញបានការកសាងសមត្ថភាពខ្ពស់ទាំងកម្រិតតំបន់ និងអន្តរជាតិ។ ដូចនេះការបញ្ជ្រាបយេនឌ័រទៅក្នុងកម្មវិធីនានារបស់កងយោធពលខេមរភូមិន្ទ គឺធ្វើយ៉ាងណាស្ត្រីទទួលបានផលប្រយោជន៍ស្មើភាពគ្នាជាមួយនឹងបុរសត្រូវខិតខំការតែក្នុងល្បឿនលឿនជាងមុន និងបន្តជំរុញស្ត្រីការចូលប្រលងក្របខណ្ឌជាយោធិននារីនៃកងយោធពលខេមរភូមិន្ទបន្ថែមទៀត ជាគោលការណ៍ជ្រើសរើសយោធិនជានារី១០%ក្នុង១ឆ្នាំ[៥]។

## ការបញ្ជ្រាបយេនឌ័រក្នុងកងយោធពលខេមរៈភូមិន្ទ

ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៩ ក្រសួងការពារជាតិបានធ្វើការបញ្ជ្រាបយេនឌ័រក្នុងកងយោធពលខេមរភូមិន្ទតាមរយៈការធ្វើសិក្ខាសាលាថ្នាក់ជាតិ វគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេសសរុបចំនួន ១១៥លើក មានយោធិនទាំងពីរភេទជាសិក្ខាកាមមានចំនួនសរុប២២,៣៦២នាក់ យោធិននារីមានចំនួនសរុប ១៧, ៧៦៦នាក់[៦] ការបញ្ជ្រាបយេនឌ័រជូនយោធិនទាំងពីរភេទមានដូចជាៈ

-ផ្សព្វផ្សាយច្បាប់ គោលនយោបាយជាតិ អន្តរជាតិ លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធតាមរយៈការធ្វើសិក្ខាសាលាថ្នាក់ជាតិ និងវគ្គបណ្តុះបណ្តាលនានា។

-ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងរយៈពេល៥ឆ្នាំ របស់ក្រសួងការពារជាតិចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០។

-ផ្សព្វផ្សាយអនុសាសន៍១១ចំណុចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

---

[៥] ប្រសាសន៍របស់សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិថ្លែងក្នុងពិធីអបអរសាទទិវាអន្តរជាតិនារី៨មីនា ឆ្នាំ២០១៥ ក្រសួងការពារជាតិ។

[៦] របាយការណ៍បូកសរុបការងារយេនឌ័រយៈពេល៥ឆ្នាំ របស់ក្រសួងការពារជាតិ ផ្នែកយេនឌ័រ ឆ្នាំ២០១៩

-ជំរុញការចូលរួមរបស់ស្ត្រីក្នុងវគ្គហ្វឹកហ្វឺន បណ្តុះបណ្តាល ទាំងក្នុង និងក្រៅប្រទេស។

-បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលយេនឌ័រ។

-ជំរុញការបញ្ជូនកងកម្លាំងជាយោធិននារីក្នុងបេសកកម្មរក្សាសន្តិភាពនៅអង្គការសហប្រជាជាតិ។

-បេសកកម្មចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការបញ្ជ្រាបយេនឌ័រតាមបណ្តាអង្គភាពនានា។

## ច្បាប់ លិខិតបទដ្ឋានគតិយុត្តជាតិ អន្តរជាតិ និងគោលនយោបាយលើកកម្ពស់ស្ត្រីនៅកម្ពុជា

កម្ពុជាមានច្បាប់ គោលនយោបាយជាតិ លិខិតបទដ្ឋានគតិយុត្ត និងមានវិធានការយន្តការជាតិជាច្រើនសុទ្ធតែបានលើកកម្ពស់តម្លៃ និងការពារផលប្រយោជន៍ស្ត្រី។ កម្ពុជាមានច្បាប់រដ្ឋធម្មនុញ្ញ ក្រមព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ច្បាប់ស្តីពីការងារ ច្បាប់ស្តីពីការទប់ស្កាត់អំពីហិង្សាក្នុងគ្រួសារ និងកិច្ចការជនរងគ្រោះ ច្បាប់ស្តីពីការបង្ក្រាបអំពីជួញដូរមនុស្ស និងអំពីធ្វើអាជីវកម្មផ្លូវភេទ គោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ។ល។ ចំពោះបទដ្ឋានគតិយុត្តអន្តរជាតិ គឺអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទស៊ី.ដ.(CEDAW)។ សន្និសិទស្តីពីស្ត្រីពិភពលោកលើកទី៤ នៅទីក្រុងប៉េកាំង បានអនុម័តផែនការការសកម្មភាពនៅទីក្រុងប៉េកាំងហើយបានរៀបចំរបាយការណ៍រីកចម្រើនចាប់ពីឆ្នាំ១៩៩៥មក។ យុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលកម្ពុជា ដំណាក់កាលទី៣ និងទី៤ ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ និងទី៥ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៥ និងយន្តការជាតិលើកកម្ពស់ស្ត្រីនៅកម្ពុជា។

## ស្ត្រីជាយោធិននៅក្នុងឆាកអន្តរជាតិ

ការលើកយកទ្រឹស្តី និងការលើកកម្ពស់ស្ត្រីជាយោធិននៅតំបន់អាស៊ីមានដូចជាៈ ប្រទេសឥណ្ឌា ប្រទេសថៃ ប្រទេសវៀតណាម និងប្រទេសឡាវ និងស្ត្រីជាយោធិននៅអ៊ឺរ៉ុបមានដូចជាៈ ប្រទេសបារាំង និងប្រទេសអាឡឺម៉ង់អំពីការរីកចម្រើន និងភាពជោគជ័យក្នុងការលើកកម្ពស់យោធិនជាស្ត្រី។

## ទ្រឹស្តីពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយសាធារណៈ

អ្នកដំបូងគេ អ្នកដែលបានរៀបចំបង្កើតការសិក្សាគោលនយោបាយសាធារណៈគឺលោក **ចន ឌីវ៉េ** (Jonh Deway) លោកបានរៀបចំចងក្រងជាសៀវភៅមួយមានចំណងជើងថា**ឡូ ជីក** *(Logic)* ***The Theory of Inquiry*** ក្នុងស្នាដៃនេះមានការលើកឡើងនូវចំណុចសំខាន់ៗ មួយចំនួនដូចជាសកម្មភាពជ្រើសរើសផ្សេងៗ មុខវិជ្ជាគោលនយោបាយជាមុខវិជ្ជាមួយដែលមិនអាចកាត់ចេញពីមុខវិជ្ជាដ៏ទៃ គឺសិក្សាអំពីអភិក្រមនៃការបង្កើតការសម្រេចចិត្តឬអភិក្រមជ្រើសរើស និងវាយតម្លៃព័ត៌មានដែលទទួលបានដើម្បីដោះស្រាយបញ្ហាណាមួយ។[៧]។ សារៈសំខាន់នៃគោលនយោបាយសាធារណៈ គឺការបង្កើនចំណេះដឹង កត្តាអ្វីខ្លះដែល

---

[៧] សៀវភៅ Dye Thomas R.,1981***, Understanding Public policy***. Prentice-Hall, New Jersey.

ជំរុញគោលនយោបាយមួយកើតមានឡើង មានផលប៉ះពាល់អ្វីខ្លះនៅក្រោយពេលគោលនយោបាយមួយបានកើតឡើង ជួយប្រតិបត្តករក្នុងការដោះស្រាយបញ្ហាសាធារណៈ អ្នកប្រតិបត្តិមានមូលដ្ឋានទ្រឹស្តីក្នុងការបង្កើតគោលនយោបាយសាធារណៈដែលល្អ និងកាត់បន្ថយបាននូវបរាជ័យក្នុងការអនុវត្តន៍គោលនយោបាយ។ ប្រយោជន៍សម្រាប់គោលបំណងនយោបាយ ដែលបានបង្កើតឡើងដោយផ្អែកលើអភិក្រមដែលត្រឹមត្រូវ និងមានការគាំទ្រពីទ្រឹស្តីដ៏រឹងមាំគឺមានជំហរយ៉ាងរឹងមាំចំពោះការរិះគន់ពីដៃគូប្រកួតប្រជែងនយោបាយ។ ទ្រឹស្តីការអនុវត្តនៃគោលនយោបាយសាធារណៈ គោលនយោបាយដែលបានជ្រើសរើស(សម្រេច) យកមកមិនទាន់ធានាថាជាគោលនយោបាយដែលទទួលបានជោគជ័យពិតប្រាកដនៅក្នុងការអនុវត្តន៍ទាំងអស់នោះទេ។ ការបង្កើតគោលនយោបាយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ សម្រាប់ដោះស្រាយបញ្ហាគឺជាការប្រសើរ។ មានកត្តាជះឥទ្ធិពលទៅលើការអនុវត្តន៍គោលនយោបាយ កត្តាទាំងនោះអាចស្តែងឡើងតាមរយៈទ្រឹស្តីដូចខាងក្រោម៖

-ទ្រឹស្តីលោកចោច សី អេវ៉ាតទី៣ (George C. Edwards III) បានលើកឡើងមានកត្តា៤ ដែលជះឥទ្ធិពលទៅលើការអនុវត្តន៍គោលនយោបាយគឺ៖ ទំនាក់ទំនង ធនធាន លក្ខណៈសម្បត្តិ និងរចនាសម្ព័នការិយាល័យធិបតេយ្យ។

-ទ្រឹស្តីលោក ឌ័រ អេស វ៉ាន់ម៉ែត (Doned S.Van Meter) និងលោក ឆាល អី វ៉ាន់ ហ៊ន (Carl E.Van Horn) បានលើកឡើងនូវកត្តាមួយចំនួន ដែលមានឥទ្ធិពលលើការអនុវត្តន៍គោលនយោបាយសាធារណៈរួមមានៈ ស្តង់ដា ធនធាន ទំនាក់ទំនងអន្តរអង្គភាព ឬស្ថាប័ន ចរិតលក្ខណៈទីភ្នាក់ងារអនុវត្តលក្ខខណ្ឌសង្គមនយោបាយ និងសេដ្ឋកិច្ច និងលក្ខណៈសម្បត្តិអ្នកអនុវត្ត។

ឆ្លងកាត់តាមការស្រាវជ្រាវ ទៅតាមលក្ខណៈការវិភាគប្រៀបធៀបទៅលើទ្រឹស្តីនៃការអនុវត្តន៍គោលនយោបាយទាំងពីរ ដោយឆ្លុះបញ្ចាំងទៅលើសារៈប្រយោជន៍គឺយើងអាចសំយោគចេញតាមរយៈការស្វែងយល់នៃការអនុវត្តន៍ជាក់ស្តែង ចំពោះការលើកកម្ពស់ស្ត្រី(យោធិននារី)នៅក្នុងកងយោធពលខេមរៈភូមិន្ទរួមមានៈ ឆន្ទៈនយោបាយរបស់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ធនធាន ការចូលរួមរបស់ភាគីពាក់ព័ន្ធ ទំនាក់ទំនងអន្តរអង្គភាព និងគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត ។

# គន្ថនិទ្ទេស

## ក-ឯកសារភាសាខ្មែរ៖


- កៅ មុយថង ៖ « *គោលនយោបាយសាធារណៈ* » គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ ឆ្នាំ២០១០។
- *«កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងទី៤»* របស់រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៣ និងឆ្នាំ២០១៨។
- « *ការពារព្រះរាជាណាចក្រកម្ពុជា* » សន្តិសុខ ការអភិវឌ្ឍន៍ និងកិច្ចសហការអន្តរជាតិ ក្រសួងការពារជាតិ បោះពុម្ពឆ្នាំ២០០៦។
- « *ផែនការនារីរតនៈទី៤* » ក្រសួងកិច្ចការនារី ឆ្នាំ២០១៨។
- ជួនណាត ៖ *«វចនានុក្រមខ្មែរ ភាគ១-ភាគ២»* បោះពុម្ពទី៥ ការផ្សាយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ឆ្នាំ១៩៦៧ ។
- « *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា* » ឆ្នាំ១៩៩៣។
- អនុសញ្ញាអន្តរជាតិស្តីពី*ការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនិងស្ត្រីភេទស៊ី.ដ. (CEDAW)*។
- « *ផែនការនារីរតនៈទី៥*» ក្រសួងកិច្ចការនារី បោះពុម្ពឆ្នាំ២០១៩ ។
- សៀវភៅ « *វិវេចនាយុទ្ធសាស្ត្រការពារជាតិ* » ក្រសួងការពារជាតិ ឆ្នាំ២០១៣។
- សៀវភៅ « *សទ្ទានុក្រមយេនឌ័រ* » ក្រសួងកិច្ចកានារី ឆ្នាំ២០០៦ ។


## ខ-ឯកសារជាភាសាបរទេស៖


- Candida March, ***A Tool Kit Concepts and Frameworks for Gender Analysis Framework***,1999 OXFAM GB.
- Anita P. Pant, ***Good practice Gender Equality in Basic Education and Lifelong Learning*** through CLCs: Experience from 15 countries*, 2003,* UNESCO**.**
- Dye Thomas R.,1981***, Understanding Public policy***. Prentice-Hall, New Jersey.
- A Jossey-Bass Reader and Jossey A. Miles, "***Management and Organization Theory"*** published by Jossey-Bass, San Francisco, USA 2021.


## គ-ឯកសារពីគេហទំព័រ៖


-http://www.2020 vietnam Military Strength (globalfirepower.com) date 30/11/2020
-http://www.2020 Laos Military Strength (globalfirepower.com) date 29/11/2020
-http://www. Laos Population (2020) - worldometer (worldometers.info) date 29/11/2020
-http://www.domesticViolence France ,European, South Africa September, 2008 date 28/11/2020
-https://en.wikipedia.org/wiki/Royal_Cambodian_Armed_Forces

# ស្ត្រីកម្ពុជាក្នុងសម័យសកលភាវូបនីយកម្ម

Cambodian Women in the Age of Globalization

បេក្ខជនបណ្ឌិត **តាន់ ផល្លី**
ឯកទេស ៖ ទស្សនវិជ្ជា
ជំនាន់១ វគ្គ២

សម័យបុរាណកន្លងផុតទៅ គេសង្កេតឃើញអត្រាអក្ខរកម្មរបស់ស្ត្រីមានច្រើនគួរឱ្យចាប់អារម្មណ៍។ ក្នុងពេលនៃការផ្លាស់ប្តូរប្រវត្តិសាស្ត្រចុងសតវត្សទី១៨ ស្ត្រីបានរៀនសូត្រចេះដឹងចំនួនតិចតួច ក្នុងចំណោមស្ត្រីដែលបានរៀនចេះដឹងក្លាយជាភាពលេចធ្លោនិងមានស្នាដៃល្អប្រសើរហើយមានកំណត់ត្រា មានសម្លេងក្នុងប្រវត្តិសាស្ត្រ។ ការសរសេររបស់ស្ត្រីមានលក្ខណៈគួរឱ្យចាប់អារម្មណ៍ដែលធ្វើឱ្យស្ត្រីបានយល់ដឹងពីគុណតម្លៃដើមរបស់ពួកគេ។ ការប្រកួតប្រជែងគ្នាដើម្បីទទួលបានកិត្តិយស និងកេរ្តិ៍ឈ្មោះក្នុងការសរសេរតាមរយៈ ទេពកោសល្យ សមត្ថភាពប្រាជ្ញា លក្ខណៈធម្មជាតិដែលបានរៀនសូត្រទៅលើសីលធម៌និងទស្សនៈវិជ្ជានៅក្នុងសហគមន៍អ្នកសិក្សា។

សម័យបន្ទាប់មក មានការរីកចំរើនផ្នែកអប់រំជាងមុន គេកត់សម្គាល់ឃើញនូវការប្រឹងប្រែងក្នុងការលុបបំបាត់អក្ខរកម្មរបស់ស្ត្រី និងផ្តល់ការអប់រំដល់កុមារី យុវតី ស្ត្រីវ័យក្មេងក្នុងតំបន់ជនបទដាច់ស្រយាលមានកម្រិតបឋមសិក្សា មធ្យមសិក្សា។ កត្តាភូមិសាស្ត្រ ជីវភាពរស់នៅ ភាពក្រីក្រ ទំនៀមទម្លាប់ប្រពៃណីដែលបង្ខំឱ្យសិស្សស្រីបញ្ឈប់ការសិក្សា ដោយសារពួកគេមិនអាចធ្វើចំណាកស្រុកចេញទៅតំបន់ទីប្រជុំជន ដើម្បីទទួលការអប់រំ កម្រិតអនុវិទ្យាល័យ វិទ្យាល័យ និងមហាវិទ្យាល័យ ដូច្នេះការបោះបង់ការសិក្សាក្នុងចំណោមសិស្សស្រីនៅមានកម្រិតខ្ពស់គួរឱ្យកត់សម្គាល់នៅឡើយ។ ទំនៀមទម្លាប់ប្រពៃណីក្នុងអតីតកាលដែលជាឥរិយាបថផ្នែកវប្បធម៌ និងសង្គមរបស់ជាតិខ្មែរបានដាក់គំនាបឱ្យស្ត្រីខ្មែរមានបន្ទុកយ៉ាងតឹងរឹងក្នុងវិស័យអប់រំដែលបានកំណត់ឱ្យកូនស្រីស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឳពុកម្តាយ "នំមិនធំជាងនាឡិ" ការដាក់បន្ទុកលើស្ត្រីដែលសង្គមកម្ពុជានាពេលនោះ បានឱ្យតម្លៃការអប់រំសិក្សារបស់កូនប្រុសខ្ពស់ជាងកូនស្រី។

ក្រោយថ្ងៃរំដោះពីរបបប្រល័យពូជសាសន៍ មានការកែប្រែឥរិយាបថពីអតីតកាលដោយបានយល់ដឹងលើការទទួលខុសត្រូវរួមរបស់បុរស និងស្ត្រី អំពីឧត្តមប្រយោជន៍របស់កុមារា កុមារី មាត្រា៤៧.១ រដ្ឋធម្មនុញ្ញបានចែងថា "មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ"។ សិទ្ធិស្ត្រីកំពុងមានការផ្លាស់ប្តូរ ដោយមានយល់ដឹងច្រើនជាងមុនអំពីសិទ្ធិស្ត្រី អ្នករស់នៅទីក្រុងមានការគាំទ្រកាន់តែច្រើនជាងស្ត្រីនៅជនបទ។ រីឯការសិក្សាអប់រំដល់កូនក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់។ មាតាបិតាបានខិតខំបន្តយកចិត្តទុកដាក់លើការអប់រំរបស់កូនប្រុសស្រីស្មើភាពគ្នាអាស្រ័យលើសមត្ថភាពរបស់កូន ដោយយល់ច្បាស់ថាការអប់រំជាធនធានដ៏សំខាន់ដើម្បីចូលរួម កសាងប្រទេសឱ្យក្លាយជាប្រទេសសម្បូណ៌រុងរឿង ជាពិសេសអភិវឌ្ឍខ្លួនឯងឱ្យមានប្រយោជន៍ក្នុងសង្គម ឱ្យយល់ដឹងពីតម្លៃរបស់ខ្លួនក្នុងការស្វះស្វែងកសាងជីវភាពប្រកប

ដោយសមត្ថភាព មានភាពក្លាហាន កិត្តិយសថ្លៃថ្នូរដោយមានការទទួលខុសត្រូវចំពោះខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងសេដ្ឋកិច្ចជាតិ។

បច្ចុប្បន្ននេះគេសង្កេតឃើញមានការអប់រំមាតាបិតា ការអប់រំក្នុងប្រព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា ឯការអប់រំក្រៅប្រព័ន្ធបន្ថែមគឺធ្វើតាមអង្គការក្រៅរដ្ឋាភិបាលនានា ជាពិសេសចំពោះកុមារី យុវតី ស្ត្រីវ័យក្មេងតាមជនបទដើម្បីចូលរួមលើកកម្ពស់គុណភាព ធនធានមនុស្សក្នុងការងារអភិវឌ្ឍន៍សង្គមនិងសេដ្ឋកិច្ចជាតិ។ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើនអាហារូបករណ៍ដល់និស្សិតនារីឱ្យចូលរៀនតាមគ្រឹះស្ថានឧត្តមសិក្សានិងឯកជន មានចំនួនជាង៥០០០នាក់ (២០១៩ - ២០២០) ក្នុងនោះផ្តល់អាទិភាពដល់សិស្សពូកែ សិស្សក្រីក្រ សិស្សមកពីតំបន់ជាច់ស្រយាល។ សិស្សនារីដែលបានបញ្ចប់ថ្នាក់ឧត្តមសិក្សា បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតមានការកើនឡើងគួរឱ្យកត់សម្គាល់។ សិស្សនារីដែលទទួលបានអាហារូបករណ៍ទៅសិក្សាក្រៅប្រទេសក៏មានចំនួនច្រើនដែរ ក្នុងនោះមានសាលារដ្ឋ សាលាឯកជនដែលមានកម្រិត និងគុណភាពស្មើសាលារដ្ឋ ដើម្បីជួយបង្កើនធនធានមនុស្សឱ្យកាន់តែប្រសើរ និងលើកកម្ពស់នារីមានចំនួនកាន់តែច្រើនដែលអាចជួយការងារប្រទេសជាតិល្អប្រសើរ។ ការលើកកម្ពស់ស្ត្រីកម្ពុជាតាមរយៈការអប់រំកុមារី យុវតី និងស្ត្រីវ័យក្មេងឱ្យមានកម្រិតខ្ពស់ដែលជាធនធានមនុស្សមិនអាចខ្វះបាន ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិឱ្យជឿនលឿន យុវជនជាគ្រឹះនៃសង្គមអនាគតនៃសង្គម សង្គមរីកចម្រើនបាន យើងត្រូវតម្រង់ទិសយុវជន យុវតីឱ្យរឹងមាំដើម្បីអនាគតសង្គមជាពិសេសក្នុងសង្គមសកលភាវូបនីយកម្ម។

ក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត ត្រូវទទួលបានជាជំហានៗដើម្បីឱ្យការអប់រំនេះបានទៅដល់នារីគ្រប់រូបក្នុងការកសាងជីវិត។ បច្ចុប្បន្នស្ត្រីបានចូលរួមយ៉ាងសកម្មគ្រប់វិស័យក្នុងការអភិវឌ្ឍន៍សង្គមជាតិដូចជាវិស័យសាធារណៈនយោបាយ វិស័យសេដ្ឋកិច្ចឯកជន សង្គមស៊ីវិល សមាគម និងអង្គការក្រៅរដ្ឋាភិបាល ការងារស្ម័គ្រចិត្ត ដើម្បីបង្ហាញពីសក្តានុពលរបស់ខ្លួនក្នុងការរួមចំណែកកិច្ចអភិវឌ្ឍន៍សង្គមប្រកបដោយសមធម៌។

## ១.វិស័យសាធារណៈនយោបាយ

តួនាទីស្ត្រីក្នុងឆ្នាំ២០២១ ស្ត្រីមានងារជាសម្តេច៥រូប, ស្ត្រីជាឧបនាយករដ្ឋមន្ត្រី១រូប, ស្ត្រីជាបណ្ឌិតសភាចារ្យ២រូប, ស្ត្រីក្រុមប្រឹក្សាធម្មនុញ្ញស្រី២រូប, ស្ត្រីជាសមាជិកព្រឹទ្ធសភា១០នាក់ (១៦.១៣%), ស្ត្រីជាសមាជិករដ្ឋសភា២៦នាក់ (២០.៨០%), ស្ត្រីជារដ្ឋមន្ត្រី៣នាក់ (១០.៣៤%), ស្ត្រីជារដ្ឋលេខាធិការ៥៩នាក់, ស្ត្រីជាអនុរដ្ឋលេខាធិការ៧៥នាក់, ស្ត្រីជាអភិបាលខេត្ត០២នាក់, ស្ត្រីជាអភិបាលរងខេត្ត-រាជធានី២៥នាក់, ស្ត្រីជាអភិបាលស្រុក-ក្រុង៧នាក់, ស្ត្រីជាអភិបាលរងស្រុក-ក្រុង១៩៤នាក់, ស្ត្រីជាប្រធានក្រុមប្រឹក្សាក្រុង-ស្រុក-ខ័ណ្ឌ៥នាក់, ស្ត្រីជាសមាជិកក្រុមប្រឹក្សាក្រុង-ស្រុក-ខ័ណ្ឌ៦១៧នាក់, ស្ត្រីជាមេឃុំ-ចៅសង្កាត់១៣០នាក់ (៧.៨៩%), ស្ត្រីជាជំទប់ទី១ ២៧២នាក់ (១៦.៣១%), ស្ត្រីជាជំទប់ទី២ ២៨៥នាក់ (១៧.៣១%), ស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ១,៦១១នាក់ (១៤%), ស្ត្រីជាចៅក្រម៤៦នាក់ ១៥.២៨% (២០១៩), ស្ត្រីជាព្រះរាជអាជ្ញា២៥នាក់ (១៣.៥១%), ស្ត្រីជាក្រឡាបញ្ជី១៨៩នាក់ (២២.៧%), ស្ត្រី

ជាមន្ត្រីរាជការ ៤១% (២០២០), ស្ត្រីជាមន្ត្រីរាជាការដែលមានមុខតំណែងចាប់ពី ថ្នាក់ការិយាល័យតាមស្រុក ដល់ថ្នាក់អគ្គនាយក ២៦% (២០២០)។ ក្នុងអង្គនីតិបញ្ញត្តិ នៅក្នុងអាណត្តិទី៦ នៃរដ្ឋសភាមានស្ត្រីចំនួន១រូប ជាអនុប្រធានរដ្ឋសភាស្ត្រីចំនួន២រូប ជាប្រធានគណៈកម្មការ និងស្ត្រីចំនួន៤រូប ជាអនុប្រធានគណៈកម្មការ។ នៅក្នុងអាណត្តិទី៤នៃព្រឹទ្ធសភាមានស្ត្រីជាប្រធានគណៈកម្មការចំនួន២រូប ក្នុងចំណោម១០រូប។ លោកជំទាវបណ្ឌិតសភាចារ្យ ខ្លូត ធីតា ជាស្ត្រីដំបូងគេដែលរាជរដ្ឋាភិបាលប្រគល់តួនាទីជាប្រធានរាជបណ្ឌិតសភា (២០០៩ - ២០១៧)។

រាជរដ្ឋាភិបាលបានបង្កើតក្រសួងកិច្ចការនារី គឺជាយន្តការជាតិមួយសម្រាប់លើកកម្ពស់ស្ថានភាពស្ត្រី ដឹកនាំសម្របសម្រួល បង្កើនភាពអង់អាចដល់ស្ត្រី ដើម្បីសមភាពយេនឌ័រនៅក្នុងប្រទេសកម្ពុជា ព្រមទាំងផ្សារភ្ជាប់ជាមួយគោលការណ៍គ្រឹះ និងអនុសាសន៍នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី, ការបញ្ជ្រាបយេនឌ័រ, ច្បាប់គោលនយោបាយជាតិ ក្របខ័ណ្ឌកំណែទម្រង់របស់រាជរដ្ឋាភិបាល និងតាមវិស័យ, របៀបវារៈសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពដោយមិនទុកអ្នកណាម្នាក់ឱ្យនៅឯកោ, ការវិវត្តថ្មីៗរបស់សង្គមជាសកល នៅក្នុងតំបន់ ក្នុងប្រទេសក៏ដូចជាឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្ម និងការធ្វើឌីជីថលភាវូបនីយកម្ម។ ក្រសួងកិច្ចការនារីបានពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូរជាមួយអង្គការជាតិ អន្តរជាតិដើម្បីចូលរួមចំណែកអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈ មានជាអាទិ៍ៈ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មូលនិធិអន្តរជាតិអភិវឌ្ឍន៍វិស័យកសិកម្ម (IFAD) រដ្ឋាភិបាលអូស្ត្រាលីស្ថានទូតឥណ្ឌា មូលនិធិសកល (Global Fund), Fred Hollow Foundation, DFAT, GIZ, UNFPA, JICA, UNICEF, UNDP, UN Women, Oxfam, Save the Children, CHEC, HEIFER, CARE, GVC, PYD, KWDI, APHEDA ជាដើម។ ក្រសួងកិច្ចការនារីបានចូលរួមក្នុងគណៈកម្មាធិការអាស៊ានដើម្បីស្ត្រី (ACW), គណៈកម្មាធិការអាស៊ានដើម្បីលើកកម្ពស់ និងការពារសិទ្ធិស្ត្រីនិងកុមារ (ACWC)។ ក្រសួងកិច្ចការនារីបានប្រារព្ធជារៀងរាល់ឆ្នាំការរំលឹកខួបស្តីពីការតស៊ូនារីទូទាំងសកលលោកក្នុងការទាមទារឱ្យមានការលើកកម្ពស់សមភាពយេនឌ័រដែលជាយុទ្ធសាស្ត្រគន្លឹះមួយផ្តល់ឱកាសដល់ស្ត្រី និងការអនុវត្តសិទ្ធិស្មើភាពរវាងបុរសនិងស្ត្រី "ទិវានារីអន្តរជាតិ៨មិនា" ដែលផ្តើមចេញពីស្ត្រីក្នុងប្រទេស ឧស្សាហកម្មក្នុងសកលលោកជាង១០០ឆ្នាំកន្លងមក រហូតបានទទួលស្គាល់ពីអង្គការសហប្រជាជាតិ។

ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី ក.ជ.ក.ស ជាយន្តការសម្រាប់សម្របសម្រួលនិងផ្តល់យោបល់ដល់រាជរដ្ឋាភិបាលកម្ពុជាលើបញ្ហាទាក់ទងទៅនឹងស្ថានភាព តួនាទីរបស់ស្ត្រី សុខុមាលភាពសង្គមរបស់ស្ត្រីក្នុងគោលបំណងកាត់បន្ថយ និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ "CEDAW"។ យន្តការជាតិក្នុងការអនុវត្តអនុសញ្ញា ស៊ី-ដ មានក្រុមប្រឹក្សាភិបាលជាតិកម្ពុជាដើម្បីស្ត្រី-ក្រសួងកិច្ចការនារី និងបណ្តាញខ្សែបណ្តោយតាមរយៈមន្ទីរកិច្ចការនារី, មន្ទីរជុំវិញខេត្ត-រាជធានី ក្រសួងស្ថាប័ន និងក្រុមការងារបច្ចេកទេសទទួលបន្ទុកបន្ថែមរបស់ ក.ជ.ក.ស។

រាជរដ្ឋាភិបាលមានចក្ខុវិស័យ និងយុទ្ធសាស្ត្រផ្តោតយ៉ាងជាក់លាក់ទៅលើការលើកកម្ពស់សមភាពយេនឌ័រ និងការអភិវឌ្ឍស្ថាប័ន កំពុងអនុវត្តដើម្បីប្រជាជនរដ្ឋកម្ពុជា ជាពិសេសស្ត្រី និងយុវវ័យ បានរួមចំណែក

អភិវឌ្ឍន៍ប្រទេសឲ្យឈានឆ្ពោះទៅរកភាពចម្រើនរុងរឿង មានជាអាទិ៍ ការធ្វើឲ្យប្រសើរឡើងនូវកំណើនសេដ្ឋកិច្ច ការរក្សានូវសន្តិភាព ស្ថិរភាពនយោបាយ និងសន្តិសុខសង្គមព្រមទាំងការលើកកម្ពស់សិទ្ធិ សេចក្តីថ្លៃថ្នូរ និងសីលធម៌ផងដែរ។ ទន្ទឹមនឹងនេះ ដំណើរការនៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានការរីកចម្រើនគួរឲ្យកត់សម្គាល់ ក៏ជាចំណែកមួយដ៏សំខាន់ក្នុងការលើកកម្ពស់ស្ថានភាព តម្លៃស្ត្រី រួមទាំងសីលធម៌សង្គម វប្បធម៌ និងប្រពៃណីដ៏ល្អផូរផង់របស់កម្ពុជា។

បច្ចុប្បន្នស្ត្រីខ្មែរមាន៥២ភាគរយ ជាស្ត្រីបានសិក្សានិងកំពុងបន្តការសិក្សាជាន់ខ្ពស់ ក៏ដូចជាសិស្សនិស្សិត ជានារី មានតួលេខកាន់តែច្រើនជាងមុន។ គោលការណ៍រាជរដ្ឋាភិបាលចំពោះស្ត្រី បានចាត់ទុកស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ ដោយបង្កើនការវិនិយោគទៅលើការលើកកម្ពស់ សមភាពយេនឌ័រតាមកម្រិតនិងតាមវិស័យ ដូចជាការសិក្សាលើការប្រើប្រាស់បច្ចេកវិជ្ជា សារគមនាគមន៍ ព័ត៌មាន បណ្តាញព័ត៌មានសង្គម។

ការរួមចំណែករបស់ស្ត្រីក្នុងការដោះមីន ក្នុងនាមអង្គការសហប្រជាជាតិ យុទ្ធនារីកម្ពុជាដើម្បីសន្តិភាព ជាអ្នកថែរក្សាសន្តិភាព មានបេសកកម្មនៅប្រទេស លីបង់, ស៊ូដង់ខាងត្បូង សាធារណៈរដ្ឋអាហ្វ្រិកកណ្តាល, ឆាដ, ស៊ីរី, ឡេបាណន និងម៉ាលី ក្នុងឆ្នាំ២០០៦ រហូតដល់បច្ចុប្បន្នមានចំនួន៨៣០០នាក់ ក្នុងនោះមានស្រី ៦០០នាក់ មានស្ត្រីជាវីរសេនីយទោ ជាមេបញ្ជាការរង ជា ម៉ែសារ៉ស់ បានទទួលមេដាយកងកម្លាំងរក្សាសន្តិភាពអង្គការសហប្រជាជាតិនៅប្រទេសឡេបាណនខែមីនា ឆ្នាំ២០២២ (ខ្មែរថៃម៍ ១៦ មិនា ២០២២)។

ស្ត្រីខ្មែរទី១ មៀច សិទ្ធិការ ដេស៊ីការ បានទទួលអាហារូបករណ៍ដែលបញ្ចប់ការសិក្សានៅសាលាបណ្ឌិតយោធា West Point នៃសហរដ្ឋអាមេរិក និងជាស្ត្រីកម្ពុជាមានកាយសម្បទាដែលអាចធ្វើរឿងដ៏អស្ចារ្យនេះ។

កីឡាការិនី កែវ ឡេង ពានយុវតីនិងនារី (២០១៩ លើកទី១៧) ទទួលបានមេដាយមាស៤លើកជាប់គ្នា, កីឡាការិនី ប៉េតង់ឆ្នើម អ៊ុក ស្រីមុំ ទទួលមេដាយមាសកម្រិតពិភពលោក, កីឡាការិនី តៃក្វាន់ដូ ស៊ន សៀវម៉ី បានទទួលមេដាយមាស សម្រាប់ព្រឹត្តិការណ៍ SEA Games ២០១៩។

## ២.វិស័យសេដ្ឋកិច្ច-ឯកជន

ចំណែកស្ត្រីក្នុងវិស័យសេដ្ឋកិច្ច ស្ត្រីបានចូលរួមសកម្មភាពវិស័យសេដ្ឋកិច្ចមានការរីកចម្រើនខ្លាំងលើការពង្រីកកាលានុវត្តភាព។ ការបង្កើតភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ត្រូវបានឆ្លើយតបបន្តបន្ទាប់នៅក្នុងរបៀបវារៈគោលនយោបាយ និងកម្មវិធីជាតិនានាមានជាអាទិ៍ៈ គោលនយោបាយជាតិគាំពារសង្គម, គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ, គោលនយោបាយជាតិស្តីពីមុខរបរនិងការងារ, គោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យមកម្ពុជា, កម្មវិធីអភិវឌ្ឍន៍កសិកម្មនិងជនបទ, កម្មវិធីកំណែទម្រង់ដីធ្លី។

បរិយាកាសសង្គមក្នុងការគាំទ្រ និងលើកកម្ពស់សហគ្រិនភាពស្ត្រី និងភាពជាអ្នកដឹកនាំក្នុងវិស័យធុរកិច្ច បានពង្រីកជាបន្តបន្ទាប់តាមរយៈការកើនឡើងនូវព្រឹត្តការណ៍សាធារណៈឯកជន និងដៃគូពាក់ព័ន្ធតាមបណ្តាញទំនាក់ទំនង និងការផ្សព្វផ្សាយតាមសង្គមដែលរៀបចំឡើងក្នុងភាពជាដៃគូ។ សមាគមសហគ្រិនស្ត្រីកម្ពុជា (CWEA) និងសហព័ន្ធស្ត្រីអ្នកជំនួញកម្ពុជា (CWBF) បាននិងកំពុងដំណើរការយ៉ាងសកម្មក្នុងការអនុវត្តមុខងាររបស់ខ្លួនហើយសហគ្រិនស្ត្រីកម្ពុជាបានចូលរួមជាមួយបណ្តាញសហគ្រិនស្ត្រីអាស៊ាន AWEN បានទទួលពានរង្វាន់សហគ្រិនស្ត្រីឆ្នើមអាស៊ានចំនួន ៣៤នាក់នៅឆ្នាំ២០១៨។ វិស័យឯកជនស្ត្រីអ្នកជំនួញកម្ពុជាបានទទួលងារជាអ្នកឧកញ៉ាចំនួន ៣រូប, ងារជាឧកញ៉ា ១២០រូប។

សម័យសកលភាវូបនីយកម្មទាំងក្នុងជួររាជរដ្ឋាភិបាល និងវិស័យសេដ្ឋកិច្ច ការងារស្ម័គ្រចិត្តឯកជន ស្ត្រីភាគច្រើនបានទទួលជោគជ័យក្នុងជីវិតប្រសើរដោយការខំប្រឹងប្រែងអស់ទាំងកម្លាំងកាយ កម្លាំងចិត្ត ខិតខំព្យាយាម តស៊ូ អំណត់អត់ធន់ដើម្បីរួមចំណែកអភិវឌ្ឍប្រទេសជាតិអោយរីកចម្រើនរុងរឿង។ បច្ចុប្បន្នស្ត្រីភាគច្រើនក្លាយជាអ្នកដឹកនាំក្រុមហ៊ុនដែលមានលំដាប់ថ្នាក់ដូចជាៈ អគ្គនាយិកា, ប្រធានក្រុមប្រឹក្សាភិបាល, នាយិកា, ប្រធាន។ល។ ស្ត្រីដែលដឹកនាំក្រុមហ៊ុនទាំងនោះសុទ្ធតែបានសិក្សាកំរិតខ្ពស់ ក្នុងនិងក្រៅប្រទេស មានទេពកោសល្យ និងជំនាញជាអ្នកដឹកនាំគ្រប់គ្រងអាជីវកម្ម ក្រុមហ៊ុនអោយបានជោគជ័យ។

បច្ចុប្បន្នការងារស្ត្រីចូលជាសកលភាវូបនីយកម្ម ទើបអាចដើរទាន់ពិភពលោក ចំណេះដឹងបច្ចេកវិទ្យាភាសាបរទេសក្បួនខ្នាតដែលបានរៀនសូត្រតាមរបៀបសកលដែលប្រទេសទូទាំងពិភពលោកគេតម្រូវ ដើម្បីដើរអោយស្របគ្នាទូទាំងពិភពលោក មានជាអាទិ៍ លោកជំទាវឧកញ៉ា កែវ មុំ ស្ត្រីដែលបានទទួលមេដាយផ្នែកសហគ្រិន។

ក្នុងកំឡុងពេលជួបវិបត្តិជាសកលនៃជម្ងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់អនុវត្តគោលនយោបាយ និងវិធានការយ៉ាងម៉ឺងម៉ាត់ ម៉ត់ចត់ ក្នុងកំឡុងពេលជួបវិបត្តិជាសកលនៃជម្ងឺកូវីដ-១៩ ដែលបានបន្ថយផលប៉ះពាល់អវិជ្ជមាននានា និងអាចរស់នៅបានជាមួយជម្ងឺកូវីដ-១៩ប្រកបដោយសុវត្ថិភាព ដោយកំណត់យកការចាក់វ៉ាក់សាំងជាយុទ្ធសាស្ត្រគន្លឹះដើម្បីបង្កើតភាពស៊ាំក្នុងសហគមន៍។ តាមរយៈការអនុវត្តវិធានការសុខាភិបាល និងវិធានការចាំបាច់នានា បានផ្តល់ប្រយោជន៍ដល់ប្រជាពលរដ្ឋគ្រប់រូបជាពិសេសស្ត្រី។ ទោះបីមានវិបត្តិជម្ងឺកូវីដ-១៩បានបង្កផលប៉ះពាល់លើស្ត្រីច្រើនជាងបុរសទាំងក្នុងវិស័យសេដ្ឋកិច្ច និងសង្គម ដោយសារស្ត្រីភាគច្រើនមានការងារនៅក្នុងវិស័យសេវាកម្ម និងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ហើយជាមួយគ្នានេះក៏មានការកើនឡើងនូវបន្ទុកថែទាំសមាជិក និងក្រុមគ្រួសារ ព្រមទាំងការអប់រំកូនចៅដែលនាំឱ្យស្ត្រីបាត់បង់ ឱកាសការងារ ប្រាក់ចំណូល និងកិច្ចគាំពារសង្គមផ្សេងៗ ក៏ប៉ុន្តែស្ត្រីនូវតែតស៊ូរស់នៅបទបែនតាមបរិបទថ្មី បន្តក្តីសង្ឃឹមតាមតួនាទីនិងមុខរបររៀងៗខ្លួន។

## ៣.ការងារស្ម័គ្រចិត្ត-សមាគម-អង្គការក្រៅរដ្ឋាភិបាល

ស្ត្រីបានចូលរួមគ្រប់វិស័យនៅក្នុងជួររាជរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈមន្ទីរ-ក្រសួង ស្ថាប័នរដ្ឋ ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ការងារឯកជន កសិកម្ម

ឧស្សាហកម្ម សេដ្ឋកិច្ច។ ការចូលរួមរបស់ស្ត្រីជាដៃគូជាមួយបុរសដែលមិនអាចខ្វះបាន ការងារខ្លះស្ត្រីមានភាពលេចធ្លោជាងបុរសជាអ្នកដឹកនាំក្នុងប្រទេស និងអន្តរជាតិផងដែរ។

ការងារស្ម័គ្រចិត្ត សមាគម និងអង្គការក្រៅរដ្ឋាភិបាលមានអ្នកដឹកនាំជាស្ត្រីដូចជា សមាគមកាកបាទក្រហមកម្ពុជា, សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍, សមាគមកាយឫទ្ធិនារីកម្ពុជា។ល។

សមាគមជាតិកាកបាទក្រហមកម្ពុជា ក៏ជាគោលការណ៍សកលភាព ចលនាកាកបាទក្រហម និងអឌ្ឍចន្ទក្រហមអន្តរជាតិដែលក្នុងនោះសមាគមជាតិ និងមានការទទួលខុសត្រូវ និងករណីកិច្ចដូចៗគ្នាក្នុងការជួយគ្នាទៅវិញទៅមក គឺជាចលនាលក្ខណៈជាសកល ដែលមានសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុនសែន ជាប្រធាន។

សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ន.ក.ស.អ (CWPD), ដែលមានកិច្ចសហការជាមួយអង្គការក្រៅរដ្ឋាភិបាល UNFPA, UNDP, UN Women, UNICEF, GIZ/SPECE, SILAKA, GAD, OMC, PYD ជាដៃគូអភិវឌ្ឍន៍ធនធានមនុស្សដែល ធ្វើការនៅក្នុងអង្គការទាំងនេះសុទ្ធតែមានចំណេះដឹងជាខ្នាតអន្តរជាតិ ដើម្បីធ្វើការទំនាក់ទំនងរបាយការណ៍ អោយបានច្បាស់លាស់ដែលមានលោកជំទាវសង្គហបណ្ឌិត ម៉ែន សំអន ជាប្រធាន។

សមាគមកាយឫទ្ធិនារីកម្ពុជា ស.ក.ន.ក (GGAC) ក៏ជាចលនាកាយឫទ្ធិនារីពិភពលោក (WAGGGS) World Association of Girl Guiles and Girl Scouts ចលនានេះរីកដុះដាលនៅឆ្នាំ១៩២៨ នៅក្នុងប្រទេសជាច្រើនក្នុងពិភពលោក ដែលមានសមាជិកជាង ១០លាននាក់ នៅក្នុងតំបន់ ៥ ទ្វីប មាន Asia Pacific Region, Europe Region, Western Hemisphere Region, Arab Region, Africa Region ជាសកម្មភាពសកល មានគោលដៅអប់រំក្រៅប្រព័ន្ធដែលផ្តល់ឲ្យកុមារី យុវតី សាកល្បងសកម្មភាពផ្សេងៗដើម្បីអោយពួកគេមានការទុកចិត្តលើខ្លួនឯង និងចាប់អារម្មណ៍លើបញ្ហាសង្គមសមាគមកាយឫទ្ធិនារីកម្ពុជាដែលដឹកនាំដោយលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី។

សតវត្សទី២១គឺសម័យមួយដែលចរន្តសកលភាវូបនីយកម្មកំពុងមានសន្ទុះខ្លាំងក្លាគួរឱ្យកត់សម្គាល់។ ចរន្តសកលភាវូបនីយកម្មនេះបានជម្រុញឱ្យពិភពលោកស្ថិតក្នុងសភាពប្រកួតប្រជែងគ្រប់វិស័យ។ ការប្រកួតប្រជែងនេះមានលក្ខណៈទូលំទូលាយ ហើយរាលដាលចេញពីប្រទេសមួយទៅប្រទេសមួយទៀតរហូតពេញពិភពលោក។ ការប្រកួតប្រជែងដែលធ្វើឡើងដោយស្របច្បាប់រដ្ឋ ស្របតាមគោលការណ៍សិទ្ធិមនុស្ស និងស្របតាមគោលការណ៍សីលធម៌ អាចធ្វើឱ្យក្រុមមួយ សង្គមមួយ ប្រទេសមួយនិងពិភពលោកឈានទៅរកវឌ្ឍនភាព សុភមង្គល និងសន្តិភាព។ ផ្ទុយទៅវិញការប្រកួតប្រជែងទាំងឡាយណាដែលមិនស្របច្បាប់រដ្ឋ មិនស្របគោលការណ៍សិទ្ធិមនុស្ស មិនស្របគោលការណ៍សីលធម៌នោះអាចឱ្យក្រុមមួយ សង្គមមួយ ប្រទេសមួយ រួមទាំងពិភពលោកកើតនូវភាពអនាធិបតេយ្យ មានអំពើហឹង្សា មានអំពើអសីលធម៌ដែលអាចនាំឱ្យសង្គមមនុស្សទាំងអស់ឆ្ពោះទៅរកអសន្តិសុខ អស្ថិរភាពនិងសង្គ្រាម។

## ៤.ស្ត្រីមេផ្ទះ

ស្ត្រីកម្ពុជាមានការទទួលខុសត្រូវច្រើន ដូចជាស្ត្រីអ្នកធ្វើការងារមេផ្ទះ និងថែទាំកូន កាន់តួនាទីយ៉ាងសំខាន់បំផុតក្នុងជីវភាពគ្រួសារ រកប្រាក់ចំណូលបន្ថែមសម្រាប់គ្រួសារ ទោះជាមានវត្តមានរបស់ប្តី ឬឪពុកក៏ដោយ គ្រួសារភាគច្រើនមិនអាចរស់បានដោយប្រាក់ចំណូលពីសហព័ន្ធតែម្នាក់បានទេ ស្ត្រីជាអ្នកដឹកនាំសេដ្ឋកិច្ចគ្រួសារ ដូចជាប្រកបមុខរបរខ្នាតតូច គ្រួសារ-មធ្យម-ធំ ផ្គត់ផ្គង់កូនចៅបានរៀនសូត្រដ៏ប្រសើរ។ ស្ត្រីជាមេផ្ទះខ្លះទទួលបានការអប់រំ ២ឬ៣ឆ្នាំក៏ជាផលិតករដ៏ល្អអាចរកប្រាក់ចំណូលដល់គ្រួសាររបស់គេដែរ។ នេះបានបង្ហាញតួនាទីរបស់បុរសនិងស្ត្រី នៅក្នុងការធ្វើសេចក្តីសម្រេចក្នុងគ្រួសារ ការគ្រប់គ្រងធនធាននិងទ្រព្យសម្បត្តិផ្សេងៗ និងការឱ្យតម្លៃទៅលើតួនាទីរបស់ស្ត្រីក្នុងការងារផ្ទះសម្បែង។

រួមសេចក្តីមកស្ត្រីក្នុងសម័យសកលភាវូបនីយកម្មមានឱកាសនិងមានសមត្ថភាពទទួលបានចំណេះដឹងភាសាបរទេស, ជំនាញ, បច្ចេកវិទ្យាអាចទំនាក់ទំនងនៅក្នុងនិងក្រៅប្រទេសជាសកល មានភាពឯករាជ្យម្ចាស់ការ ការទទួលខុសត្រូវខ្ពស់ដែលធ្វើឱ្យស្ត្រីមានឱកាសចូលរួមការងារអភិវឌ្ឍន៍ប្រទេសជាតិគ្រប់វិស័យដូចបុរសដែរ។ លទ្ធផលទាំងអស់នេះ បានមកអំពីការទទួលស្គាល់ ការលើកកម្ពស់សមភាពយេនឌ័រនិងសុខុមាលភាពសង្គមរបស់ស្ត្រីក្នុងគោលបំណងកាត់បន្ថយនិងលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទដែលរាជរដ្ឋាភិបាលបានផ្តោតយកចិត្តទុកដាក់តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ជាពិសេសស្ត្រីខ្លួនឯងត្រូវតែបង្កើនចំណេះដឹង បង្ហាញពីសមត្ថភាព ស្នាដៃ ការតស៊ូ ភាពក្លាហានរបស់ខ្លួនប្រកបដោយសេចក្តីថ្លៃថ្នូរ និងសីលធម៌ខ្ពស់ដែលសង្គមគេទទួលស្គាល់ និងឱ្យតម្លៃ។

© ២០២២ រាជបណ្ឌិត្យសភាកម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង
គ្មានផ្នែកណាមួយនៃទស្សនាវដ្ដីនេះនឹងត្រូវបានបោះពុម្ពឡើងវិញ
ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីរាជបណ្ឌិត្យសភាកម្ពុជាឡើយ។

©2022 Royal Academy of Cambodia
All rights reserved,
no part of this book may be reproduced,
in any form, by any means, without permission in writing from
Royal Academy of Cambodia.



**Royal Academy of Cambodia**
Russian Federation Blvd
P.O.Box: 531 Phnom Penh
Kingdom of Cambodia
Tel: (855) 23 890 180
Fax: (855) 23 890 180
Email: info@rac.gov.kh
Website: www.rac.gov.kh

**រាជបណ្ឌិត្យសភាកម្ពុជា**
**មហាវិថីសហព័ន្ធរុស្ស៊ី**
**ប្រអប់សំបុត្រលេខ ៥៣១ ភ្នំពេញ**
**ព្រះរាជាណាចក្រកម្ពុជា**
**ទូរសព្ទលេខ**: (៨៥៥)២៣ ៨៩០១៨០
**ទូរសារលេខ**: (៨៥៥)២៣ ៨៩០១៨០
**អ៊ីម៉ែល**: info@rac.gov.kh
**វេបសាយ**: www.rac.gov.kh